ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- យុត្តិធម៌បំពេញបន្ថែម
- អង្គហេតុពិត : ប៉ុល ពត និងអ្នកទោសនៅមន្ទីរ ស-២១

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣៤ ខែកុម្ភៈ ឆ្នាំ២០១១

# ស្វែងរកការពិត

លេខ១៣៨ ខែកុម្ភៈ ឆ្នាំ២០១១

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆យុត្តិធម៌បំពេញបន្ថែម ....... ១

**ផ្នែកឯកសារ**

◆ការប្រជុំជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា ....... ១៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆អង្គហេតុពិត ៖ ប៉ុល ពត និងអ្នកទោសនៅមន្ទីរស-២១ ....... ២៦

◆ជីវិតបដិវត្តន៍របស់យុទ្ធនារី ឡៃ ស៊ីម ....... ៣២

◆គស្ញូចិញ្ចឹមឪពុកម្ដាយក្មេកក្នុងរបបខ្មែរក្រហម ....... ៣៥

◆អតីតកម្មាភិបាលនៅដីរំថ្មដា ....... ៣៨

◆ឃឹម សុធា ៖ កុមាររើសអាចម៍គោ ....... ៤០

**ផ្នែកច្បាប់**

◆តើអ្វីជាអំពើប្រល័យពូជសាសន៍? ....... ៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ចុះបើ តាម៉ុក នៅរស់វិញ? ....... ៥៥

◆ការពិភាក្សាជាមួយផលិតកររឿង «វាលពិឃាត» ....... ៥៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ស្វែងរកសាច់ញាតិនៅក្នុងរូបថត ....... ៦០




លោកជំទាវ ទន់ សាអ៊ីម មើលទស្សនាវដ្ដីស្វែងរកការពិត




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ*** ៖ *ចាយ៉ា រ៉ាមជី, លី សុខឃាង, ឌី ខាំបូលី, វីលៀម សាបាស់, ចេន អានហ៊ីល, កែវ ដាស៊ីល* ***អ្នកនិពន្ធនិងស្រាវជ្រាវ៖*** *គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា* ***អ្នកបកប្រែ៖*** *ជា ផល្លា* ***និពន្ធនាយកទូទៅ៖*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយក៖*** *ញាណ សុជាតិ, ទេព ម៉េងឃាន* ***ក្រាហ្វិកកុំព្យូទ័រ៖*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយ៖*** *ម៉ម សុជាត* Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# យុត្តិធម៌បំពេញបន្ថែម :

## ការរៀបចំយន្តការមួយសម្រាប់ការចងចាំ និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា

### សេចក្តីផ្តើម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចគោលដៅដ៏ជោគជ័យរបស់ខ្លួនក្នុងការកាត់ទោស «មេដឹកនាំជាន់ខ្ពស់» ខ្មែរក្រហម ។ យន្តការសម្រាប់យុត្តិធម៌អន្តរកាលដែលផ្តោតលើតម្រូវការរបស់ប្រទេសកម្ពុជាបំពេញបំណងស្វែងរកយុត្តិធម៌ និងផ្តល់ជាសំណងដែលប្រជាជនកម្ពុជាយល់ថាសមរម្យអាចក្លាយជាការជួយបំពេញបន្ថែមដល់តុលាការ ។ ជាញឹកញាប់ គណៈកម្មការស្វែងរកការពិតតែងតែត្រូវបានស្នើឲ្យបង្កើតឡើងដោយសារតែលក្ខណៈប្រែប្រួល និងលទ្ធភាពរបស់គណៈកម្មការនេះក្នុងការផ្តល់ជាដំណើរការទទួលខុសត្រូវដ៏សំខាន់តាមទំនៀមទម្លាប់វប្បធម៌ ។ ប្រព័ន្ធយុត្តិធម៌អន្តរកាលដ៏ជោគជ័យមួយនៅក្នុងប្រទេសកម្ពុជាត្រូវតែបំពេញទៅតាមលក្ខណ្ឌរបស់ខ្លួន និងបរិបទវប្បធម៌របស់ប្រជាជន ។

គណៈកម្មការស្វែងរកការពិតផ្តល់នូវឆន្ទៈបំពេញតម្រូវការរបស់សង្គមកម្ពុជា ។ យ៉ាងណាមិញ ដូចគ្នានឹងទម្រង់យុត្តិធម៌អន្តរកាលផ្សេងទៀតដែរ គណៈកម្មការនេះនឹងជួបបញ្ហាប្រឈមមុខនានា ។ រហូតមកដល់សព្វថ្ងៃនេះ គណៈកម្មការស្វែងរកការពិតស្ទើរតែទាំងអស់ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសដែលប្រណិប័តន៍ជំនឿគ្រិស្តសាសនា ។ ដើម្បីធ្វើឲ្យគណៈកម្មការស្វែងរកការពិតអាចឈានទៅរកការផ្សះផ្សា និងយុត្តិធម៌នៅក្នុងប្រទេសដែលមិនប្រណិប័តន៍ជំនឿគ្រិស្តសាសនាបាន លុះត្រាតែគណៈកម្មការនេះត្រូវរួមបញ្ចូលពុទ្ធសាសនិកនិងអ្នកកាន់សាសនាអ៊ីស្លាមនៅក្នុងដំណើរការផ្សះផ្សានោះ ។ នៅក្នុងប្រទេសកម្ពុជា គណៈកម្មការស្វែងរកការពិតដ៏ចម្រូងចម្រាសនេះគួរតែឆ្លុះបញ្ចាំងឲ្យឃើញពីតម្លៃរបស់ពុទ្ធសាសនិក និងអ្នកកាន់សាសនាអ៊ីស្លាមដោយធ្វើការយកចិត្តទុកដាក់ចម្បងលើមេដឹកនាំសាសនា បំពេញតម្រូវការប្រជាជនកម្ពុជា និងបញ្ចូលសំណងជានិមិត្តរូប និងសំណងផ្សេងទៀតដែលអាចជួយអភិវឌ្ឍន៍តម្លៃរបស់សង្គមនេះបាន ។ ដើម្បីធ្វើជាគំរូដ៏ល្អបំផុតនោះ អនុស្សរណៈនេះធ្វើការផ្តោតទៅលើតម្រូវការរបស់សង្គមកម្ពុជា ដូចដែលបានឃើញនៅក្នុងការស្ទាបស្ទង់មតិឆ្នាំ២០០៩ ដែលស្រាវជ្រាវដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់សកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ើឃ្លី ដោយផ្តោតលើបទពិសោធន៍ដែលដកស្រង់ចេញពីគណៈកម្មការស្វែងរកការពិតផ្សេងៗទៀត ហើយទាញយកមតិឆ្លើយតបរបស់ប្រជាជនកម្ពុជាដែលមានចំពោះតុលាការកាត់ទោស «មេដឹកនាំជាន់ខ្ពស់» ខ្មែរក្រហម ។ ជាក់ស្តែង គណៈកម្មការស្វែងរកការពិតដ៏ជោគជ័យមួយអាចនឹងឈានទៅដល់ការទទួលខុសត្រូវ និងជួយប្រជាជនកម្ពុជារៀបរាប់ពីភាពអន្ទកាលនៅក្នុងរបបខ្មែរក្រហមដែលកើតមាននៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

### គណៈកម្មការស្វែងរកការពិត

គណៈកម្មការស្វែងរកការពិតគឺជាយន្តការសម្រាប់យុត្តិធម៌អន្តរកាលមួយ ដែលមានអំណាចក្នុងការស៊ើបអង្កេត និងដោះស្រាយអំពើហិង្សាលើសិទ្ធិមនុស្សកាលពីអតីតកាល ។ ការផ្តល់និយមន័យទៅលើពាក្យគណៈកម្មការស្វែងរកការពិតមានការលំបាកជាងប្រភេទនៃយុត្តិធម៌អន្តរកាលផ្សេងទៀត ដូចជា តុលាការអន្តរជាតិព្រោះថា គណៈកម្មការស្វែងរកការពិតនេះទោរទន់ទៅតាមសង្គមនិងកាលៈទេសៈរបស់សង្គមនីមួយៗ ។ លក្ខណៈសម្គាល់ទូទៅខ្លះនៃគណៈកម្មការស្វែងរកការពិតរួមមាន «គោលបំណងលាតត្រដាងអំពើហិង្សាដែលមានលក្ខណៈទ្រង់ទ្រាយធំជាជាងការសង្កត់ធ្ងន់លើព្រឹត្តិការណ៍ដាច់ដោយឡែកមួយ...ហើយការទទួលបាននូវអំណាចមួយចំនួនដោយធ្វើឲ្យមានការទទួលបានព័ត៌មាននិងសន្តិសុខ ។ ខុសពីតុលាការអន្តរជាតិ គណៈកម្មការស្វែងរកការ

ពិតមិនមែនជាក្រុមអ្នកធ្វើការកាត់ទោស ហើយមិនរៀបចំដំណើរការតុលាការដែលផ្តល់លទ្ធផលជាការប្រកាសទោសនោះទេ ។ គោលដៅចម្បងបំផុតខ្លះៗរបស់គណៈកម្មការស្វែងរកការពិតអាចមានដូចជា ការទទួលស្គាល់ពីឧក្រិដ្ឋកម្ម ការផ្តល់ឱកាសឲ្យជនរងគ្រោះនិយាយអំពីរឿងរ៉ាវរបស់ខ្លួន និងការផ្តល់ជារឿងរ៉ាវប្រវត្តិសាស្ត្រទាក់ទងនឹងកត្តាផ្សេងៗ ដែលបណ្តាលឲ្យមានអំពើសម្លាប់សាហាវយោរយៅទ្រង់ទ្រាយធំ ។ គណៈកម្មការស្វែងរកការពិតមានគោលដៅធ្វើយ៉ាងណាឲ្យយុវជនជំនាន់ក្រោយបានយល់ដឹងពីអ្វីដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ដោយភ្ជាប់ជាមួយនឹងគោលដៅចម្បងក្នុងការការពារមិនឲ្យអំពើសម្លាប់សាហាវយោរយៅកើតឡើងម្តងទៀត ។

ស្រដៀងគ្នានឹងតុលាការអន្តរជាតិ គណៈកម្មការស្វែងរកការពិតមានចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗក្នុងការដោះស្រាយអំពើហិង្សាលើសិទ្ធិមនុស្ស ។ ជាទូទៅ មានក្តីបារម្ភពីរយ៉ាងដែលលើកឡើងដោយក្រុមអ្នកសិក្សាស្រាវជ្រាវគឺថា គណៈកម្មការស្វែងរកការពិតអាចនឹងបរាជ័យក្នុងការលាតត្រដាងពីការពិត បើទោះបីជាគណៈកម្មការនេះត្រូវបានចាត់ទុកថា បានធ្វើការឆ្លើយតបទៅតាមតម្រូវការរបស់ប្រទេសនីមួយៗក៏ដោយ ។ ដូច្នេះ ដំណើរការស៊ើបអង្កេតដ៏ហ្មត់ចត់លើអំពើហិង្សាពីអតីតកាលអាចនឹងមិនមានលក្ខណៈសមស្រប ឬអាចប៉ះពាល់វប្បធម៌ចំពោះការពិតរបស់សង្គមដែលបានរងគ្រោះ ដោយអំពើហិង្សាទ្រង់ទ្រាយធំ ។ ជាឧទាហរណ៍ គណៈកម្មការស្វែងរកការពិតបានទទួលបរាជ័យក្នុងការដោះស្រាយបញ្ហាអំពើសម្លាប់យ៉ាងសាហាវយោរយៅក្នុងទ្រង់ទ្រាយធំដែលជាប់ពាក់ព័ន្ធនឹងសហគមន៍អន្តរជាតិ ហើយមិនបានបំពេញទៅតាមតម្រូវការវប្បធម៌ ឬបានមើលរំលងប្រភេទជម្លោះ ដែលត្រូវបានដោះស្រាយកាលពីមុន ។

បើទោះបីជាត្រូវបានចាត់ទុកថាជាគណៈកម្មការគំរូដែលទទួលបានជោគជ័យខ្ពស់ក៏ដោយ ក៏គណៈកម្មការផ្សះផ្សា និងស្វែងរកការពិតរបស់ប្រទេសអាហ្វ្រិកខាងត្បូង នៅតែមានចំណុចខ្វះខាតដែលត្រូវរិះគន់ដដែល ។ អ្នកចូលរួមដែលជាជនរងគ្រោះខ្លះគិតថាខ្លួនគេមិនអាចនិយាយពី «ការពិត» ឬទទួលយកសំណងខូចខាតដែលអ្នកទាំងនេះបានទទ្ទឹងរង់ចាំជាយូរមកហើយនោះទេ ។ ចំណែកគណៈកម្មការផ្សះផ្សា និងស្វែងរកការពិតនៅប្រទេសសេរ៉ាឡេអូនវិញក៏បានលើកឡើងពីក្តីព្រួយបារម្ភអំពីគណៈកម្មការស្វែងរកការពិត ក្រោយអំពើសម្លាប់សាហាវយោរយៅដែរ ។ ឧទាហរណ៍ ប្រជាជនសេរ៉ាឡេអូនមានមធ្យោបាយពិសេសរបស់ខ្លួនក្នុងការដោះស្រាយជម្លោះដោយធ្វើការ «ទទួលស្គាល់យោធា តស៊ូចងសម្ព័ន្ធមិត្តភាព និងស្ថាបនាសហគមន៍ដែលប្រកបដោយសីលធម៌» ហើយអនុវត្តយន្តការបំភ្លេចចោលសង្គមអន្តរកាលដែលប្រើប្រាស់ឡើងដើម្បី «រំងាប់អារម្មណ៍» ជនរងគ្រោះនិងកសាងសហគមន៍របស់ខ្លួនសាជាថ្មីម្តងទៀត ។ ផ្ទុយទៅវិញ គណៈកម្មការផ្សះផ្សានិងស្វែងរកការពិតនៅប្រទេសសេរ៉ាឡេអូនបានរំខានដល់ដំណើរដោះស្រាយជម្លោះដែលអនុវត្តដោយប្រជាជនសេរ៉ាឡេអូន ដូចដែលបានលើកឡើងខាងលើ ។

## តម្រូវការរបស់ប្រទេសកម្ពុជា

គណៈកម្មការស្វែងរកការពិតនៅកម្ពុជាអាចនឹងជួយបំពេញបន្ថែមលើកិច្ចការរបស់តុលាការកាត់ទោស «មេដឹកនាំជាន់ខ្ពស់» ខ្មែរក្រហម ដែលមានរយៈពេលយូរ ដោយធ្វើឲ្យមានការចូលរួមច្រើន និងការទទួលស្គាល់ពីជនរងគ្រោះ ប្រសិនបើគណៈកម្មការនេះត្រូវបានដំណើរការឡើងដោយមានការយកចិត្ត


កិច្ចប្រជុំប្រចាំឆ្នាំស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅខេត្តព្រះវិហារ

ទុកដាក់យ៉ាងចម្បងលើការបំពេញទៅតាមលក្ខខណ្ឌរបស់ប្រទេសកម្ពុជា ។ ការស្រាវជ្រាវនៅឆ្នាំ២០០៩ របស់សកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ើឃ្លី ស្ដីពីតម្រូវការរបស់ប្រជាជនកម្ពុជាបានរកឃើញថា ៨៥,៥ភាគរយនៃអ្នកឆ្លើយតបបានយល់ស្របនឹងប្រយោគដែលថា «វាពិតជាមានសារសំខាន់ក្នុងការស្វែងរកការពិតពីអ្វីដែលបានកើតឡើងក្នុងអំឡុងរបបខ្មែរក្រហម» ។ ដូច្នេះ គណៈកម្មការស្វែងរកការពិតរបស់ប្រទេសកម្ពុជាគួរតែផ្ដោតទៅលើការចងក្រងបទពិសោធន៍ ប្រជាជនកម្ពុជាទុកជាឯកសារ និងវិភាគលើបទពិសោធន៍ទាំងនោះទាំងក្នុងអំឡុង និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ បង្កើតជាសាច់រឿងប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងអំពើហិង្សា ដោយរួមបញ្ចូលទាំងគោលបំណង និងការកកើតឡើងនៃរបបនេះ ហើយធ្វើការអប់រំជនរងគ្រោះ និងយុវជនជំនាន់ក្រោយពីប្រវត្តិសាស្ត្រកម្ពុជានេះ ។

មតិឆ្លើយតបទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានគោលដៅជួយដល់វិធានផ្លូវច្បាប់ ការទាមទារយុត្តិធម៌ និងការផ្សះផ្សាត្រូវតែចាប់ផ្ដើមឡើងដោយត្រូវសួរថា តើប្រជាជនដែលបានរស់នៅជំនាន់នោះចង់បានអ្វី ។ ការស្រាវជ្រាវរបស់សកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ើឃ្លី បានគូសបញ្ជាក់ឲ្យឃើញពីខ្លឹមសារសំខាន់ពីរដែលគួរតែធ្វើការដោះស្រាយនៅក្នុងការបង្កើតជាគណៈកម្មការស្វែងរកការពិត ដើម្បីឲ្យគណៈកម្មការនេះធ្វើការឆ្លុះបញ្ចាំងពីតម្រូវការរបស់សង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ ។


លោកគ្រូឡើងផ្ដល់យោបល់អំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ទីមួយ ការស្រាវជ្រាវបង្ហាញឲ្យឃើញថា ប្រជាជនកម្ពុជាពិតជាចង់ស្វែងរកការពិតពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ទីពីរ ឥរិយាបថរបស់ប្រជាជនកម្ពុជាមានចំពោះការរស់នៅជាមួយនឹងអតីតខ្មែរក្រហមបានគូសបញ្ជាក់ពីភាពស្មុគស្មាញនៃការផ្សះផ្សា និងការដាក់ទោស ដែលមាននៅក្នុងវប្បធម៌របស់ប្រទេសកម្ពុជា ។ គណៈកម្មការស្វែងរកការពិតភាគច្រើនពឹងផ្អែកយ៉ាងខ្លាំងទៅលើភាពសហការពីជនដៃដល់ ដូច្នេះហើយបានជាការយល់ដឹងពីឥរិយាបថរបស់ប្រជាជនកម្ពុជាដែលមានចំពោះកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមមានសារសំខាន់ ។ សរុបមក ការស្រាវជ្រាវនេះបានបង្ហាញថា ប្រជាជនកម្ពុជាចង់ឃើញជនដែលទទួលខុសត្រូវចំពោះរបបខ្មែរក្រហមត្រូវបានកាត់ទោស ហើយអ្នកទាំងអស់នេះជឿថា យុត្តិធម៌គឺជាដំណើរការមួយស្ដីពីការលាតត្រដាងការពិត ។

ការស្ទាបស្ទង់មតិរបស់សកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ើឃ្លី គូសបញ្ជាក់ថា ប្រជាជនកម្ពុជាភាគច្រើនចង់ដឹងពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ៧០ភាគរយក្នុងចំណោមអ្នកដែលរស់នៅក្រោមរបបខ្មែរក្រហមបានអះអាងថា អ្នកទាំងនេះចង់ដឹងបន្ថែមទៀតពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ហើយ៨០ភាគរយក្នុងចំណោមអ្នកដែលមិនបានរស់នៅក្រោមរបបខ្មែរក្រហមក៏ចង់ដឹងពីរបបនេះដែរ ។ បើទោះបីជាប្រជាជនកម្ពុជាទាំងអ្នកបានរស់នៅ ឬមិនបានរស់នៅក្រោមរបបខ្មែរក្រហមចង់ស្វែងរកការពិតពីអ្វីដែលបានកើតឡើងនៅក្នុងរបបនេះក៏ដោយ ក៏មានមនុស្សតិចជាង៥០ភាគរយ មានឆន្ទៈចូលរួមនៅក្នុងការពិភាក្សាជាសាធារណៈ និងការនិយាយរៀបរាប់ពីបទពិសោធន៍របស់ខ្លួនដែរ ។

ទស្សនៈដែលឆ្លុះបញ្ចាំងពីការទទួលខុសត្រូវដោយប្រជាជនកម្ពុជា នាពេលបច្ចុប្បន្ននេះ បានគូសបញ្ជាក់ឲ្យឃើញពីការគាំទ្រយ៉ាងខ្លាំងក្លាចំពោះការកាត់ទោសជនដែលទទួលខុសត្រូវចំពោះរបបខ្មែរក្រហម ។ ទោះបីជា ៩៨ភាគរយនៃអ្នកដែលត្រូវបានស្ទាបស្ទង់មតិ

ដោយការស្រាវជ្រាវរបស់សកលវិទ្យាល័យកាលីហ្វ័រញ៉ា នៅបើឃ្លីបានបញ្ជាក់ថា អ្នកទាំងអស់ជាពុទ្ធសាសនិកក៏ដោយ ក៏ការស្វាបស្ទង់មតិនេះមិនបានផ្ដោតទៅលើការដាក់ទោសដែលផ្អែកលើមូលដ្ឋានវប្បធម៌នោះទេ ។ ដូច្នេះការស្រាវជ្រាវបន្ថែមចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់លាស់ពីទម្រង់បែបបទនៃការដាក់ទោសនេះ ។ លើសពីនេះទៅទៀត ទោះបីជាជនជាតិភាគតិចអ៊ីស្លាមមានចំនួនតិចក៏ដោយ ក៏ទស្សនៈសាសនារបស់ក្រុមនេះគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការរបស់គណៈកម្មការស្វែងរកការពិត ជាពិសេសគឺនៅក្នុងតំបន់ដែលមានប្រជាជនចាមរស់នៅច្រើន ។

បើនិយាយពីការទទួលខុសត្រូវវិញ អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ខាងពុទ្ធសាសនាហីនយាន អៀន ហារីស បាន អះអាងថា ពុទ្ធសាសនិកកម្ពុជាបានយល់ស្របតាមខ្លឹមសារបីរបស់ព្រះពុទ្ធ ។ ខ្លឹមសារទាំងនេះគឺជាការគាំទ្រលើវិធានការអន្តរជាតិ ដែលនៅមានកម្រិតចំពោះតុលាការកាត់ទោស ដែលជាគោលដៅដើម្បីធានាថា ការទទួលខុសត្រូវគោរពទៅតាមឥរិយាបថរបស់ពុទ្ធសាសនាហីនយាន និងជាការផ្ដោតទៅលើការផ្សះផ្សា «ដែលត្រូវបានយល់ថាជាការផ្សះផ្សារបស់ពិភពលោកស្របទៅតាមផ្លូវធម៌» ។

ព្រះសង្ឃពុទ្ធសាសនានៅកម្ពុជាបានផ្ដល់សេចក្ដីណែនាំបន្ថែមលើអត្ថន័យនៃការផ្សះផ្សាតាមលក្ខខណ្ឌវប្បធម៌ ។ ឧទាហរណ៍ លោកបណ្ឌិត ឡៅ ម៉ុងហៃ អតីតនាយកប្រតិបត្តិនៃវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យបានគាំទ្រការផ្សះផ្សាជាតិពីព្រោះវាមានទស្សនៈដូចគ្នានឹងទស្សនវិជ្ជារបស់ព្រះពុទ្ធដែរ ។ ការយកចិត្តទុកដាក់លើការរំសាយកំហឹងតាមផ្លូវព្រះពុទ្ធសាសនាគឺធ្វើឡើងដើម្បីលាងជម្រះចិត្តគំនិតគុំគួននោះតាមរយៈការធ្វើឲ្យសតិអារម្មណ៍ស្ងប់ស្ងាត់ និងដើម្បីការពារចំណងមិត្តភាពរវាងមនុស្ស និងមនុស្សទាំងអស់ ។

ក្រុមអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់បានអះអាងថា ការសុំខមាទោសជាលក្ខណៈថ្នាក់ជាតិ ដែលជាសកម្មភាពបង្ហាញការពិតជាផ្លូវការដែលត្រូវបានមើលឃើញដោយមេដឹកនាំសាសនាហើយ ដែលមានព្រះមហាក្សត្រធ្វើជាគណៈអធិបតីនោះ «អាចក្លាយជាការផ្ដោតលើដំណើរការផ្សះផ្សាជាតិជានិមិត្តរូបបាន» ។ ការប្រារព្ធពិធីរួមដូចជា ពិធីបុណ្យភ្ជុំបិណ្ឌអាចរៀបចំឡើងដើម្បីបួងសួងដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្រោមរបបខ្មែរក្រហមដើម្បីចាប់ផ្ដើមការកាន់ទុក្ខ ការព្យាបាលរបួសនិងដំណើរការផ្សះផ្សា ។ ការបំពេញទៅតាមតម្រូវការរបស់បុគ្គល និងតម្រូវការរួមសម្រាប់ការកាន់ទុក្ខនេះ មិនមែនជាកិច្ចការងាយស្រួលនោះទេ ។ យ៉ាងណាមិញ វប្បធម៌កម្ពុជាក៏បានផ្ដល់ជាសេចក្ដីណែនាំមួយចំនួនដែរ ។ ដូចគ្នានឹងពិធីបុណ្យភ្ជុំបិណ្ឌ គណៈកម្មការស្វែងរកការពិតគួរតែផ្ដល់ឱកាសឲ្យបុគ្គលម្នាក់ៗធ្វើការចងចាំអ្នកដែលបានស្លាប់ទៅហើយនោះ ដោយបង្ហាញឲ្យឃើញពីសារសំខាន់ និងការយល់ដឹងពីវប្បធម៌ ។ ចុងក្រោយបង្អស់ គណៈកម្មការស្វែងរកការពិតនឹងពឹងផ្អែកលើការចូលរួមរបស់បុគ្គលនីមួយៗ ធ្វើដូច្នេះនឹងបង្កើតបរិយាកាសមួយដែលគ្មានការបែងចែករវាងជនដៃដល់ ជនរងគ្រោះ និងអ្នកកាន់ទុក្ខដែលអាចនឹងជួយលើកតម្កើងការចងចាំ ការកាន់ទុក្ខ និងការផ្សះផ្សាបានយ៉ាងល្អជាមិនខាន ។


បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ចែកទស្សនាវដ្ដីស្វែងរកការពិត ដល់អ្នកភូមិនៅខេត្តព្រះវិហារ

មនុស្សមួយភាគធំដែលកំពុងរស់នៅជាមួយនឹងអតីតខ្មែរក្រហមបានរំពុកពីអារម្មណ៍ខឹងសម្បារបស់ខ្លួន ហើយជាច្រើននាក់ទៀតមានបំណងចង់សងសឹក ។ នេះគឺជាបញ្ហាវឹកវរ ពីព្រោះថាមនុស្សដែលធ្លាប់ឆ្លងកាត់ការភ័យខ្លាចបញ្ហាជំងឺផ្លូវចិត្តអស់រយៈពេលយ៉ាងយូរ ហើយរងអំពើហិង្សាដោយផ្ទាល់អាចនៅតែចងចាំសត្រូវរបស់ខ្លួន ហើយងាយនឹងរងគ្រោះ និងទទួលឥទ្ធិពលពីការបោកបញ្ឆោតផ្សេងៗ ។ បញ្ហាមួយទៀតគឺថា កម្មាភិបាលខ្មែរក្រហមថ្នាក់កណ្ដាល និងថ្នាក់ក្រោមកំពុងតែរស់នៅជាមួយនឹងជនរងគ្រោះយ៉ាងជិតស្និទ្ធ ។ តាមការស្រាវជ្រាវរបស់សកលវិទ្យាល័យកាលីហ្វ័រញ៉ានៅបើឃ្លី បានធ្វើការកត់សម្គាល់ថា អ្នកចូលរួមនៅក្នុងការស្រាវជ្រាវនេះ «អាចលើកលែងទោសឲ្យអ្នកដែលជាខ្មែរក្រហមបាន ប៉ុន្តែអ្នកទាំងនេះនៅតែមានអារម្មណ៍ខឹងសម្បានឹងមេដឹកនាំខ្មែរក្រហម ឬអំពើហិង្សា ដែលកើតមានជាទូទៅនៅក្នុងរបបនេះ» ។ បើពិចារណាពីឥរិយាបថរបស់ប្រទេសកម្ពុជាវិញ ការបង្កើតឲ្យមានជាយន្តការដោះស្រាយកំហឹងដ៏សមរម្យមួយពិតជាមានសារសំខាន់ ។ ការផ្សះផ្សា គឺជាការខិតខំប្រឹងប្រែងដែលចេញពីបុគ្គលផ្ទាល់ ប៉ុន្តែប្រហែលជាប្រព័ន្ធដោះស្រាយជម្លោះដោយផ្អែកលើគោលការណ៍របស់ប្រទេសកម្ពុជា អាចផ្ដល់ឱកាសឲ្យប្រជាជនកម្ពុជានិយាយពីរឿងរ៉ាវរបស់ខ្លួនទាំងក្នុងនាមជាជនរងគ្រោះ និងជនដៃដល់ ហើយអាចដោះស្រាយបញ្ហាពិរុទ្ធភាពនេះបាន ។

បើទោះបីជាព័ត៌មានជាច្រើនស្ដីពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមត្រូវបានប្រមូលផ្ដុំអស់រយៈពេលជាច្រើនឆ្នាំដោយអង្គការផ្សេងៗគ្នាក៏ដោយ ក៏ព័ត៌មានស្ដីពីឧក្រិដ្ឋកម្មនេះមិនទាន់ត្រូវបានចងក្រង និងចែកចាយជូនដល់ប្រជាជនកម្ពុជាមួយភាគធំនៅឡើយទេ ។ ឧទាហរណ៍ លិខិតលើកលែងញត្តិរណសិរ្សបានទាញយកសក្ខីកម្មពីមនុស្សរាប់លាននាក់ ប៉ុន្តែព័ត៌មានទាំងនោះមិនត្រូវបានផ្សាយជាសាធារណៈទេ ។ គណៈកម្មការស្វែងរកការពិតអាចវិភាគ និងផ្សព្វផ្សាយព័ត៌មានទាំងនេះដោយធ្វើការទាក់ទាញឲ្យប្រជាជនកម្ពុជាចូលរួមនៅក្នុងដំណើរការនេះបាន ។

មកដល់ពេលនេះ គណៈកម្មការស្វែងរកការពិតអាចពឹងផ្អែកលើបទពិសោធន៍របស់រដ្ឋាភិបាលប្រទេសស៊ុយអែត ។ ដោយព្រួយបារម្ភខ្លាចថា យុវជនស៊ុយអែតមានការយល់ដឹងតិចតួចពីការសម្លាប់រង្គាល ដោយមានការងឿងឆ្ងល់នឹងការកកើតឡើងនៃអំពើនេះ និងបារម្ភពីការកើនឡើងនៃការឃោសនាតាមសាលារៀនរបស់ក្រុមមូលធននិយម រដ្ឋសភាប្រទេសស៊ុយអែតបានបង្កើតគម្រោងប្រវត្តិសាស្ត្ររស់ ។ គម្រោងនេះមានគោលបំណងនិយាយពីរឿងរ៉ាវនៃការសម្លាប់រង្គាល តាមវិធីសាស្ត្រផ្សេងៗ រួមមានការប្រមូលផ្ដុំធនធានព័ត៌មានសម្រាប់សាលារៀន ខ្សែភាពយន្ត សិក្ខាសាលា និងការប្រគុំតន្ត្រីជាដើម ។ គម្រោងនេះចាប់ផ្ដើមឡើងនៅក្នុងការជជែកពិភាក្សាអន្តរជាតិនៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែត ដែលមានការប្រជុំសិក្ខាសាលាអន្តរជាតិចំនួនបួន ដែលធ្វើឡើងក្នុងគោលបំណងបង្កើតវេទិកា «ប្រជុំមួយដើម្បីផ្លាស់ប្ដូរព័ត៌មានចំណេះដឹង គំនិត និងទស្សនៈរវាងអ្នកស្រាវជ្រាវជាន់ខ្ពស់ អ្នកធ្វើសេចក្ដីសម្រេច និង អ្នកជាប់ពាក់ព័ន្ធ» ។ មុនពេលសិក្ខាសាលាលើកទីមួយចាប់ផ្ដើម រដ្ឋាភិបាលស៊ុយអែតបានបោះពុម្ពសៀវភៅមួយក្បាលដែលមានចំណងជើងថា «ប្រាប់កូនរបស់អ្នក» ដែលធ្វើការនិយាយពីការសម្លាប់រង្គាលនៅសហគមន៍




លោកគ្រូ ប៊ុច សៀកឡេង ឡើងផ្ដល់យោបល់អំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

អឺរ៉ុប ។ សៀវភៅថតចម្លងប្រមាណមួយលានពីរសែនក្បាលដែលបកប្រែជាភាសា ហ្វាំងឡង់ អារ៉ាប់ ទួគី ស៊ឺបូក្រូស្មៀន អង់គ្លេស អេស្ប៉ាញ និងពីសង់ ត្រូវបានចែកជូនកូនសិស្សសាលារបស់គ្រួសារជនជាតិស៊ុយអែតគ្រប់ៗគ្នា ។ ក្រោយពេលដែលសិក្ខាសាលានេះបានបញ្ចប់ទៅ រដ្ឋាភិបាលស៊ុយអែតបានបោះពុម្ពសៀវភៅមួយក្បាលទៀតដែលមានចំណងជើងថា បន្ទាប់ពីពាក្យ «មិនកើតឡើងម្តងទៀត» ដែលសៀវភៅនេះធ្វើការគូសបង្ហាញពីការស្រាវជ្រាវរបស់សិក្ខាសាលា រួមជាមួយនឹងបទសម្ភាសន៍ជាមួយអ្នកចូលរួមមួយចំនួនទៀត ។ ពិតណាស់ គម្រោងស្តីពីការលើកកម្ពស់ ការយល់ដឹងស្រដៀងគ្នានៅប្រទេសកម្ពុជា អាចនឹងចាំបាច់ត្រូវតែបំពេញទៅតាមបរិបទវប្បធម៌របស់កម្ពុជា ប៉ុន្តែវិធីសាស្ត្រសម្រេចនូវជោគជ័យច្រើនបែបនេះអាចនឹងផ្តល់នូវគំរូដ៏ល្អសម្រាប់គណៈកម្មការស្វែងរកការពិតរបស់កម្ពុជាបាន ។

## ការស្នើសុំ

ការស្នើសុំបច្ចុប្បន្ននេះដើម្បីបង្កើតគម្រោងមួយដែលនឹងចាប់ផ្តើមដំណើរការ ដោយការប្រមូលយកសក្ខីកម្មពីប្រជាជនកម្ពុជាស្តីពីបទពិសោធន៍របស់គាត់កាលពីរបបខ្មែរក្រហម តាមរយៈវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀននៅតាមសហគមន៍ និងការសហការពីសំណាក់ព្រះសង្ឃ ឬអ្នកកាន់សាសនាអ៊ីស្លាម ។ កិច្ចប្រឹងប្រែងនេះនឹងធ្វើការវិវឌ្ឍក្នុងរយៈពេលពីរឆ្នាំខាងមុខទៅប្រាំឆ្នាំទៀត ដើម្បីបញ្ចូលសក្ខីកម្មសំខាន់ៗជាច្រើន ជាថ្នាក់ជាតិ និងដើម្បីឆ្លើយតបនឹងសំណួរពីការកកើតឡើងនៃរបបខ្មែរក្រហមនិងឥទ្ធិពលរបស់របបនេះមកលើប្រទេសកម្ពុជា ។

គ្រូបង្រៀនអាចនឹងត្រូវចាត់តាំងឲ្យធ្វើបទសម្ភាសន៍ ចងក្រងព័ត៌មាន ហើយដឹកនាំការអប់រំ ។ គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលកំពុងដំណើរការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ព្យាយាមផ្លាស់ប្តូរនិន្នាការ ដែលជៀសវាងមិនបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលារៀនឲ្យបានទូលំទូលាយ ។ បច្ចុប្បន្ននេះសិស្សសាលាគ្រប់វ័យទាំងអស់មិនបានទទួលការអប់រំជាផ្លូវការឲ្យបានទូលំទូលាយស្តីពីរបបនេះទេ ដោយសារតែការផ្តោតទៅលើសារសំខាន់នៃប្រវត្តិសាស្ត្រសម័យទំនើប និងព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជានៅពេលបច្ចុប្បន្ននេះ ។ ក្រោយពីការរៀបរៀងជាសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង សៀវភៅណែនាំគ្រូបង្រៀន មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនទាំងបីកម្រិត ហើយដាក់បញ្ចូលសៀវភៅទាំងនេះជាឯកសារគោលចូលទៅក្នុងកម្មវិធីសិក្សានេះដើម្បីបង្រៀននៅតាមវិទ្យាល័យ និងមហាវិទ្យាល័យទូទាំងប្រទេសកម្ពុជា ។ គ្រូបង្រៀនទាំងអស់នេះជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការពង្រីកសកម្មភាពអប់រំដែលចាប់ផ្តើមចេញពីការបង្រៀនសិស្សតាមសាលារៀន ឈានទៅដល់ការអប់រំតាមសហគមន៍ធំៗ ដើម្បីចងក្រងប្រវត្តិសាស្ត្រនេះ ។ ការពង្រីកសកម្មភាពអប់រំរបស់គ្រូបង្រៀន ទាំងអស់នេះអាចធ្វើទៅបាន ដោយសារតែលោកគ្រូ-អ្នកគ្រូទទួលបានសេចក្តីគោរពរាប់អានពីអ្នកភូមិក្នុងសហគមន៍របស់ខ្លួន និងដោយសារតែចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាល ។

សៀវភៅប្រវត្តិសាស្ត្រនេះគឺជាផ្នែកមួយនៃកម្មវិធីអប់រំដែលផ្តល់ជូនអ្នកដែលកើតក្រោយរបបខ្មែរក្រហម ។ ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡាបានកំពុងដាក់តាំងពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅតាមសាលារៀនក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សិស្សនិង គ្រូបង្រៀនពីអំពើប្រល័យពូជសាសន៍ និងដើម្បីរារាំងអំពើប្រល័យពូជសាសន៍ ។ គណៈកម្មការស្វែងរកការពិតរបស់ប្រទេសកម្ពុជាអាចនឹងបង្កើតជាកិច្ចប្រឹងប្រែងទាំងនេះបាន ។

នៅក្នុងប្រទេសដែលពោរពេញទៅដោយអ្នកកាន់ពុទ្ធសាសនា ព្រះសង្ឃគឺជាប្រភពផ្តល់ ដំបូន្មាន និងបញ្ញាដែលទទួលបានការគោរពដ៏ខ្ពង់ខ្ពស់ ។ បើទោះបីជាបារាំងបានបង្កើតប្រព័ន្ធច្បាប់លោកខាងលិចក៏ដោយ ក៏គំរូដោះស្រាយជម្លោះក្នុងស្រុករបស់ប្រទេសកម្ពុជានៅតែបន្តឋិតថេររហូតមក ។ ដូចគ្នានឹងប្រព័ន្ធដោះស្រាយជម្លោះផ្សេងទៀតទំនាក់ទំនងរវាងភាគីទាំងអស់ពិតជាមានសារសំខាន់ ។ បន្ថែមលើនេះ ជាធម្មតាប្រជាជនកម្ពុជា «បានចាត់ទុកជម្លោះមួយជាកត្តាដែលធ្វើឲ្យប៉ះពាល់ដល់ចំណងមិត្តភាពយូរអង្វែងរបស់ខ្លួន» ។ ជាមួយគ្នានេះ សមាសធាតុផ្នែក

សាសនាបានដើរតួជាផ្នែកដ៏សំខាន់មួយ នៅក្នុងគំរូដោះស្រាយជម្លោះ ។ ព្រះសង្ឃនៅតែបន្តទទួលបានការគោរពនិងកោតសរសើរ ហើយអាចនឹងត្រូវបានចាត់ទុកជាភាគីទីបី ដែលចូលរួមនៅក្នុងទម្រង់ដោះស្រាយជម្លោះតាមបែបប្រពៃណី ។ ដូច្នេះ ព្រះសង្ឃគឺជាបុគ្គលដែលស័ក្តិសមធ្វើជាអ្នកបង្កើតវិធីសាស្ត្រដោះស្រាយជម្លោះបន្ថែមលើវិធីសាស្ត្រដែលមាននៅតាមភូមិ ហើយធ្វើការពិភាក្សាពីការដាក់ទោសដែលមានលក្ខណៈស្របទៅតាមព្រះពុទ្ធសាសនាហីនយាន ។ ជាមួយគ្នានេះ មេដឹកនាំរបស់ជនជាតិភាគតិចចាមគួរតែចូលរួមនៅក្នុងការរៀបចំគណៈកម្មការស្វែងរកការពិតរបស់កម្ពុជានេះដែរ ។

គម្រោងនេះនឹងចាប់ផ្តើមដំណើរការឡើងជាក្រុមការងារគ្រូបង្រៀនដែលទទួលបានវគ្គបណ្តុះបណ្តាលពីមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំយុវជននិងកីឡាតាមរយៈគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គ្រូបង្រៀនទាំងអស់នេះនឹងត្រូវបានជ្រើសរើសពីវិទ្យាល័យ ថ្នាក់ឃុំ ស្រុក និងជាតិ ដើម្បីធ្វើឲ្យការធ្វើជាតំណាងមានលក្ខណៈធំទូលាយ ហើយចុះធ្វើការងារគ្រប់តំបន់ទូទាំងប្រទេសកម្ពុជា ។ នៅក្នុងចំណោមគ្រូបង្រៀនចំនួន៣៥០០នាក់ នឹងមានការជ្រើស២០០នាក់ដែលនឹងចូលរួមនៅក្នុងគម្រោងនេះនឹងមានការជ្រើសតាំងគណៈកម្មាធិការប្រតិបត្តិតូចមួយ ដើម្បីជួយរៀបចំ និងដឹកនាំក្រុមគ្រូបង្រៀនទាំងអស់ ។ គណៈកម្មាធិការប្រតិបត្តិនេះមានសមាជិកចាប់ពីប្រាំទៅប្រាំពីរនាក់ ដែលត្រូវបានជ្រើសតាំងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើចំណាប់អារម្មណ៍ និងសកម្មភាពរបស់គ្រូបង្រៀនទាំងនោះនៅក្នុងកំឡុងវគ្គបណ្តុះបណ្តាលការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីធានាថាគ្រូបង្រៀនទាំងអស់នេះមានឆន្ទៈមោះមុតក្នុងការបង្រៀន និងបង្រៀនប្រវត្តិសាស្ត្រកម្ពុជា ។ សម្រាប់ក្រុមការងារគ្រូបង្រៀនក្រុមធំវិញនឹងត្រូវទទួលបានការផ្តោតយកចិត្តទុកដាក់ខ្លាំងដើម្បីធានា ថាក្រុមការងារ នេះដើរតួជាអ្នកតំណាងឲ្យតំបន់ ភូមិសាស្ត្រ យេនឌ័រ ជាតិពន្ធុ សាសនា បទពិសោធន៍បង្រៀន និងប្រជាសាស្ត្រផ្សេងៗ ។ គណៈកម្មាធិការប្រតិបត្តិនៃក្រុមការងារនេះនឹងធ្វើការដោយស្ម័គ្រចិត្ត ហើយកិច្ចការរបស់គណៈកម្មាធិការនេះគឺរក្សាទំនាក់ទំនងជាចំហរជាមួយគ្រូបង្រៀនទាំងអស់ដោយរៀបចំជាគម្រោងកំណត់ពេលវេលាសម្រាប់ការបង្កើតព័ត៌មាន និងរៀប


គ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ខេត្ត ពិភាក្សាពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ចំការប្រជុំប្រចាំឆ្នាំ ។

ដំណើរការចាប់ផ្ដើមរបស់គម្រោងនេះ និងការប្រជុំ ប្រចាំឆ្នាំជាលើកដំបូងនឹងនាំយកមេដឹកនាំសាសនាមកពីគ្រប់តំបន់ និងគ្រូបង្រៀនចំនួន២០០នាក់ទៀតមកចូលរួមពិភាក្សា និងទទួល យកវគ្គបណ្ដុះបណ្ដាលសម្រាប់ជំនាញផ្សេងៗបន្ថែមទៀតនៅក្នុង កំឡុងពេលបំពេញការងារ ។ ជាឧទាហរណ៍ គ្រូបង្រៀននឹងទទួល បានវគ្គបណ្ដុះបណ្ដាលពីអ្នកជំនាញទាក់ទងនឹងបញ្ហាផ្លូវចិត្ត និង សង្គម វិធីសាស្រ្តធ្វើបទសម្ភាសន៍ និងវិធីសាស្រ្តជួយសម្រួល ដល់ការពិភាក្សាជាក្រុម ។ ក្នុងរយៈពេលពេញមួយឆ្នាំ គ្រូបង្រៀន ទាំងអស់នឹងធ្វើការជាមួយនឹងប្រជាជនក្នុងសហគមន៍របស់ខ្លួន ដើម្បីកត់ត្រា និងចងក្រងសក្ខីកម្មរបស់ប្រជាជនស្ដីពីការកកើត ច្បាប់ ការដួលរលំរបស់របបខ្មែរក្រហម និងលទ្ធផលបន្ទាប់ពីរបប នេះរលត់ផុតទៅ ហើយស្របពេលជាមួយគ្នានោះដែរ ព្រះសង្ឃ នឹងបង្កើតវិធីសាស្រ្តសម្រាប់ការផ្សះផ្សា ។

គោលដៅដ៏មានឥទ្ធិពលនេះនឹងត្រូវធ្វើឡើងដើម្បីបង្កើត ជារឿងរ៉ាវមួយស្ដីពីរយៈពេលដ៏សំខាន់នៃប្រវត្តិសាស្រ្តកម្ពុជា ។ ការស្វែងរករឿងរ៉ាវនេះនឹងក្លាយជាជំហានដំបូងក្នុងការបង្កើត បរិយាកាសដែលឆ្ពោះទៅរកការផ្សះផ្សាសង្គម ។ ដំណើរការនេះ អាចចាប់ផ្ដើមដោយធ្វើយ៉ាងណាឲ្យប្រជាជននៅតាមសហគមន៍ ចូលរួមរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួន ដែលផ្ដោតទៅលើកត្តាការ កកើតឡើងឥទ្ធិពលអាក្រក់របស់របបខ្មែរក្រហមដែលមាននាពេលបច្ចុប្បន្ន និងការប្រាស្រ័យទាក់ទងរវាងជនដៃដល់ និងជនរងគ្រោះ ។ ដំណើរការនេះគួរតែធ្វើការយកចិត្តទុកដាក់លើរឿងរ៉ាវ នៅតាមថ្នាក់ភូមិ និងទម្រង់ដើមនៃយុត្តិធម៌តាមរយៈការផ្សះផ្សា តាមផ្លូវច្បាប់ និងការអប់រំដែលជួយលើកកម្ពស់សាមគ្គីភាព ។

សក្ខីកម្មរបស់អតីត «ខ្មែរក្រហម» ពិតជាមានសារសំខាន់ ពីព្រោះបុគ្គលទាំងអស់នេះមានការយល់ដឹងច្រើនពីទស្សនវិជ្ជា របស់ខ្មែរក្រហម រចនាសម្ព័ន្ធ និងតួនាទីរបស់របបនេះ និងខ្សែសង្វាក់នៃការបញ្ជា ។ រឿងរ៉ាវដែលទទួលបានពីកម្មាភិបាលថ្នាក់ទាបនិងជនរងគ្រោះស្ដីពីការចូលរួមរបស់ប្រជាជននឹងជួយបង្កើត ជាការយល់ដឹងមួយស្ដីពីកត្តាដែលនាំឲ្យមានឧក្រិដ្ឋកម្មកើតឡើង ។ ជាមួយគ្នានេះ អតីតជនដៃដល់ក៏អាចសហការជាមួយនឹងគ្រូបង្រៀន និងព្រះសង្ឃនៅក្នុងសហគមន៍របស់ខ្លួន ដើម្បីចែករំលែក រឿងរ៉ាវនិងបទពិសោធន៍របស់ខ្លួនជាមួយនឹងគម្រោងគណៈកម្មការ ស្វែងរកការពិត ដើម្បីជំរុញឲ្យមានការចូលរួមកាន់តែច្រើនពី សំណាក់អតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀត ។ ការទាក់ទាញ ឲ្យអតីតជនដៃដល់ធ្វើសហការនៅក្នុងគម្រោងនេះអាចនឹងប្រឈម មុខជាមួយបញ្ហាដ៏ធំមួយទាក់ទងនឹងដំណើរការចូលរួមពិភាក្សានេះ ពីព្រោះថាការបែងចែកដាច់ដោយឡែកថា នរណាជាជនរងគ្រោះ និងជនដៃដល់នៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ។

ជារៀងរាល់ឆ្នាំ ការប្រជុំប្រចាំឆ្នាំនឹងប្រារព្ធឡើងដោយ មានការចូលរួមពីគ្រូបង្រៀនទាំងអស់ ដើម្បីបូកសរុបព័ត៌មាន ដែលប្រមូលបានពេញមួយឆ្នាំ ។ សម្រាប់អ្នកចូលរួមដែលចង់ ចែករំលែកបទពិសោធន៍របស់ខ្លួននោះ ទិន្នន័យដែលទទួលបានពី បទពិសោធន៍ទាំងអស់នេះអាចត្រូវបានរៀបចំបោះពុម្ពជាសាច់ រឿងមួយដែលនឹងត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការ ប្រតិបត្តិគ្រូបង្រៀន អ្នកជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានិង អ្នកដឹកនាំផ្នែកប្រវត្តិសាស្រ្តកម្ពុជាផ្សេងទៀត ដើម្បីបង្កើតជាសាច់ រឿងរួមធំមួយដែលទទួលបានព័ត៌មានពីប្រជាជនទូទាំងប្រទេសស្ដី ពីព្រឹត្តិការណ៍ទាំងអស់ដែលកើតមានកាលពីអតីតកាល ។ ដើម្បីធ្វើ ឲ្យគណៈកម្មការស្វែងរកការពិតដំណើរការទៅបាន ក្រុមអាជ្ញាធរ ឯករាជ្យមួយត្រូវតែទទួលបានអំណាចក្នុងការប្រើប្រាស់ទិន្នន័យ សម្រាប់ការស្រាវជ្រាវដែលឆ្លើយតបនឹងសំណួរដែលទាក់ទងនឹង កត្តាជំរុញឲ្យមានការកកើតឡើងនៃរបបនេះ និងបទពិសោធន៍ ដែលកើតឡើងជាទូទៅ ។ ការបោះពុម្ពដែលជាលទ្ធផលនៃដំណើរការនេះនឹងត្រូវយកមកប្រើប្រាស់ដើម្បីជួយផ្សែផ្សំបន្ថែមដល់ ការបង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យនៅតាមវិទ្យាល័យនិងមហាវិទ្យាល័យ តាមរយៈគម្រោងរបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា ហើយការបោះពុម្ពទាំងនេះនឹងត្រូវចែកជូនដល់ សាធារណជនទូទៅដើម្បីបង្កើនការយល់ដឹងពីប្រវត្តិសាស្រ្តនេះ ។ ក្រោយមកទៀត ព្រឹត្តិការណ៍ទាញយកព័ត៌មានបែបនេះអាចនឹង ធ្វើឡើងនៅតាមថ្នាក់ស្រុក និងថ្នាក់ជាតិដើម្បីប្រមូលផ្ដុំទិន្នន័យ និង ផ្សព្វផ្សាយការស្រាវជ្រាវឲ្យកាន់តែទូលំទូលាយ ។

បន្ថែមលើការចងក្រងសក្ខីកម្មតាមរយៈបទសម្ភាសន៍

និងការសរសេររឿងរ៉ាវរបស់ជនរងគ្រោះទាំងអស់នៅក្នុងរបបខ្មែរក្រហម និងអ្នកដែលកើតក្រោយរបបនេះ គ្រូបង្រៀននៅតាមភូមិ និងទីរួមស្រុកទាំងអស់អាចនឹងទទួលការណែនាំឲ្យរៀបចំជាវេទិកាពិភាក្សាក្នុងសហគមន៍ ។ ប្រជាជននៅក្នុងសហគមន៍ទាំងអស់នឹងមិនត្រូវបានបង្ខិតបង្ខំឲ្យចូលរួមនៅក្នុងវេទិកាពិភាក្សានេះទេ ។ ព្រឹត្តិការណ៍ពិភាក្សានេះនឹងផ្តល់ជាឱកាសចែករំលែក និងសន្ទនាពីបញ្ហាកាលពីសម័យខ្មែរក្រហមដែលនឹងជួយសម្រួលដោយគ្រូបង្រៀនម្នាក់ ។ មេដឹកនាំខាងសាសនាក្នុងសហគមន៍ក៏គួរតែចូលរួមនៅក្នុងវេទិកាពិភាក្សានេះដែរដោយសារតែមេដឹកនាំទាំងនេះអាចទាញយកភាពជឿជាក់ពីអ្នកភូមិ និងបទពិសោធន៍របស់មេដឹកនាំទាំងនេះក្នុងការដោះស្រាយបញ្ហាសីលធម៌ និងបញ្ហាផ្លូវចិត្ត ។ បន្ថែមលើការរៀបរាប់រឿងរ៉ាវជាសាធារណៈ ទម្រង់នៃការបង្ហាញឲ្យឃើញពីអារម្មណ៍របស់បុគ្គលតាមទំនៀមទម្លាប់ប្រពៃណី ដូចជាតាមរយៈតន្ត្រី ឬកំណាព្យអាចនឹងត្រូវបានប្រើប្រាស់ចេញពីការផ្តួចផ្តើមឡើងពីសំណាក់អ្នកភូមិ ។ វេទិកាពិភាក្សាទាំងអស់នេះនឹងធ្វើឲ្យគម្រោងនេះមានលក្ខណៈខុសប្លែកពីការបង្កើតសក្តីកម្មខាងលើ ។

វេទិកាពិភាក្សាអាចនឹងប្រើប្រាស់ទម្រង់បែបបទស្រដៀងគ្នាដែលត្រូវបានប្រើប្រាស់នៅក្នុងព្រឹត្តិការណ៍ ដូចជាថ្ងៃចងកំហឹងជាដើម ។ ចាប់តាំងពីទសវត្សរ៍៩០មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកកម្ពស់ការចងចាំពីរបបខ្មែរក្រហមដោយជំរុញឲ្យមន្ទីរពេទ្យ សាលារៀន និងរោងចក្រនានាធ្វើបដា ឬផ្ទាំងរូបភាពស្តីអំពីការប្រឆាំងនឹងរបបខ្មែរក្រហម ដើម្បីយកមកប្រើប្រាស់នៅក្នុងកិច្ចពិភាក្សាជាសាធារណៈនិងព្រឹត្តិការណ៍រំឭកផ្សេងៗ ។ ការជួបជុំពិភាក្សានៅក្នុងទិវាចងកំហឹងដែលតែងតែប្រារព្ធធ្វើនៅតាមទីកន្លែងវប្បធម៌សំខាន់ៗ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឲ្យចូលរួម និងចែករំលែករឿងរ៉ាវរបស់ខ្លួន ។ សកម្មភាពរបស់បុគ្គលទាំងអស់នេះមានតុល្យភាពជាមួយ «ការសរសេររៀបរៀងជាផ្លូវការមួយដែលសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការធ្វើឲ្យអារម្មណ៍ផ្លូវចិត្តស្ងប់ និងការផ្តោតយកចិត្តទុកដាក់ទៅលើការប្រឆាំងនឹងការបំភ្លេចដែលកត្តាទាំងនេះពិតជាមានសារសំខាន់ក្នុងការកសាងជាតិឡើងវិញ» ។ ដូចគ្នាដែរ វេទិកាពិភាក្សានៅតាមសហគមន៍ត្រូវតែធ្វើការពង្រឹងគោលដៅពីរខាងលើនេះ ហើយធ្វើយ៉ាងណាផ្តល់នូវទីកន្លែងមួយដែលអ្នកចូលរួមមានអារម្មណ៍ងាយស្រួលក្នុងការបង្ហាញពីកំហឹង និងការឈឺចាប់របស់ខ្លួន ។

ស្របពេលដែលគ្រូបង្រៀននឹងក្លាយជាអ្នកដើរតួ និងអ្នករៀបចំដ៏សំខាន់នៅក្នុងការអនុវត្តស្វែងរកការពិតនេះ ទាំងរាជរដ្ឋាភិបាលកម្ពុជានិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់នូវធនធាន និងបទពិសោធន៍សំខាន់ជាច្រើនដល់ដំណើរការនេះ ។ រាជរដ្ឋាភិបាលអាចនឹងផ្តល់អំណាច និងភាពត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដូចជាធ្វើឲ្យមានការយកចិត្តទុកដាក់ពីសារព័ត៌មានទៅលើដំណើរការនេះ ។ បន្ថែមលើនេះ មន្ត្រីរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងការរៀបចំព្រឹត្តិការណ៍ផ្សេងៗដូចជា ពិធីរំឭកទិវាចងកំហឹងនៅថ្ងៃទី២០ ខែឧសភា និងថ្ងៃទី៧ ខែមករា ក៏អាចចែករំលែកនូវទេពកោសល្យនិងចំណេះដឹងផ្សេងៗរបស់ខ្លួនបានដែរ ។ រាជរដ្ឋាភិបាលក៏អាចផ្តល់ជាធនធានមិនមែនជាថវិកាដូចជា ទីកន្លែងប្រជុំ ការផ្សព្វផ្សាយព័ត៌មានជាផ្លូវការ និងការគាំទ្រជាសាធារណៈជាដើម ។ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងផ្តល់នូវបទពិសោធន៍ស្តីពីការចងក្រងរឿងរ៉ាវរបស់ប្រជាជនក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ ហើយអាចនឹងផ្តល់ជាសេចក្តីណែនាំបច្ចេកទេសសម្រាប់ការបោះពុម្ព ។ ទាំងរាជរដ្ឋាភិបាលកម្ពុជា និងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងដើរតួនាទីយ៉ាងចម្បងនៅក្នុងការដំណើរការគណៈកម្មការនេះ ប៉ុន្តែខណៈពេលដែលគណៈកម្មការនេះកំពុងបន្តដំណើរការគណៈកម្មាធិការប្រឹក្សាដែលដំណើររយៈពេលយូរ គឺអាចនឹងត្រូវបានជ្រើសតាំងឡើងដែលមានអ្នកតំណាងពីរាជរដ្ឋាភិបាលកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា និងអតីតសមាជិកគណៈកម្មការដែលមកពីគណៈកម្មការស្វែងរកការពិតផ្សេងទៀត ។

ស្របពេលដែលគម្រោងនេះដំណើរការដល់ដំណាក់កាលបោះពុម្ពជាសៀវភៅ ហើយព្រឹត្តិការណ៍របស់គម្រោងនេះត្រូវបានរៀបចំឡើងលើសពីថ្នាក់សហគមន៍នីមួយៗនោះ សិស្សវិទ្យាល័យ និងនិស្សិតមហាវិទ្យាល័យក៏ដើរតួរនៅក្នុងដំណើរការនេះដែរ ។ ដោយដើរតួនាទីជាអ្នកពង្រីកការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន សិស្សនិស្សិតទាំងអស់នេះអាចធ្វើការស្ម័គ្រចិត្តជួយប្រមូល រៀបចំ និងបោះពុម្ពឯក

សារបន្ទាប់បន្សំផ្សេងៗ ។ ការធ្វើដូច្នេះមិនមែនត្រឹមតែធ្វើឲ្យមានការចូលរួមពីសំណាក់យុវជនជំនាន់ក្រោយ និងជួយសម្រេចគោលដៅរារាំងអំពើសាហាវឃោរឃៅតែប៉ុណ្ណោះទេ ថែមទាំងជួយធ្វើឲ្យមានការចំណាយថវិកាតិចទៅលើការចងក្រងឯកសារថ្មីៗទៀតផង ។ សិស្សមហាវិទ្យាល័យអាចជួយក្រុមការងារគ្រូបង្រៀននៅក្នុងការចងក្រង សក្ដិកម្មរបស់អ្នកមានឋានៈខ្ពស់ និងចូលរួមនៅក្នុងព្រឹត្តិការណ៍ ឬពិធីផ្សេងៗដើម្បីផ្សព្វផ្សាយអរសាទរចំពោះដំណើរការឆ្ពោះទៅមុខរបស់គម្រោងគណៈកម្មការស្វែងរកការពិតនេះ ។

## ការវិភាគលើរចនាសម្ព័ន្ធ និងសេចក្ដីណែនាំដល់គម្រោងនេះ

គំរូដែលបានស្នើឡើងខាងលើនេះមានផលវិជ្ជមានច្រើនក្នុងការស្វែងយល់ពីអតីតកាលរបស់កម្ពុជា ។ ទីមួយ ដំណើរការខាងលើនេះមានលក្ខណៈក្រៅផ្លូវការ ហើយមានផលប៉ះពាល់តិចតួចណាស់លើជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងនយោបាយជាតិ ។ ការចូលរួមរបស់មនុស្សគ្រប់លំដាប់ថ្នាក់គឺផ្ដើមចេញពីការស្ម័គ្រចិត្ត ។ លើសពីនេះទៅទៀត គណៈកម្មការស្វែងរកការពិតនេះគឺជួយបំពេញកិច្ចការបន្ថែមរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងដោយសារតែរចនាសម្ព័ន្ធ ដែលប្រើប្រាស់ថវិកាតិចតួចរបស់ខ្លួន គណៈកម្មការស្វែងរកការពិតនេះអាចបន្តកិច្ចការរបស់ខ្លួនបានរយៈពេលយ៉ាងយូរបំផុត ។ ខុសពីតុលាការដែលយល់ថាការស្វែងរកទោសកំហុស និងភាពស្អាតស្អំរបស់ជនជាប់ចោទគឺជាគោលដៅចម្បងនោះ គណៈកម្មការស្វែងរកការពិតនេះបានធ្វើឲ្យមនុស្សជាច្រើននាក់អាចចូលរួម និងធ្វើឲ្យបទពិសោធន៍របស់អ្នកទាំងនេះត្រូវបានទទួលស្គាល់ជាផ្លូវការ ។ ដូចការរៀបរាប់ខាងលើ គោលការណ៍របស់ពុទ្ធសាសនិកធ្វើការគាំទ្រទស្សនៈដែលថា គម្រោងគណៈកម្មការស្វែងរកការពិតនឹងជួយបំពេញកិច្ចការបន្ថែមរបស់តុលាការ ។ គណៈកម្មការស្វែងរកការពិត មានលក្ខណៈដូចនឹងយុត្តិធម៌តាមរយៈការផ្សះផ្សាតាមផ្លូវច្បាប់ដែរ ប៉ុន្តែមិនដូចគ្នានឹងវិធានការផ្ដន្ទាទោសដែលសម្រេចបានតាមរយៈការកាត់ទោសនោះទេ ។ នៅក្នុងពុទ្ធសាសនាហីនយាន ការទទួលស្គាល់ពីកំហុស និងការកំណត់គោលដៅល្អសម្រាប់អនាគតគឺជាសមាសធាតុដ៏សំខាន់នៅក្នុងការចៀសវាងការប្រព្រឹត្តអំពើហិង្សា ។ ដូច្នេះ វេទិកាពិភាក្សា និងការធ្វើសក្ខីភាពគឺជាមាគ៌ាមួយដែលធ្វើឲ្យមានការទទួលស្គាល់ និងបង្កើតជាមូលដ្ឋានសម្រាប់ការផ្សះផ្សា ។

អត្ថប្រយោជន៍ដ៏សំខាន់បំផុតមួយនៃគំរូរបស់គណៈកម្មការស្វែងរកការពិតនេះគឺថា វាចាប់ផ្ដើមដំណើរការឡើងនៅតាមសហគមន៍ ។ លក្ខណៈប្រែប្រួលក្នុងតំបន់អាចត្រូវបានក្ដោបក្ដាប់បានតាមរយៈដំណើរការចេញពីថ្នាក់មូលដ្ឋានបែបនេះ ហើយការចូលរួមដ៏ពិតប្រាកដនឹងអាចកើតមានឡើងរវាងប្រជាជនជនកម្ពុជាពីថ្នាក់ទាបមិនមែនត្រឹមតែថ្នាក់ជាតិប៉ុណ្ណោះទេ ។ ការធ្វើដំណើរទៅសួរសុខទុក្ខនិងការអប់រំនៅតាមភូមិនឹងត្រូវធ្វើឡើងក្នុងបរិយាបថប្រកបដោយការយល់ដឹងពីការប្រាស្រ័យទាក់ទងនៅក្នុងភូមិដែលទាក់ទាញអ្នកភូមិឲ្យចូលរួមនៅក្នុងការពិភាក្សាជាសាធារណៈ និងការសួរសុខទុក្ខតាមផ្ទះរបស់ខ្លួនទៅវិញទៅមក ។

ខណៈពេលដែលព្រឹត្តិការណ៍ទាំងនេះត្រូវបានរៀបចំឡើងនៅតាមថ្នាក់ខ្ពស់ ហើយទិន្នន័យត្រូវបានវិភាគដើម្បីស្រាវជ្រាវពីសាច់រឿងពីអតីតកាលមួយនោះ មេរៀនដកស្រង់ចេញពីអតីតកាល និងអនាគតទាំងអស់នេះនឹងក្លាយជាផ្នែកមួយនៃការយល់ដឹងរបស់ប្រទេសជាតិ ។ មនុស្សគ្រប់ជំនាន់ទាំងអស់អាចចូលរួមនៅក្នុង


អ្នកគ្រូ មុំ ម៉េត ឡើងផ្ដល់យោបល់អំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ដំណើរការនេះ តាមរយៈការផ្តល់ជាការរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួន ឬចូលរួមនៅក្នុងវេទិកាពិភាក្សា ។ តាមរយៈការពង្រីកពេលវេលាដែលធ្វើឲ្យមានការចែករំលែកបទពិសោធន៍ ពាក្យថា «ជនរងគ្រោះ» និង «ជនដៃដល់» អាចនឹងត្រូវបានយល់ក្នុងន័យផ្សេង ។ យោងតាមអត្ថបទរបស់លោក នូវង់ហ្គូ ពាក្យទាំងពីរខាងលើនេះអាចក្លាយជាលក្ខខណ្ឌបណ្តោះអាសន្នដែលបុគ្គលម្នាក់អាចក្លាយជាសមាជិកណាមួយនៃក្រុមទាំងពីរនេះ ។ ជនរងគ្រោះនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យប្រហែលជាបានសម្លាប់មនុស្សដើម្បីសងសឹក ប៉ុន្តែតាមរយៈការបង្កើតឲ្យមានឱកាសសម្រាប់ចែករំលែកបទពិសោធន៍ខុសប្លែកគ្នាទាំងនេះក៏ត្រូវបានលាតត្រដាង ។

នៅក្នុងបរិបទជាច្រើនបែប ការស្វែងរកការពិត និងការបង្កើតជារឿងប្រវត្តិសាស្ត្រមួយនឹងប្រឈមមុខនឹងបញ្ហាមួយចំនួនជាមិនខាន ។ ឧបសគ្គធំមួយនៅក្នុងដំណើរការនេះគឺទាក់ទងនឹងការធានាឲ្យបាននូវការចូលរួម និងការផ្តល់រឿងរ៉ាវផ្ទាល់ខ្លួនពីសំណាក់អតីតជនដៃដល់ ។ មធ្យោបាយសម្រាប់ដោះស្រាយបញ្ហានេះគឺថាយើងត្រូវធានាជនដៃដល់ថា ប្រសិនបើអ្នកទាំងនោះចែករំលែករឿងរ៉ាវរបស់ខ្លួន នោះជនដៃដល់នឹងមិនត្រូវបានកាត់ទោសសម្រាប់ការប្រព្រឹត្តកន្លងមកឡើយ ។ វេទិកាពិភាក្សាត្រូវតែរៀបចំឡើងដោយជំរុញឲ្យមានបរិយាកាសល្អដើម្បីឲ្យអ្នកចូលរួមទាំងអស់ធ្វើការចែករំលែក និងរៀនសូត្រពីគ្នាទៅវិញទៅមកជាជាងធ្វើការពង្រីងឲ្យមានការបែងចែកប្រភេទអ្នកចូលរួម ។ គំរូនេះអាចមានលក្ខណៈស្រដៀងយុត្តិធម៌តាមរយៈការផ្សះផ្សាតាមផ្លូវច្បាប់ ហើយអាចជួយជំរុញឲ្យមានអនាគតដែលពោរពេញទៅដោយសន្តិភាព និងស្ថាបនាទំនាក់ទំនងរបស់សង្គមសាជាថ្មី ។ សំខាន់ជាងនេះ ការស្រាវជ្រាវបន្ថែមគួរតែត្រូវផ្តួចផ្តើមឡើងដោយកំណត់ថាតើប្រជាជនកម្ពុជាគិតថាការចូលរួមពីជនដៃដល់គួរតែត្រូវបានដោះស្រាយយ៉ាងដូចម្តេច ។ ចំណែកការចូលរួមពីសំណាក់មេដឹកនាំសាសនានឹងក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការធានាឲ្យមានការចូលរួមពីសំណាក់ជនដៃដល់ ។

បញ្ហាមួយទៀតគឺទាក់ទងនឹងការបង្កើតជាក្រុមចងក្រង និងវិភាគព័ត៌មាន ។ ក្រៅពីការចងក្រងជារឿងរ៉ាវផ្សេងៗ គម្រោងនេះត្រូវតែឆ្លើយនឹងសំណួរថា «ហេតុអ្វី» បានជាការសម្លាប់ដែលកើតមានឡើងត្រូវចាត់ទុកថាមានសារសំខាន់សម្រាប់ប្រជាជនកម្ពុជាទូទៅ ។ ស្របពេលដែលចម្លើយសម្រាប់សំណួរនេះនឹងទទួលបានពីសក្ខីកម្មរបស់ជនដៃដល់ និងជនរងគ្រោះនោះ អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលមានការយល់ដឹងជ្រាលជ្រៅមានឯករាជ្យ និងអព្យាក្រឹតក៏ត្រូវតែអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រឹងប្រែងវិភាគនិងចងក្រងទិន្នន័យដើម្បីរកឲ្យឃើញនូវការពិតរបស់ប្រវត្តិសាស្ត្រនេះដែរ ។

បញ្ហាមួយទៀតដែលអាចក្លាយជាកត្តាជោគជ័យសម្រាប់ការដោះស្រាយបញ្ហាសំខាន់ផ្សេងៗទៀតគឺថា ប្រជាជនកម្ពុជាអាចគិតថាបញ្ហាជម្លោះដីធ្លី ការទទួលបានការអប់រំ និងបញ្ហាសុខភាពជាបញ្ហាសំខាន់នៅក្នុងជីវិតរបស់ខ្លួន ហើយអាចនឹងមិនចង់ចូលរួមនៅក្នុងដំណើរការរបស់គណៈកម្មការស្វែងរកការពិតនេះ ។ សម្រាប់ប្រជាជនកម្ពុជាមួយចំនួនដូចជាប្រជាជនដែលរស់នៅតាមព្រំដែនថៃជាដើម ការបញ្ចប់ទៅនៃរបបខ្មែរក្រហមបានរកយុត្តិធម៌តិចតួចណាស់ឲ្យប្រជាជនទាំងអស់នោះ ។ ការអាក់អន់ចិត្តនិងការខឹងសម្បាទាំងអស់នេះអាចយកមកប្រើប្រាស់ជាកត្តាជោគជ័យមួយដើម្បីធ្វើឲ្យប្រជាជនទាំងអស់រួបរួមគ្នា ហើយបណ្តុះបណ្តាលឲ្យចេះទាមទាររកយុត្តិធម៌បន្ថែមទៀត ។ បើទោះបីជាមិនមានចម្លើយដ៏ងាយស្រួលថាតើគណៈកម្មការស្វែងរកការពិតអាចនឹងដោះស្រាយនឹងតម្រូវការទាំងអស់នេះក៏ដោយ ក៏ការបង្កើតជាយន្តការដែលមានលក្ខណៈច្នៃប្រឌិតថ្មីនេះអាចនឹងធ្វើឲ្យមានភាពងាយស្រួលក្នុងការដោះស្រាយបញ្ហាសំខាន់ៗទាំងអស់នេះបាន ។

ការព្រួយបារម្ភដំបូងបង្អស់ដែលត្រូវចងចាំក្នុងអំឡុងដំណើរការរៀបចំនិងអនុវត្ត គឺទាក់ទងនឹងការគ្រប់គ្រងលើការរំពឹងចង់បានរបស់បុគ្គលផ្សេងៗ ។ ប្រជាជនទាំងអស់ត្រូវយល់ពីគោលដៅរបស់គម្រោងគណៈកម្មការនេះដោយគ្មានការរំពឹងទុកថានឹងទទួលបានសំណងខូចខាត ដំណើរការកាត់ទោសលើជនសង្ស័យបន្ថែមទៀត ឬយុត្តិធម៌ដល់បុគ្គលនីមួយៗទេ ។ ការរៀបចំសកម្មភាពនៅតាមសហគមន៍នីមួយៗស្តីការរំពឹងទុកខាងលើគឺពិតជាមានសារសំខាន់សម្រាប់ជោគជ័យនៃកិច្ចប្រឹងប្រែងនេះ ។ មុននឹងគម្រោងនេះចាប់ផ្តើមដំណើរការនៅតាមសហគមន៍ អ្នកដែល

ចូលរួមនៅក្នុងការអនុវត្តក្នុងតំបន់ត្រូវតែធ្វើការពន្យល់ពីព្រំដែនកំណត់នៃការអាចធ្វើបានរបស់គម្រោងនិងការជាប់ពាក់ព័ន្ធនឹងការចូលរួមនេះ ។ នៅក្នុងអំឡុងពេលប្រមូលសក្ខីកម្ម ឬរៀបចំព្រឹត្តិការណ៍ពិភាក្សា ការក្រើនរំឭកជាបន្តបន្ទាប់ត្រូវតែធ្វើឡើងក្នុងទម្រង់ជាឯកសារ ការប្រកាសជាសំឡេង និងការធ្វើបទសម្ភាសន៍ ឬការទាក់ទងដោយផ្ទាល់នឹងប្រជាជន ដើម្បីឲ្យអ្នកទាំងអស់នេះយល់ថាយន្តការនេះគឺជាឱកាសតែមួយគត់ដែលប្រជាជនទាំងអស់អាចចែករំលែក និងនិយាយពីបទពិសោធន៍របស់ខ្លួន និងដើម្បីឲ្យសេចក្តីរំពឹងចង់បានរបស់អ្នកទាំងអស់នេះទទួលបានការតំណាងពីដំណើរការនេះវិញ ។

ដោយសារតែការនិយាយ ឬសរសេរពីបទពិសោធន៍ដ៏លំបាកបែបនេះអាចនឹងបង្កជាបញ្ហាផ្លូវចិត្តដល់អ្នកចូលរួម ធនធានផ្សេងៗសម្រាប់ការជួយផ្គត់ផ្គង់បញ្ហានេះចាំបាច់ត្រូវតែមានដូចជាព័ត៌មានទំនាក់ទំនងអ្នកជំនាញខាងចិត្តសាស្ត្រជាដើម ។ វាគួរតែមានការសហការជាដៃគូរពីសំណាក់អង្គការសុខភាពផ្លូវចិត្តដើម្បីធានាឲ្យមានវត្តមានចូលរួមពីអ្នកជំនាញខាងផ្លូវចិត្តនៅតាមសហគមន៍ក្នុងអំឡុង និងក្រោយពេលប្រមូលយកសក្ខីកម្ម ជាពិសេសនៅពេលដែលព្រឹត្តិការណ៍ពិភាក្សាជាសាធារណៈនេះត្រូវបានរៀបចំឡើង ។ មេដឹកនាំសាសនាក៏អាចផ្តល់ដំបូន្មានផ្នែកសាសនា និងការគាំទ្រដោយផ្អែកលើការជឿជាក់បានដែរ ។

ខណៈពេលដែលគ្រូបង្រៀនទាំងអស់ត្រូវបានបណ្តុះបណ្តាលដើម្បីបំពេញកិច្ចការទាំងអស់នេះនៅក្នុងដំណើរបេសកកម្មរបស់ខ្លួន នោះគម្រោងនេះនឹងចំណាយថវិកាសមល្មមតែប៉ុណ្ណោះ ។ ប៉ុន្តែ វគ្គបណ្តុះបណ្តាលនឹងទាមទារធនធានច្រើន ។ បន្ថែមលើនេះ តាមរយៈការប្រើប្រាស់គ្រូបង្រៀនក្នុងស្រុកនោះ ការទាក់ទាញឲ្យមានការចូលរួមពីសំណាក់ប្រជាជនខ្មែរក្រៅប្រទេសនឹងមិនអាចសម្រេចបាននោះទេ ។ ដោយសារតែប្រជាជនដែលបានចាកចេញពីប្រទេសកម្ពុជាក្នុងអំឡុង និងក្រោយទសវត្ស៍៧០ក៏មានរឿងរ៉ាវសំខាន់ៗដើម្បីចូលរួមនៅក្នុងការរកឃើញនូវការពិតរបស់ប្រវត្តិសាស្ត្រនេះដែរ នោះគណៈកម្មាធិការអប់រំគួរតែត្រូវបានបង្កើតឡើងនៅពេលអនាគតដើម្បីធានាថា ការប្រមូលចងក្រងរឿងរ៉ាវរបស់ប្រជាជនកម្ពុជាក៏អាចធ្វើទៅបាននៅខាងក្រៅប្រទេសកម្ពុជាដែរ ។ នៅក្នុងករណីរបស់ប្រទេសសេរ៉ាឡេអូន ក្រុមអ្នកតំណាងគណៈកម្មការដូចជាអង្គការក្រៅរដ្ឋាភិបាលនៅសហរដ្ឋអាមេរិកបានចូលរួមប្រមូលយករឿងរ៉ាវរបស់ប្រជាជនសេរ៉ាឡេអូនដែលរស់នៅក្រៅប្រទេស ។ អ្នកដែលបានចូលរួមនៅក្នុងការបង្កើតដំណើរការនេះអាចជួយផ្តល់ជាការណែនាំដើម្បីសម្រេចកិច្ចការនេះជាមួយនឹងប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេស ។

អាណត្តិនិងគោលដៅនៃការអនុវត្តរបស់គម្រោងនេះត្រូវតែមានលក្ខណៈច្បាស់លាស់ ។ ក្រុមការងាររបស់គម្រោងនេះត្រូវបានគេហៅថា «គណៈកម្មការផ្សះផ្សា និងស្វែងរកការពិត» ។ យ៉ាងណាមិញ ឈ្មោះនេះបានបង្កជាការយល់ច្រឡំពីគោលដៅជាច្រើនរបស់គម្រោងនេះ និងធ្វើឲ្យមានការរំពឹងចង់បានខ្ពស់ពីដំណើរការផ្សះផ្សាមួយ ដែលដំណើរការនេះមិនអាចបំពេញទៅតាមការរំពឹងចង់បានទាំងអស់នេះបានឡើយ ។ ប្រជាជនខ្លះនៅក្នុងប្រទេសកម្ពុជាបានផ្សះផ្សាជាមួយនឹងបទពិសោធន៍របស់ខ្លួន និងជាមួយអ្នកដទៃទៀតដែលធ្វើបាបខ្លួន ឬដែលគេបានធ្វើបាប ។ ចំណែកប្រជាជនដទៃទៀតវិញនឹងមិនអាចរកឃើញការផ្សះផ្សាឡើយ បើទោះបីជាដំណើរការផ្សះផ្សានិងស្វែងរកការពិតនេះអាចជួយដោះស្រាយបញ្ហាពីអតីតកាលបានក៏ដោយ ។ សម្រាប់ប្រទេសកម្ពុជានៅក្នុងពេលនេះ តម្រូវការចាំបាច់នោះគឺត្រូវតែកំណត់ពីការពិតនិងបង្កើតជារឿងរ៉ាវមួយដែលជួយនាំយកបទពិសោធន៍របស់បុគ្គលម្នាក់ៗដាក់ចូលទៅក្នុងបរិបទធំមួយ ហើយឆ្លើយតបទៅនឹងសំណួរដែលថា «ហេតុអ្វី» បានជាខ្មែរក្រហមប្រព្រឹត្តអំពើសាហាវឃោរឃៅបែបនេះ ។ សម្រាប់ប្រជាជនកម្ពុជាខ្លះ ដំណើរការផ្តល់សក្ខីកម្មនិងចូលរួមនៅក្នុងវេទិកាពិភាក្សាសាធារណៈទាំងនេះអាចជួយផ្តល់ការផ្សះផ្សាដល់ប្រជាជនកម្ពុជាបាន ។ សម្រាប់ប្រជាជនដទៃទៀតវិញ ចំណេះដឹងគឺជាអត្ថប្រយោជន៍ដ៏ធំដែលគេអាចទទួលបាន ។ ដើម្បីធ្វើឲ្យគម្រោងស្វែងរកការពិត និងការចងក្រងអតីតកាលនេះទទួលបានជោគជ័យ និងឋិតថេរនោះ អាណត្តិបំពេញការងារដោយយកចិត្តទុកដាក់បំផុតមួយអាចនឹងនាំមកនូវលទ្ធផលដ៏ល្អបំផុតសម្រាប់ការស្វែងរកការពិតពីប្រវត្តិសាស្ត្រនេះ ។ **ឆាំង យុ និង ចាយ៉ា រ៉ាមជី**

# ការប្រជុំជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា
# យល់ដឹងពីអំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និង យុត្តិធម៌

## ១) សេចក្តីសង្ខេប

ការប្រជុំជាលើកទីពីរស្តីពីការស្វែងយល់ពីអំពើប្រល័យពូជសាសន៍ជាមួយក្រុមជនជាតិភាគតិចត្រូវបានរៀបចំសម្រាប់ក្រុមជនជាតិភាគតិចនៅក្នុងប្រទេសកម្ពុជា ។ ដូចគ្នាទៅនឹងប្រទេសផ្សេងៗផងដែរ កម្ពុជាគឺជាប្រទេសមួយដែលមានចម្រុះជាតិសាសន៍ និងជាកន្លែងមួយដែលក្រុមជនជាតិភាគតិចជាច្រើនរស់នៅដោយសុខសន្តិភាព និងទទួលបានសិទ្ធិជាមូលដ្ឋានព្រមទាំងសេរីភាព ។ អ្នកចូលរួមភាគច្រើនគឺជាជនជាតិចាម ចំណែកឯមួយចំនួនទៀត គឺមានក្រុមជនជាតិភាគតិចវៀតណាម ខ្មែរកម្ពុជាក្រោម ព្រះសង្ឃ ជនជាតិព្នងមកពីខេត្តរតនគិរី ជនជាតិកួយមកពីខេត្តព្រះវិហារ និង ជនជាតិមិលក្ខុៈ ឬ (មិល) មកពីខេត្តក្រចេះ ។ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចំនួនប្រជាជនភាគច្រើនដែលរួមទាំងជនជាតិភាគតិចផងនោះបានប្រឈមមុខទៅនឹងអំពើអមនុស្សធម៌យ៉ាងធ្ងន់ធ្ងរបំផុត ដែលមិនធ្លាប់ឆ្លងកាត់ពីមុនមកនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ។ ប្រជាជនគ្រប់រូបកាលពីសម័យនោះបានទទួលរងនូវភាពអន្តរាយ និងការឈឺចាប់យ៉ាងច្រើនដែលមិនអាចវាស់វែងបាន ។ ប្រជាជនប្រហែលជាងពីរលាននាក់បានស្លាប់យ៉ាងអាណោចអាធ័មដោយសារគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យនេះ ។

ពេលវេលាកន្លងទៅជាងបីទសវត្សរ៍ ការមើលឃើញនូវយុត្តិធម៌ដែលពីមុនមានលក្ខណៈស្រពេចស្រពិលនោះបានប្រែក្លាយទៅជាសញ្ញាណដ៏ជោគជ័យមួយខណៈពេលដែលសំណុំរឿងតាមផ្លូវច្បាប់ត្រូវបានរៀបចំឡើងដើម្បីកាត់ទោសមេដឹកនាំទាំងប្រាំនាក់ ដូចជា ខៀវ សំផន អតីតគណៈប្រធានរដ្ឋ អៀង សារី



អ្នកចូលរួមជនជាតិភាគតិចថតរូបជុំគ្នានៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

អតីតរដ្ឋមន្ត្រីក្រសួងការបរទេស អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នួន ជា អតីតប្រធានសភា និង កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតមេគុកទួលស្លែង។ បន្ទាប់ពីការចេញសាលក្រមកាត់ទោសឌុច ឲ្យជាប់ទោសរយៈពេល៣៥ឆ្នាំរួចមក ការជំនុំជម្រះលើសំណុំរឿង០០២ របស់អតីតមេដឹកនាំទាំងបួននាក់ដូចរៀបរាប់ឈ្មោះខាងលើទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់សាធារណជន។ ប្រជាពលរដ្ឋជាច្រើនរំពឹងទុកថា «មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម» នឹងជួយធ្វើការពន្យល់ឲ្យកាន់តែច្បាស់លាស់ថែមទៀតពីមូលហេតុដែលរបបកម្ពុជាប្រជាធិបតេយ្យនេះធ្វើឲ្យមានប្រជាជនស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់បែបនេះ និងពីចេតនាពិតប្រាកដនៃគោលនយោបាយទាំងនោះ។ នៅក្នុងចំណោមបទចោទផ្នែកព្រហ្មទណ្ឌជាច្រើនដែលស្ថិតក្រោមច្បាប់ជាតិនិងអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានធ្វើការចោទប្រកាន់អតីតមេដឹកនាំទាំងបួនរូបនោះពីបទអំពើប្រល័យពូជសាសន៍មកលើជនជាតិភាគតិចចំនួនពីរក្រុមគឺ ជនជាតិចាមនិងវៀតណាម (រួមទាំងខ្មែរកម្ពុជាក្រោមផងដែរ) នៅក្នុងចំណោមបទចោទផ្សេងៗទៀត។

ក្នុងកិច្ចខំប្រឹងប្រែងដើម្បីផ្តល់នូវការយល់ដឹងឲ្យកាន់តែច្បាស់ពីបទចោទ ការប្រជុំនេះបានប្រមូលផ្តុំសមាជិកជនជាតិភាគតិចជាងបីរយនាក់ រួមមាន ជនជាតិចាម វៀតណាម និងក្រុមជនជាតិភាគតិចជាច្រើនទៀតដែលអញ្ជើញមកពីបណ្តាខេត្តក្រុងចំនួន១៦នៅប្រទេសកម្ពុជា (តំណាងជនជាតិភាគតិចមកពីខេត្តផ្សេងៗទៀតបានចូលរួមការប្រជុំវគ្គទី១ នៅខែតុលា ឆ្នាំ២០១០)។ ការជួបជុំគ្នានេះមានគោលបំណងបង្កើននូវការយល់ដឹងពីពាក្យអំពើប្រល័យពូជសាសន៍ និងប្រវត្តិនៃអនុសញ្ញាស្តីអំពីការបង្ការបទឧក្រិដ្ឋប្រល័យពូជសាសន៍។ បន្ថែមពីនេះទៅទៀត ការជួបជុំគ្នានេះគឺសង្ឃឹមថានឹងអាចធ្វើឲ្យប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យកាន់តែពេញលេញថែមទៀតតាមរយៈការសាកសួរ ក៏ដូចជាបង្កើនការពិភាក្សាថែមទៀតទៅលើរបបកម្ពុជាប្រជាធិបតេយ្យនិងលើកទឹកចិត្តឲ្យអ្នកភូមិចូលរួមកាន់តែសកម្មនៅក្នុងដំណើរការស្វែងរកការពិត។

ក្នុងការប្រជុំនេះដែរក៏បានអញ្ជើញអ្នកជំនាញផ្នែកច្បាប់ សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ និងអ្នកស្រាវជ្រាវមួយចំនួនដើម្បីផ្តល់នូវការពន្យល់ឲ្យច្បាស់លាស់ទាក់ទងនឹងអ្វីដែលហៅថាអំពើប្រល័យពូជសាសន៍នៅក្នុងបរិបទច្បាប់ អក្សរសាស្ត្រខ្មែរ និងនយោបាយ។ បន្ទាប់ពីកិច្ចពិភាក្សា មានការបញ្ចាំងខ្សែភាពយន្តដែលមានចំណងជើងថា «ឃ្លាតទៅសែនឆ្ងាយ» និងការជំរុញលើកទឹកចិត្តឲ្យអ្នកដែលមកចូលរួមនិយាយនិងចែករំលែកនូវបទពិសោធន៍ជាមួយកូនចៅ និងសហគមន៍របស់គាត់។ នេះគឺជាវិធីសាស្ត្រមួយដើម្បីឆ្ពោះទៅរកការកសាងនូវភាពជារួមក្នុងភាពទីទៃ និងការការពារអំពើប្រល័យពូជសាសន៍។

## ២) សកម្មភាពនៅក្នុងកិច្ចប្រជុំ

អ្នកដែលមកចូលរួមនៅក្នុងកិច្ចប្រជុំនេះ បានអញ្ជើញមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជាតែម្នាក់ឯង និងខ្លះទៀតអញ្ជើញមកជាក្រុមពីបណ្តាខេត្តឆ្ងាយៗ។ ចំពោះអ្នកចូលរួមមួយចំនួនធំ ការធ្វើដំណើរមកទីក្រុងភ្នំពេញនេះគឺចំណាយពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ ខណៈពេលដែលអ្នកចូលរួមមួយចំនួនតូចត្រូវចំណាយពេលស្ទើរតែមួយថ្ងៃពេញ។ ពេលអញ្ជើញមកដល់នៅថ្ងៃទី២៣ វិច្ឆិកា អ្នកចូលរួមទាំងអស់ត្រូវបានផ្តល់នូវការស្វាគមន៍យ៉ាងកក់ក្តៅ ហើយបន្ទាប់ពីទទួលទានអាហារថ្ងៃត្រង់រួច អ្នកចូលរួមទាំង



អ្នកចូលរួមប្រជុំស្តីពីអំពើប្រល័យពូជសាសន៍

អស់បានត្រឡប់ទៅកន្លែងស្នាក់នៅវិញ ។ ជាមួយគ្នានោះផងដែរ អ្នកចូលរួមនីមួយៗក៏បានទទួលនូវឯកសារសម្រាប់យកទៅអានមុនពេលចាប់ផ្តើមការប្រជុំនៅថ្ងៃទី២៨ វិច្ឆិកា ។ អ្នកចូលរួមទាំងអស់បានចំណាយពេលមួយថ្ងៃមុនដើម្បីអាននិងស្វែងយល់ខ្លះៗពីឯកសារទាំងនោះ ។

### ក) កម្មវិធីពេលព្រឹក

នៅថ្ងៃទី ២៨ វិច្ឆិកា កញ្ញា សូ ហ្វារីណា ដែលជាប្រធានគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំបានរង់ចាំនៅក្នុងបន្ទប់ប្រជុំនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដើម្បីស្វាគមន៍ការអញ្ជើញមកដល់របស់អ្នកចូលរួម ។ បន្ទាប់ពីអ្នកចូលរួមទាំងអស់រកកន្លែងអង្គុយហើយ កញ្ញា ហ្វារីណា ចាប់ផ្តើមនិយាយថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ចំពោះការចំណាយពេលចូលរួមក្នុងកិច្ចប្រជុំនេះ ។ កញ្ញា ហ្វារីណា បានឆ្លៀតឱកាសប៉ុន្មាននាទីដើម្បីបង្វែរការចាប់អារម្មណ៍របស់អ្នកចូលរួមទាំងអស់មកលើការស្លាប់យ៉ាងអាណោចអាធ័មនៅក្នុងឧបទ្ទវហេតុរត់ជាន់គ្នានៅថ្ងៃចុងក្រោយនៃពិធីបុណ្យអុំទូក ដែលបានធ្វើឲ្យប្រជាជនស្លាប់៣៥១នាក់ និងរបួស៣៩៥នាក់ ។ ដើម្បីសម្តែងនូវការចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំជាមួយក្រុមគ្រួសារជនរងគ្រោះ បន្ទាប់ពីការគោរពភ្លេងជាតិរួច កញ្ញា ហ្វារីណា បានសុំឲ្យអ្នកចូលរួមទាំងអស់ធ្វើការស្មឹងស្មាធិ៍មួយស្របក់ ដើម្បីគោរពដល់វិញ្ញាណក្ខន្ធជនរងគ្រោះ ។

ដោយយោងទៅតាមពេលវេលាដែលបានកំណត់ កញ្ញា ហ្វារីណា បានស្នើឲ្យអ្នកចូលរួមទាំងអស់ ធ្វើការបំពេញតារាងស្ទាបស្ទង់មតិមុនពេលកិច្ចប្រជុំដំណើរការក្នុងគោលបំណងដើម្បីវាយតម្លៃការយល់ដឹងរបស់គាត់ស្តីពីអ្វីទៅដែលដែលថាអំពើប្រល័យពូជសាសន៍ ។ បន្ទាប់ពីបំពេញចប់សព្វគ្រប់ហើយ លោក វ៉ាន់ថាន់ ពោដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាបានឡើងថ្លែងសុន្ទរកថា ដើម្បីចាប់ផ្តើមកម្មវិធីជាផ្លូវការនិងធ្វើការស្វាគមន៍ដល់អ្នកចូលរួមទាំងអស់និងវាគ្មិន ។


អ្នកចូលរួមស្តាប់ការពន្យល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត

លោក វ៉ាន់ថាន់ ពោដារ៉ា បានថ្លែងអំណរគុណដល់អ្នកចូលរួមក៏ដូចជាវាគ្មិនទាំងអស់ចំពោះវត្តមានរបស់គាត់ និងធ្វើការកត់សម្គាល់ពីសារសំខាន់នៃកិច្ចប្រជុំនេះ ។ លោកបាននិយាយថា «ការប្រជុំនេះគឺមានលក្ខណៈពិសេសណាស់» ហើយបន្ថែមទៀតថាប្រជាជនទាំងអស់ ជាពិសេសក្រុមជនជាតិភាគតិចធ្លាប់បានឮនិងនាំគ្នានិយាយពាក្យថា «ប្រល័យពូជសាសន៍» នេះជាយូរណាស់មកហើយ ប៉ុន្តែចំពោះការយល់ដឹងឲ្យច្បាស់លាស់ទៅលើពាក្យនេះនៅតែស្រពេចស្រពិលនៅឡើយ ។ លោកក៏បានជំរុញឲ្យអ្នកចូលរួមទាំងអស់ផ្តោតការយកចិត្តទុកដាក់មកលើការប្រជុំដើម្បីឲ្យមានចំណេះដឹងនិងការយល់ដឹងពីប្រធានបទនេះកាន់តែប្រសើរឡើង ។

បន្ទាប់ពីការថ្លែងរបស់លោក វ៉ាន់ថាន់ ពោដារ៉ា រួចមក កញ្ញា ហ្វារីណា បានអញ្ជើញលោក វីលៀម ស្មីត សហព្រះរាជអាជ្ញារងអន្តរជាតិ និងលោក ចាន់ ដារ៉ារស្មី សហព្រះរាជអាជ្ញារងជាតិ ដើម្បីធ្វើបទបង្ហាញជូនដល់អ្នកចូលរួម ។ ធ្វើការថ្លែងក្នុងនាមឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាពិសេសក្នុងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា លោក វីលៀម ស្មីត បានចូលរួមចែករំលែកទុក្ខយ៉ាងក្រៀមក្រំជាមួយអ្នកដែលបានស្លាប់នៅក្នុងឧបទ្ទវហេតុរត់ជាន់គ្នានោះ ។ បន្ទាប់មក លោកក៏បានចាប់ផ្តើមធ្វើបទបង្ហាញស្តីពីការឲ្យនិយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក៏ដូចជារបៀបនិងថាតើបទឧក្រិដ្ឋនេះត្រូវបានប្រើប្រាស់នៅសាលាក្តីខ្មែរក្រហមដែរឬអត់ ។ ដោយយោង

ទៅតាមអនុសញ្ញាស្តីពីការបង្ការបទឧក្រិដ្ឋប្រល័យពូជសាសន៍ លោក វីលៀម ស្ម៊ីត បានសង្កត់ធ្ងន់ថា «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ត្រូវបានដាក់បញ្ចូលទៅក្នុងមាត្រា៤នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយថាអតីតមេដឹកនាំទាំងបួនរូប ដែលរង់ចាំការកាត់ទោសនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ទៅលើក្រុមជនជាតិភាគតិចដែលមានជនជាតិចាមនិងវៀតណាម (រួមទាំងខ្មែរក្រោមផង) នៅក្នុងប្រទេសកម្ពុជា ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺត្រូវបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លិចបំផ្លាញដោយផ្នែក ឬទាំងស្រុងមកលើសមាជិកក្រុម ប្រជាជាតិ ជាតិពន្ធុ ជាតិសាសន៍ និងសាសនា ។ លោកក៏បានលើកឡើងផងដែរថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនមែនធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗ ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ។ លោក ចាន់ ដារ៉ារស្មី បានបន្ថែមទៅលើយោបល់របស់លោក វីលៀម ស្ម៊ីត ដោយកត់សម្គាល់ថា អំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មដែលសាហាវឃោរឃៅដែលនៅតែបន្តកើតមាននាពេលបច្ចុប្បន្ន ។ អនុសញ្ញានេះត្រូវបានប្រកាសថាជាឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងឆ្នាំ១៩៤៨ ។ គាត់ធ្វើការសង្ខេបថា ទោះបីជាមានប្រទេសដល់ទៅ១៤០ បានផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះក៏ដោយ ក៏ឧក្រិដ្ឋកម្មនេះនៅតែមិនអាចបញ្ឈប់បាននៅក្នុងបរិបទសកលលោកទេ ។ លោកបានបញ្ជាក់ប្រាប់អ្នកចូលរួមទាំងអស់ថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឥឡូវនេះត្រូវបានអនុម័តនៅក្នុងច្បាប់របស់ប្រទេសកម្ពុជា ហើយតុលាការនិងរាជរដ្ឋាភិបាលកម្ពុជាមានយុត្តាធិការក្នុងការកាត់ទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នាថ្ងៃអនាគត ប្រសិនបើវាកើតឡើងទៀត ។

បន្ទាប់ពីធ្វើបទបង្ហាញរួចមក កញ្ញា ហ៊ុរីណា បានលើកទឹកចិត្តឲ្យអ្នកចូលរួមលើកជាសំណួរទៅកាន់សហព្រះរាជអាជ្ញារងទាំងពីរ ។ អ្នកចូលរួមជនជាតិចាមបីនាក់មកពីខេត្តកំពង់ឆ្នាំងបានលើកជាសំណួរឡើងមុនគេ ។ លោក កើ ម៉ាត់ បានបញ្ជាក់ពីការសង្ស័យរបស់គាត់ទៅលើបញ្ហាដែលថា តើអង្គការសហប្រជាជាតិបានដឹងដែរឬទេពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ហើយហេតុអ្វីបានជាអង្គការសហប្រជាជាតិនៅតែអនុញ្ញាតឲ្យខ្មែរក្រហមកាន់កាប់កៅអីកម្ពុជា នៅអង្គការសហប្រជាជាតិក្រោយឆ្នាំ១៩៧៩ ទៀត ។ ចំណែកលោក នង វ៉ាន់ឌី យល់ឃើញថា អង្គការសហប្រជាជាតិអសមត្ថភាពក្នុងការទប់ស្កាត់ការកើតមានឡើងនៃអំពើប្រល័យពូជសាសន៍ ប៉ុន្តែលោកជឿជាក់ថាអង្គការសហប្រជាជាតិបានធ្វើនូវអ្វីដែលខ្លួនអាចធ្វើទៅបានបន្ទាប់ពីអំពើប្រល័យពូជសាសន៍បានកើតឡើងរួចហើយ ទោះបីជាជីវិតមនុស្សជាច្រើនបានបាត់បង់ហើយក៏ដោយ ។ ទាំងលោក ម៉ាត់ និង វ៉ាន់ឌី សុទ្ធតែយល់ស្របជាមួយលោកស្រី លី សាគី ដែលចង់មើលឃើញការកាត់ទោសអតីតមេដឹកនាំទាំងបួនរូបនេះឲ្យលឿនជាងនេះ ។


រូបពីឆ្វេងមកស្តាំ លោក ស៊ីវ ធួន ចាន់ ដារ៉ារស្មី និង វ៉ាន់ថាន់ ពៅដារ៉ា ក្រោយពេលកិច្ចប្រជុំស្តីពីអំពើប្រល័យពូជសាសន៍

បន្ទាប់ពីជួបជាមួយអ្នកជំនាញផ្នែកច្បាប់រួចមក មានបទបង្ហាញពីសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរដែលមានលោកសាស្ត្រាចារ្យ ជួរ គារី និង ស៊ីវ ធួន រួមជាមួយលោក អេង កុកថាយ ដែលជានាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកសាស្ត្រាចារ្យទាំងពីរបានធ្វើការពន្យល់ពាក្យប្រល័យពូជសាសន៍ដោយយោងទៅតាមភាសានិងវប្បធម៌របស់ខ្មែរ ។ លោកសាស្ត្រាចារ្យ ជួរ គារី បានធ្វើការពន្យល់ពាក្យនេះថាជា «អំពើ ឬការសម្លាប់មនុស្ស

ដោយឥតរើសមុខមិនខ្វល់ពីភាពខុសគ្នា ឬ ដូចគ្នានៃពូជសាសន៍ ឬសាសនាណាមួយឡើយ» ។ សាស្ត្រាចារ្យ ស៊ីវ ធួន បានទទួលស្គាល់ថា ពាក្យប្រល័យពូជសាសន៍នេះគឺជាពាក្យថ្មីមួយនៅក្នុងប្រទេសកម្ពុជា ហើយបន្ថែមទៀតថា យើងទើបតែដឹងពីការកាប់សម្លាប់មនុស្សយ៉ាងព្រៃផ្សៃនៅឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ។ ដោយពិចារណាទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនេះ លោក អេង កុកថាយ យល់ឃើញថា អនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះ គឺមានលក្ខណៈតូចចង្អៀតនិងទូលាយពេក ។ លោកបានអះអាងថា «ក្រុមនយោបាយនិងសង្គម» គួរតែត្រូវបានទទួលការការពារឲ្យប្រសើរជាងនេះ ហេតុដូច្នេះហើយគួរតែត្រូវបានរាប់បញ្ចូលទៅក្នុងនិយមន័យនេះ ។ ផ្ទុយពីមតិរបស់លោក វីលៀម ស្មីត លោក កុកថាយ បានសង្កត់ធ្ងន់ថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះគឺធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀត ។

## ១) កម្មវិធីពេលរសៀល

អ្នកចូលរួមបានស្តាប់ការពន្យល់របស់អ្នកជំនាញខាងច្បាប់និងអក្សរសាស្ត្រ ហើយចាត់ទុកថាមានប្រយោជន៍ ទោះបីជាការប្រជុំនាពេលព្រឹកមានរយៈពេលយូរដែលធ្វើឲ្យអ្នកចូលរួមមួយចំនួនមានការនឿយហត់បន្តិចមែន ប៉ុន្តែគាត់ហាក់ដូចជាមានអារម្មណ៍ស្រស់ថ្លា និងមានកម្លាំងឡើងវិញបន្ទាប់ពីទទួលទានអាហារពេលថ្ងៃត្រង់រួច ហើយសម្រាប់អ្នកចូលរួមដែលជាអ្នកកាន់សាសនាអ៊ីស្លាមវិញ គឺបន្ទាប់ពីថ្វាយបង្គំនៅក្នុងសាលប្រជុំរួច ។ អ្នកចូលរួមខ្លះបានអង្គុយជាក្រុមធ្វើការពិភាក្សាពីបញ្ហាផ្សេងៗ ដូចជានិយាយពីអ្វីដែលទទួលបានពីកម្មវិធីពេលព្រឹក និងធ្វើការចែករំលែកនូវបទពិសោធន៍កាលពីជំនាន់ខ្មែរក្រហម ។ ការសម្រាកពេលថ្ងៃត្រង់ និងការពិភាក្សាផ្សេងៗបានបង្កើតនូវបរិយាកាសកក់ក្តៅមួយក្នុងចំណោមអ្នកចូលរួម និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

កម្មវិធីពេលរសៀលបានចាប់ផ្តើមជាមួយនឹងខ្សែភាពយន្តមួយដែលមានចំណងថា «ឃ្លាតទៅសែនឆ្ងាយ» ។ មុនពេលចាប់ផ្តើមបញ្ចាំងខ្សែភាពយន្តនេះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក ឆាយ បូរ៉ា អ្នកផលិតនិងដឹកនាំរឿងបានសំណេះសំណាលជាមួយអ្នកចូលរួម ។ លោក ឆាំង យុ បានរំឭកពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់នៅក្នុងសម័យខ្មែរក្រហម ដោយលើកឡើងថា គាត់ចងចាំយ៉ាងច្បាស់នូវរឿងរ៉ាវរបស់ក្មេងប្រុស និងក្មេងស្រីម្នាក់ដែលគាត់ស្គាល់កាលពីជំនាន់នោះ ។ លោកបានជួបក្មេងប្រុសនោះម្តងទៀតដែលក្មេងប្រុសនោះ ក៏មានវត្តមាននៅក្នុងសាលប្រជុំនៅថ្ងៃនោះដែរ ប៉ុន្តែជាអកុសលក្មេងស្រីម្នាក់នោះបានស្លាប់បាត់បង់ជីវិតទៅហើយ ។ អាស្រ័យហេតុនេះ លោកបានលើកទឹកចិត្តឲ្យអ្នកដែលចូលរួមទាំងអស់ធ្វើការចែករំលែកនូវអ្វីដែលខ្លួនបានឆ្លងកាត់កាលពីពេលនោះ ។ លោកក៏បាននិយាយទៀតថា នេះគឺជារឿងមួយដែលអាចយល់បានថា ការនិយាយរឿងចេញមកក្រៅ គឺធ្វើឲ្យយើងមានអារម្មណ៍ឈឺចាប់ជាមួយនឹងការចងចាំដ៏ជូរចត់នោះ ។ ប៉ុន្តែនេះគឺជាដំណាក់កាលនៃការព្យាបាលរបួសនិងដើម្បីការអប់រំ ។ លោកទទូចទៀតថាប្រសិនបើក្មេងជំនាន់ក្រោយមានការស្រពេចស្រពិលនឹងប្រវត្តិសាស្ត្រខ្មែរក្រហម នោះយើងទាំងអស់គ្នាមិនគួរព្រងើយនោះទេ ប៉ុន្តែយើងត្រូវតែព្យាយាមដើម្បីធ្វើឲ្យក្មេងៗយល់និងជឿ ។

លោក ឆាយ បូរ៉ា យល់ឃើញថា ខ្សែភាពយន្តមួយនេះគឺជាឆាកមួយដែលអាចបង្ហាញពីជ្រុងមួយនៃប្រវត្តិសាស្ត្រដ៏ជូរចត់ ។ ដូចមតិរបស់លោក ឆាំង យុ ដែរ លោក បូរ៉ា និយាយថា ខ្សែភាពយន្តនេះគឺជាសាររូបភាពសម្រាប់ក្មេងៗជំនាន់ក្រោយ ។ លោកក៏ទទួលស្គាល់ដែរថា ការសរសេរនិងនិយាយពីប្រវត្តិសាស្ត្រខ្មែរក្រហមបានដើរតួយ៉ាងសំខាន់ណាស់ ។ លោកក៏បានបញ្ជាក់អំពីការពិតនៃប្រវត្តិសាច់រឿងរបស់ប្រពន្ធនិងម្តាយក្មេករបស់គាត់ ។ ម្តាយក្មេករបស់គាត់មិនដែលឃើញឪពុកវិលត្រឡប់មកវិញទេ បន្ទាប់ពីខ្មែរក្រហមចាប់យកគាត់ដាក់លើឡានបាត់ទៅ ។ ខាងក្រោមនេះ គឺជាការពិពណ៌នាសង្ខេបនៃខ្សែភាពយន្ត ៖

> ខ្សែភាពយន្តនេះនិយាយពីរឿងរ៉ាវរបស់ស្ត្រីម្នាក់ឈ្មោះ អមរា ហៅ (សិលា) និងសមាជិកគ្រួសាររបស់គាត់ក្នុងសម័យខ្មែរក្រហម ។ អមរា ជាម្តាយដែលមានកូនប្រាំនាក់ និងជាស្ត្រីម្នាក់ដែលតស៊ូដើម្បីរួចរស់ជីវិតពីរបបនេះ ។ គាត់ធ្លាប់រស់នៅក្នុងត្រកូលអ្នកធូរធារ ប៉ុន្តែក្រោយមកក្រុមគ្រួសារនេះត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះ ហើយត្រូវ

ធ្វើការផ្សារភ្ជាប់ធ្ងន់ធ្ងរនៅស្រែចម្ការដូចប្រជាជនដទៃទៀតដែរកាលពីសម័យនោះ ។ សមាជិកគ្រួសារទីមួយដែលត្រូវបានចាប់ខ្លួននិងសម្លាប់ចោលមុនគេ គឺឪពុករបស់គាត់ដែលជាអតីតមេបញ្ជាការកងទ័ពរបស់សាធារណរដ្ឋខ្មែរ (លន់ នល់) ។ ចំណែកឯស្វាមីរបស់គាត់គឺជាអ្នកទីពីរ ។ ក្នុងអំឡុងរបបខ្មែរក្រហម កូនៗនិងសមាជិកគ្រួសាររបស់គាត់ត្រូវស្លាប់ដោយសារការអត់អាហារ ជំងឺ និងការសម្លាប់ ។ ខ្សែភាពយន្តដ៏គួរឲ្យឈឺចាប់នេះបានស្តែងនូវការអត់ធន់ក្នុងចិត្ត ភាពក្លាហាន សេចក្តីស្រឡាញ់ រវាងម្តាយនិងកូន និងការបែកបំបែករវាងសមាជិកគ្រួសារ


ស្ត្រីជនជាតិចាមសួរសំណួរទៅវាគ្មិន


សិស្សវិទ្យាល័យជនជាតិចាមសួរសំណួរទៅវាគ្មិន

ក៏ដូចជាវិប្បដិសារីនៅក្នុងអំឡុងពេលដ៏លំបាកនេះ ។ អមរា និងកូនពីរនាក់របស់គាត់បានរស់ពីការស្លាប់ ប៉ុន្តែរងទុក្ខវេទនាពីការបាត់បង់និងឈឺចាប់ដែលរបបនោះបានបន្សល់ទុក ។ របួសផ្លូវចិត្តរបស់គាត់នៅតែបន្តរហូតមកដល់សព្វថ្ងៃនេះ ។ អមរា ព្យាយាមធ្វើការព្យាបាលរបួសរបស់គាត់តាមរយៈការនិយាយប្រាប់និងការចាប់យកធម៌អាថ៌និងជំនឿដាក់ខ្លួន ។

ខ្សែភាពយន្តនេះត្រូវបានសរសេរឡើងដោយលោកស្រី កូវ សុធារី ដែលជាអ្នកសម្តែង តួលោកស្រី (អមរា) ហើយត្រូវបានដឹកនាំសម្តែងនិងផលិតដោយលោក ឆាយ បូរ៉ា ។ គោលបំណងសំខាន់នៃការផលិតកុននេះ គឺដើម្បីជំរុញឲ្យប្រជាជនធ្វើការនិយាយដើម្បីព្យាបាលរបួស និងអប់រំក្មេងជំនាន់ក្រោយអំពីរបបខ្មែរក្រហម ។ តាមរយៈការអង្កេតរបស់ខ្ញុំ ខ្សែភាពយន្តនេះពិតជាធ្វើឲ្យអ្នកចូលរួមទាំងអស់ មិនថាអ្នករួចរស់ពីរបបនេះឬក៏យុវជនជំនាន់ក្រោយ សុទ្ធតែមានការចាប់អារម្មណ៍យ៉ាងខ្លាំង ។ អ្នកចូលរួមជាច្រើនបានទស្សនាខ្សែភាពយន្តនេះពោរពេញដោយមនោសញ្ចេតនាជាទីបំផុត ។ ដូចអ្នកដទៃទៀតដែរ ស្ត្រីជនជាតិចាមម្នាក់យំយ៉ាងខ្លាំង ហើយដើរចេញពីសាលប្រជុំដើម្បីលុបមុខចេញមួយភ្លែត ។ យុវជនម្នាក់ដែលអង្គុយនៅពីមុខខ្ញុំបានជូតទឹកភ្នែកដែលហូរមិនចេះដាច់ ។ ពិតប្រាកដណាស់ ខ្សែភាពយន្តនេះបានធ្វើឲ្យមានប្រតិកម្មផ្នែកអារម្មណ៍យ៉ាងខ្លាំងជាបន្តបន្ទាប់ពីសំណាក់អ្នកចូលរួម ។ ខាងក្រោមនេះគឺជាយោបល់ដែលបានមកពីអ្នកចូលរួមវ័យចំណាស់បួននាក់ ៖

- «នេះគឺជារឿងពិតប្រាកដ និងមិនអាចបំភ្លេចបាន ។ ខ្ញុំពិតជាគាំទ្រកុននេះណាស់ ។ ខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់នៅពេលដែលឪពុករបស់ខ្ញុំត្រូវបានដុតទាំងរស់នៅសម័យនោះ ។ ខ្ញុំសំណូមពរកុំឲ្យមានរបបនេះកើតឡើងម្តងទៀត» ។
- «កុននេះពិតជាពោរពេញដោយមនោសញ្ចេតនាមែន ។

នេះគឺជារឿងពិត ។ ប្រសិនបើមាននរណាម្នាក់សើចចំអកឲ្យខ្សែភាពយន្តនេះ នោះគឺដូចជាសើចចំអកឲ្យឪពុកម្តាយនិងប្រទេសរបស់ខ្លួនអីចឹង ។ ខ្ញុំសង្ឃឹមថាក្មេងៗជំនាន់ក្រោយទាំងអស់គួរតែទស្សនាខ្សែភាពយន្តនេះ» ។

◆ «កុននេះគួរតែនាំយកទៅបញ្ចាំងឲ្យប្រជាជនទាំងអស់នៅទូទាំងប្រទេសកម្ពុជាបានទស្សនា» ។

◆ «ខ្ញុំមើលកុននេះជាលើកទីមួយ ។ ខ្ញុំសូមសំណូមពរថាខ្សែភាពយន្តនេះគួរតែបញ្ចាំងឲ្យអតីតមេដឹកនាំទាំងបួននាក់ដែលកំពុងរង់ចាំការកាត់ទោសនោះបានមើលឃើញ ។ ចំណែកឯសំណួរវិញ និងសួរថា តើអ្នកឯងមានបានដឹងពីជីវិតដ៏សែនវេទនារបស់





ស្ត្រីជនជាតិចាមសួរសំណួរទៅវាគ្មិន

ប្រជាជនខ្មែរឬទេ»? ។ ចំណែកខាងក្រោមនេះគឺជាមតិយោបល់ពីយុវជនបីរូប ៖

◆ «កុននេះគឺពិតជាជះឥទ្ធិពលដល់ការគិតរបស់ខ្ញុំមែន ហើយខ្ញុំនឹងនិយាយប្រាប់មិត្តភក្តិរបស់ខ្ញុំពីកុននេះ ។ ខ្ញុំសង្ឃឹមថាយុវជនទាំងអស់នឹងទស្សនាខ្សែភាពយន្តនេះ ។ សុំសំណូមពរឲ្យអ្នកដឹកនាំសម្តែងធ្វើការផលិតខ្សែភាពយន្តបន្ថែមទៀត» ។

◆ «ខ្ញុំមានអារម្មណ៍ក្តុកក្តួលនិងភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ខ្សែភាពយន្តជាច្រើនផ្សេងទៀតមិនអាចធ្វើឲ្យខ្ញុំមានអារម្មណ៍បែបនេះទេ» ។

◆ «ខ្ញុំមើលខ្សែភាពយន្តបណ្តើរយំបណ្តើរ ។ ខ្ញុំសូមអរគុណលោកដែលបានបញ្ចាំងខ្សែភាពយន្តនេះ ។ ខ្ញុំសង្ឃឹមថានឹងមានការបញ្ចាំងខ្សែភាពយន្តនេះនៅតាមបណ្តាខេត្តនានា» ។

ជារួម ការបញ្ចាំងខ្សែភាពយន្តនេះអាចក្លាយជាគ្រឿងជំរុញមួយសម្រាប់លើកទឹកចិត្តឲ្យប្រជាជនគ្រប់រូបធ្វើការនិយាយនិងចែករំលែកជាមួយមិត្តភក្តិនិងអ្នកជិតខាងរបស់ខ្លួនពីឧក្រិដ្ឋកម្មដ៏គួរឲ្យស្អប់ខ្ពើមមកលើប្រជាពលរដ្ឋកម្ពុជា រួមទាំងមកលើក្រុមជនជាតិភាគតិចផ្សេងដែរ ។ ការបញ្ចាំងខ្សែភាពយន្តនេះក៏អាចក្លាយជាវិធីសាស្រ្តមួយក្នុងការឆ្ពោះទៅរកការកសាងទំនាក់ទំនងសង្គមមួយឲ្យកាន់តែប្រសើរឡើងផងដែរ ។

### ៣) អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងសិទ្ធិរបស់ក្រុមជនជាតិភាគតិច

សោកនាដកម្មជាច្រើនដែលបង្កើតឡើងដោយមនុស្សជាតិបានកើតឡើងក្នុងប្រវត្តិសាស្រ្តរបស់ពិភពលោក ។ អ្នកជំនាញផ្នែកច្បាប់បានរៀបចំធ្វើការសរសេរនិងកែតម្រូវឡើងវិញលើច្បាប់អន្តរជាតិមួយចំនួន ដោយសង្ឃឹមថាឧបករណ៍ផ្លូវច្បាប់ទាំងអស់នេះនឹងអាចក្លាយជាវិធីសាស្រ្តដើម្បីទប់ស្កាត់ ។ ទាំងតុលាការជាតិនិងអន្តរជាតិបានលេចចេញជារូបរាងឡើងដើម្បីនាំយកអ្នកដែលត្រូវបានគេជឿជាក់ថាជាអ្នកទទួលខុសត្រូវ

ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរប្រឆាំងនឹងមនុស្សជាតិទៅកាត់ទោស ។ ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដ៏គួរឲ្យស្អប់ខ្ពើមបំផុតនោះគឺ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ចំណែកឯប្រវត្តិនៃការបង្កើតពាក្យនេះគឺត្រូវរំឭកទៅមើលការសម្លាប់រង្គាលរបស់ជនជាតិអាល្លឺម៉ង់ ។ ដើម្បីធ្វើការពិពណ៌នាឧក្រិដ្ឋកម្ម នៅក្នុងឆ្នាំ១៩៤៤ មេធាវីជនជាតិប៉ូឡូញ-ជ្វីហ្វដែលមានឈ្មោះថា រ៉ាហ្វែល លឹមគិន (Raphael Lemkin) បានហៅឧក្រិដ្ឋកម្មនេះថាជា «អំពើប្រល័យពូជសាសន៍» ។ អ្នកជំនាញលើមុខវិជ្ជាផ្សេងៗបានធ្វើការពិភាក្សាលើពាក្យដែលទើបបង្កើតថ្មីនេះ ដើម្បីធ្វើការកំណត់និយមន័យ និងប្រើប្រាស់ពាក្យនេះសម្រាប់ច្បាប់អន្តរជាតិ ។ បួនឆ្នាំក្រោយមក តម្រូវការជាផ្លូវការចាំបាច់មួយរបស់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានកើតឡើង ដែលមានចែងនៅក្នុងមាត្រា២ ៖

> អំពើណាមួយក្នុងចំណោមអំពើទាំងប៉ុន្មានខាងក្រោម ដែលត្រូវបានធ្វើឡើង ដោយចេតនា ទោះជាទាំងស្រុងក្តី ឬក៏មួយផ្នែកក្តី មកលើប្រជាជាតិ ជាតិពន្ធុ ពូជសាសន៍ ឬក្រុមសាសនា ដូចជា ៖
>
> ក) ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ។
>
> ខ) បង្កការឈឺចាប់និងខូចខាតយ៉ាងដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។
>
> គ) បង្កឡើងដោយចេតនានូវមហន្តរាយ ឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកម្ទេចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃសង្គម ។
>
> ឃ) ដាក់បង្ខំនូវវិធានការនានាដែលបង្ការមិនឲ្យមានកំណើតទារកនៅក្នុងសង្គម
>
> ង) យកកូនក្មេងចេញពីក្រុមមួយទៅក្រុមមួយទៀតដោយបង្ខិតបង្ខំ ។

អនុសញ្ញានេះបានផ្តល់នូវមូលដ្ឋានគ្រឹះមួយដ៏រឹងមាំដើម្បីធ្វើការការពារ «ក្រុមប្រជាជាតិ ជាតិពន្ធុ ពូជសាសន៍ និងក្រុមសាសនា» ចេញពីការបំផ្លិចបំផ្លាញទាំងស្រុងក្តី ឬដោយផ្នែកក្តី ។ រដ្ឋហត្ថលេខីជាច្រើនដែលរួមទាំងប្រទេសកម្ពុជាផងនោះ ត្រូវបានតម្រូវឲ្យអនុវត្តក្របខណ្ឌផ្លូវច្បាប់នេះ ។ ប៉ុន្តែចាប់តាំងពីពេលដែលអនុសញ្ញានេះមានរូបរាងមក ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅតែបន្តកើតមាននៅទូទាំងសកលលោក ជាពិសេសទាក់ទងទៅនឹងមុខសញ្ញានៃក្រុមជនជាតិភាគតិច ។ ឧទាហរណ៍ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលកើតមានឡើងនៅប្រទេសបូស្នៀពីឆ្នាំ១៩៩២-១៩៩៥ បានសម្លាប់មនុស្សរហូតដល់ទៅពីរសែននាក់ ។ នៅប្រទេសរ៉្វាន់ដា អំពើប្រល័យពូជសាសន៍បានសម្លាប់ជីវិតជនជាតិទុតស៊ី និង ហ៊ូទូ អស់ប្រហែលជាប្រាំសែននាក់នៅក្នុងឆ្នាំ១៩៩៤ ។ ការសម្លាប់រង្គាលជនជាតិភាគតិចទុតស៊ីក្នុងរយៈពេលតែជាង១០០ថ្ងៃនោះ គឺជាឧក្រិដ្ឋកម្មមួយដ៏គួរឲ្យស្អប់ខ្ពើមជាទីបំផុត ។ បន្ថែមពីនេះទៅទៀត របបកម្ពុជាប្រជាធិបតេយ្យត្រូវបានចោទប្រកាន់ថា ជារបបប្រល័យពូជសាសន៍ដោយសារតែរបបនេះមានបំណងធ្វើការសម្លាប់ជនជាតិភាគតិចចាម និងវៀតណាម (ដែលរួមខ្មែរក្រោមផងដែរ) នៅក្នុងអំឡុងពេលកាន់កាប់រយៈពេលបួនឆ្នាំ (១៩៧៥-១៩៧៩) ។ ក្រុមជនជាតិភាគតិចតែងតែត្រូវបានកំណត់ជាមុខសញ្ញាសម្លាប់ និងជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ទោះបីជាក្រុមនេះទទួលបានការការពារពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីអំពីសិទ្ធិរបស់បុគ្គលណាម្នាក់ដែលស្ថិតនៅក្នុងក្រុមប្រជាជាតិ ឬជាតិពន្ធុ ជាតិសាសន៍ និងសាសនាក៏ដោយ ។ សេចក្តីប្រកាសនេះត្រូវបានអនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៤៧,១៣៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២ និងមាត្រា ១ បានតម្រូវថា ៖

> «១) រដ្ឋគួរតែការពារអត្តិភាពនិងអត្តសញ្ញាណរបស់ក្រុមប្រជាជាតិ ឬជាតិពន្ធុ វប្បធម៌ សាសនា និងភាសា ឬ ក្រុមជនជាតិភាគតិចដែលនៅក្នុងព្រំដែនរបស់ខ្លួន ហើយត្រូវតែជំរុញឲ្យមានលក្ខខណ្ឌសម្រាប់លើកស្ទួយអត្តសញ្ញាណទាំងនោះ ។ ២) រដ្ឋគួរតែអនុម័តនូវច្បាប់បញ្ញត្តិសមរម្យមួយនិងវិធានការផ្សេងៗដើម្បីសម្រេចឲ្យបាននូវគោលបំណងទាំងនោះ» ។

ទោះបីជាមានអនុសញ្ញានិងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិក៏ដោយ ក៏អ្នកប្រាជ្ញ មេធាវី និងអ្នកស្រាវជ្រាវ

នៅតែយល់ឃើញថាអំពើនេះពិបាកបង្ការខ្លាំងណាស់ ។ នេះមានហេតុផលពីរ-បីដែលធ្វើឲ្យមានការពិបាកក្នុងការបង្ការអំពើនេះ ៖ ទីមួយ អំពើប្រល័យពូជសាសន៍តែងតែប្រព្រឹត្តឡើងដោយរដ្ឋប្រឆាំងទៅនឹងប្រជាជនខ្លួនឯង និងជាពិសេសទៅលើក្រុមជនជាតិភាគតិច ។ ទីពីរ ច្បាប់អន្តរជាតិបានហាមឃាត់មិនឲ្យប្រទេសមួយរំលោភបំពានអធិបតេយ្យភាពរបស់ប្រទេសមួយទៀតបានទេ ។ ដូចគ្នាទៅនឹងក្រុមជនជាតិភាគតិចជាច្រើនទៀតនៅលើសកលលោកដែរ មានមនុស្សជាច្រើនមកពីសហគមន៍ចាមបានសម្តែងនូវការមិនពេញចិត្តរបស់ខ្លួនចំពោះទង្វើនេះ ។ អ្នកទាំងនោះសំណូមពរឲ្យអង្គការសហប្រជាជាតិនិងអង្គការអន្តរជាតិផ្សេងៗចាត់វិធានការប្រយុទ្ធប្រឆាំងដើម្បីដោះស្រាយជាមួយឧក្រិដ្ឋកម្មទាំងនេះ ។ ចំពោះជនរងគ្រោះនៃអំពើបែបនេះ អ្វីដែលសំខាន់ជាងការដែលគ្រាន់តែនាំយកជនល្មើសទៅកាត់ទោស គឺអ្វីដែលប្រជាជនកម្ពុជាតែងតែនិយាយថា «ការពារប្រសើរជាងព្យាបាល» ។

## ៤) ការស្វែងយល់របស់អ្នកចូលរួមស្តីពីអំពើប្រល័យពូជសាសន៍

ដោយសារតែអតីតមេដឹកនាំខ្មែរក្រហមទាំងបួននាក់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដូចនេះគឺមានសារសំខាន់ខ្លាំងណាស់ក្នុងការផ្តល់នូវចំណេះដឹងជាមូលដ្ឋានអំពីបញ្ហានេះដល់ក្រុមជនជាតិភាគតិចផ្សេងៗដែលត្រូវបានកំណត់មុខសញ្ញាសម្លាប់ក្នុងអំឡុងរបបខ្មែរក្រហម ។ ការប្រជុំនេះ គឺជាវេទិកាមួយសម្រាប់ឲ្យអ្នកចូលរួមធ្វើការចែករំលែកនូវបទពិសោធន៍ជាមួយអ្នកដទៃអំពីប្រធានបទប្រល័យពូជសាសន៍ ។ គារាងស្ទាបស្ទង់មតិបានបង្ហាញពីការពិពណ៌នារបស់អ្នកចូលរួមស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះថាជាទម្រង់មួយនៃ «ការកម្ទេចដោយចេតនា ដើម្បីបន្ទាចសត្រូវ លុបបំបាត់ការគំរាមកំហែង និងដើម្បីទទួលបានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច» «ការបំផ្លិចបំផ្លាញ និងការសម្លាប់ដោយផ្អែកទៅលើជាតិពន្ធុ សាសនា វប្បធម៌ និងភាពជាពលរដ្ឋ» «ការសម្លាប់មិនរើសមុខ មិនថាពូជសាសន៍ ឬ ជាតិពន្ធុនោះទេ» «ការសម្លាប់ដោយកំណត់មុខសញ្ញាពូជសាសន៍ និងការបំផ្លិចបំផ្លាញ សាសនាជាតិ សេដ្ឋកិច្ច និងនយោបាយ» «ការសម្លាប់មនុស្ស ឬការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដើម្បីបំផ្លាញក្រុមមួយទាំងស្រុង» «ការសម្លាប់មនុស្ស ឬក្រុមជនជាតិភាគតិចដោយ



អ្នកចូលស្តាប់ការពន្យល់របស់វាគ្មិនបកស្រាយពីអំពើប្រល័យពូជសាសន៍ និងទស្សនាភាពយន្តឯកសារ

មិនរើសមុខ និងដោយចេតនាដើម្បីអនុវត្តន៍នូវមនោគមន៍វិជ្ជាណាមួយ» «ចេតនាក្នុងការកម្ទេចពូជសាសន៍មួយ» «ការហាមប្រាមមិនឲ្យប្រណិប័តន៍សាសនា» «ការបញ្ចូលក្រុមជនជាតិភាគតិចទាំងស្រុកទៅក្នុងសង្គម» និង «ការសម្លាប់មនុស្សតាមតែអំពើចិត្ត» ។

តារាងស្ទាបស្ទង់មតិដែលធ្វើឡើងមុនពេលចាប់ផ្តើមកិច្ចប្រជុំខាងលើនេះបានបង្ហាញពីការយល់ដឹងអំពើប្រល័យពូជសាសន៍នេះតែមួយផ្នែកតូចប៉ុណ្ណោះ ។ គួរឲ្យយល់ផងដែរ «អំពើប្រល័យពូជសាសន៍» គឺជាពាក្យមួយដែលមានភាពស្មុគស្មាញពិបាកយល់ក្នុងចំណោមមនុស្សធម្មតា ។ ប៉ុន្តែ តារាងស្ទាបស្ទង់មតិ និងបទសម្ភាសដែលធ្វើឡើងក្រោយកិច្ចប្រជុំបានបញ្ជាក់ឲ្យឃើញថា វគ្គហ៊ឹកហ៊ឺននេះពិតជាធ្វើឲ្យមាននូវការរីកចម្រើនមួយយ៉ាងខ្លាំងស្តីពីការយល់ដឹងរបស់អ្នកចូលរួមអំពីច្បាប់អន្តរជាតិ អំពើប្រល័យពូជសាសន៍ និងដំណើរការនាំយកអតីតមេដឹកនាំខ្មែរក្រហមទៅកាត់ទោស ។ ដោយឡែក មានអ្នកចូលរួមមួយចំនួនទៀត បានលើកឡើងពីការយល់ដឹងប្រសើរជាងមុនទាក់ទងនឹងអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការចោទប្រកាន់របស់សាលាក្តីខ្មែរក្រហមមកលើអតីតមេដឹកនាំខ្មែរក្រហមទាំងបួននាក់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។

លោក ស្លេះ គ្រីយ៉ា ជនជាតិចាមអាយុ៥៣ឆ្នាំមកពីខេត្តកំពង់ចាមម្នាក់ បាននិយាយថា ក្រោយពីបានស្តាប់វាគ្មិននិយាយអំពីអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ពាក្យថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាពាក្យមួយដែលសមរម្យបំផុតដើម្បីពិពណ៌នាពីចេតនារបស់ខ្មែរក្រហមក្នុងការសម្លាប់រង្គាលជនជាតិចាម ។ លោក ស្លេះ គ្រីយ៉ា បាននិយាយបន្តទៀតថា ជនជាតិចាមមានវប្បធម៌ ភាសា និងសាសនារបស់ខ្លួន ។ លោកមានបំណងបញ្ជាក់ថា ជនជាតិចាមគួរតែត្រូវបានការពារដោយសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់បុគ្គលដែលស្ថិតក្នុងក្រុមប្រជាជាតិ ឬ ជាតិពន្ធុ ជាតិសាសន៍ និងសាសនា ។ ដូចគ្នាផងដែរ លោក លីន កូប ជនជាតិចាមអាយុ៦០ឆ្នាំមកពីខេត្តក្រចេះបាននិយាយថា គាត់យល់ស្រប ហើយយល់ពីការពន្យល់និយមន័យនៃពាក្យថាប្រល័យពូជសាសន៍ ។ លោកក៏ចាំផងដែរពីបណ្តាប្រទេសដែលកើតមានអំពើប្រល័យពូជសាសន៍នៅលើសាកលលោកនេះ ។ ជាងនេះទៅទៀត លោក ហ៊ុម ម៉ាត់ ជនជាតិចាមអាយុ៥៧ឆ្នាំមកពីខេត្តកំពង់ចាមបានលើកឡើងថា ខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើទាំងជនជាតិចាម និង វៀតណាម ។

មានអ្នកចូលរួមជាច្រើនយល់ឃើញថា ការជួបប្រជុំគ្នារយៈពេលមួយថ្ងៃនេះ គឺមានប្រយោជន៍ច្រើនណាស់ ហើយមានតម្លៃទៀតផងចំពោះប្រទេសជាតិនិងការយល់ដឹងរបស់គាត់ ។ ការហ៊ឹកហ៊ឺននេះ គឺជាសារមួយផ្ញើទៅឲ្យកូនចៅរបស់គាត់ដើម្បីធ្វើការការពារប្រយុទ្ធប្រឆាំងនឹងការកើតឡើងវិញនៃអំពើប្រល័យពូជសាសន៍និងភាពឃោរឃៅផ្សេងៗ ។ ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញថាអំពើប្រល័យពូជសាសន៍តែងតែត្រូវបានប្រព្រឹត្តឡើងដោយរដ្ឋខ្លួនឯង ។ ដូចនេះ ប្រជាជនរួមទាំងក្រុមជនជាតិភាគតិចផងដែរនោះ អាចចូលរួមបង្កើតជាវិធីសាស្ត្រមួយចំនួនដើម្បីការពារការកើនឡើងនៃស្ថានភាពដែលអាចបង្កឲ្យទៅជាអំពើប្រល័យពូជសាសន៍នៅកម្ពុជាទៅថ្ងៃមុខ ។ ខាងក្រោមគឺជាការឆ្លើយតបរបស់អ្នកចូលរួមទៅនឹងវិធីសាស្ត្រក្នុងការបង្ការបទឧក្រិដ្ឋប្រល័យពូជសាសន៍ ៖



អ្នកចូលរួមប្រជុំស្តីពីអំពើប្រល័យពូជសាសន៍

◆ លោក យូ សុះ ជនជាតិចាមអាយុ ៣៨ ឆ្នាំ មកពីខេត្តសៀមរាប បាននិយាយថា «ខ្ញុំសូមសំណូមពរឲ្យយើងទាំងអស់គ្នាបង្កើតឲ្យមាននូវទំនាក់ទំនងដ៏រឹងមាំរវាងប្រទេសរបស់ខ្លួននិងប្រទេសជិតខាង» ។

◆ លោក ណេះ ម៉ាស់ ជនជាតិចាមអាយុ៦៥ឆ្នាំមកពីខេត្តកំពង់ឆ្នាំង បានរៀបរាប់ថា «យើងត្រូវតែរៀបរៀងចងក្រងជាឯកសារ និងបង្ហាត់បង្រៀនកូនចៅជំនាន់ក្រោយដើម្បីកុំឲ្យប្រព្រឹត្តទង្វើខុសឆ្គងនេះម្តងទៀត» ។

◆ លោក រី ម៉ាត់ ជនជាតិចាមអាយុ៥៨ ឆ្នាំមកពីខេត្តតាកែវ បានរៀបរាប់ថា «យើងត្រូវតែធ្វើការផ្សព្វផ្សាយឲ្យបានទូលាយនៅគ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់» ។

◆លោក លីន កូប ជនជាតិចាមអាយុ ៦០ ឆ្នាំមកពីខេត្តក្រចេះ បានរៀបរាប់ថា «មានតុលាការតាមផ្លូវច្បាប់ក៏អាចជួយទប់ស្កាត់អំពើនេះមិនឲ្យកើតឡើងវិញផងដែរ» ។

◆លោក ស្លេះ គ្រីយ៉ា ជនជាតិចាមអាយុ៥៣ឆ្នាំមកពីខេត្តកំពង់ចាម បានរៀបរាប់ថា «យើងត្រូវតែគោរពច្បាប់ទាំងច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិ» ។

◆លោកស្រី ហ៊ឹម លីម៉ៅ ជនជាតិកួយ អាយុ៤៥ ឆ្នាំមកពីខេត្តព្រះវិហារ បានរៀបរាប់ថា «ខ្ញុំជាមនុស្សធម្មតា ។ ខ្ញុំគ្មានសមត្ថភាពឯណាទៅការពារអ្វីបាននោះទេ ។ តែខ្ញុំគ្រាន់តែចង់ធ្វើការស្នើសុំដល់មេដឹកនាំប្រទេសនីមួយៗកុំឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍នេះទៀត» ។

អ្នកចូលរួមបានផ្តល់នូវបទសម្ភាសជាច្រើនដែលបង្ហាញពីបទពិសោធន៍របស់ខ្លួន ។ ដូចជាករណី អ៊ីប្រុស ស្លេះ គ្រីយ៉ា យោបល់របស់គាត់គឺពាក់ព័ន្ធទៅនឹងតម្រូវការចង់ឲ្យប្រទេសជិតខាងលូកដៃដើម្បីជួយបញ្ឈប់អំពើប្រល័យពូជសាសន៍ ។ ឧទាហរណ៍នៅក្នុងឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តជនជាតិវៀតណាមបានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបញ្ចប់រយៈកាលនៃអំពើព្រៃផ្សៃយង់ឃ្នងដែលបណ្តាលឲ្យមនុស្សស្លាប់ជាងពីរលាននាក់ ។ ដើម្បីឆ្លើយតបទៅនឹងការអះអាងដែលតែងតែលើកឡើងថា ព័ត៌មានស្តីពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា គឺមានលក្ខណៈខ្វះខាតណាស់ ហើយពិភពខាងក្រៅបានដឹងតិចតួចបំផុតអំពីព្រឹត្តិការណ៍នៅប្រទេសកម្ពុជាដែលកើតឡើងក្នុងពេលនោះ ។ អ៊ីប្រុស រី ម៉ាត់ ជឿជាក់ថាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាមធ្យោបាយដ៏មានប្រយោជន៍មួយដើម្បីធ្វើឲ្យសហគមន៍អន្តរជាតិបានដឹងអំពីអ្វីដែលបានកើតឡើងនៅក្នុងសហគមន៍ឬប្រទេសណាមួយ ។ ជាងនេះទៅទៀត ពិភពខាងក្រៅគួរតែសកម្មនិងមានការឆ្លើយតបលឿនជាងនេះក្នុងការស៊ើបអង្កេតអំពើមនុស្សឃាតផ្សេងៗ ។ អ្នកចូលរួមភាគច្រើនបានយល់ស្របយ៉ាងខ្លាំងថាការប្រឆាំងនឹងមេក្លោងនៃអំពើប្រល័យពូជសាសន៍គឺតាមរយៈយុត្តិធម៌ផ្លូវច្បាប់ ដូចអ្វីដែលបានមើលឃើញនៅសាលាក្តីខ្មែរក្រហម និងតុលាការអន្តរជាតិផ្សេងៗ ។

## ៥) សារសំខាន់នៃការពិតនិងយុត្តិធម៌

ការលាតត្រដាងនូវការពិតឲ្យកាន់តែធំទូលាយ គឺជាមូលហេតុចម្បងមួយដែលការប្រជុំនេះចង់ឲ្យអ្នកចូលរួមទាំងអស់ចូលរួមយ៉ាងសកម្ម ហើយបន្ទាប់ពីបានស្តាប់ពុការធ្វើបទបង្ហាញពីសំណាក់អ្នកជំនាញរួចមក អ្នកចូលរួមជនជាតិចាមជាច្រើនបានក្រោកឈរឡើងធ្វើការចែករំលែកនូវរឿងរ៉ាវផ្ទាល់ខ្លួន ក៏ដូចជាធ្វើការភ្ជាប់នូវបទពិសោធន៍របស់ខ្លួនទៅនឹងសំណួរដែលនឹងសួរនោះ ។ អ្នកចូលរួមជនជាតិខ្មែរក្រោមមួយចំនួនតូចមានឱកាសធ្វើការលើកឡើងនូវភាពធ្ងន់ធ្ងរនៃការសម្លាប់របស់ខ្មែរក្រហមនៅខេត្តពោធិ៍សាត់ និងទីកន្លែងផ្សេងទៀត ។ កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីសម្រួលដល់ការនិយាយរឿងរ៉ាវប្រាប់គ្នាទៅវិញទៅមក និងបង្កើតបរិយាកាសមួយដែលធ្វើឲ្យរឿងរ៉ាវដែលអ្នកចូលរួមបាននិយាយត្រូវបានស្តាប់ពុនិងទទួលស្គាល់ ។ លោក ស្វាយ ភឿន អាយុ៦០ឆ្នាំ មកពីខេត្តក្រចេះបាននិយាយថា ការប្រជុំនេះបានផ្តល់នូវការចងចាំដ៏ល្អមួយ ។ ខ្សែភាពយន្តដែលមានចំណងជើងថា «ឃ្លាតទៅសែនឆ្ងាយ» ពិតជាដូចរឿងខ្ញុំមែនទែន ។ អ្វីដែលសំខាន់នោះគឺថា ការប្រជុំនេះធ្វើឲ្យយុវជនស្វែងយល់និងជឿជាក់ទៅលើព្រឹត្តិការណ៍ពិតប្រាកដដែលបង្កឲ្យមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ។

ទាំងក្នុងបទសម្ភាសន៍និងតារាងស្ទាបស្ទង់មតិសំណូមពរមួយដែលអ្នកចូលរួមមានដូចគ្នានោះគឺ ចង់ឲ្យពន្លឿនការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោក រូន លាស់ មកពីខេត្តកំពង់ឆ្នាំង

បាននិយាយថាគាត់សូមអំពាវនាវឲ្យសាលាក្តីខ្មែរក្រហមធ្វើការកាត់ទោសអតីតមេដឹកនាំទាំងនោះឲ្យលឿនតាមដែលអាចធ្វើទៅបាន ។ លោក យូ សុះ អាយុ៣៨ឆ្នាំ មកពីខេត្តសៀមរាប បានលើកឡើងបន្តថា អ្វីដែលគាត់រំពឹងចង់ស្តាប់ឮនូវការពិតពីមាត់របស់អតីតមេដឹកនាំទាំងនោះគឺថា «ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សហើយមានបំណងអ្វី?» បន្ថែមលើនេះទៀត អ៊ីប្រុស ក៏បានសង្កត់ធ្ងន់លើសារសំខាន់នៃការលាតត្រដាងនូវចេតនាពិតប្រាកដរបស់មេដឹកនាំទាំងនោះ ។ លោក ហាប់ សុះ អាយុ៦៦ឆ្នាំ មកពីខេត្តកណ្តាលបាននិយាយថា ប្រសិនបើមេដឹកនាំទាំងនោះចង្អុលបង្ហាញមួយដ៏ជាក់លាក់ដល់យុវជនស្តីអំពីភាពឃោរឃៅរបស់ខ្មែរក្រហម ជាពិសេស អំពើប្រល័យពូជសាសន៍មកលើជនជាតិចាមនិងវៀតណាម ។ គេរំពឹងទុកថាការពិតដែលចេញពីសាលាក្តីខ្មែរក្រហមនេះនឹងធ្វើឲ្យប្រជាជន ក៏ដូចជាជនជាតិភាគតិចបានទទួលការព្យាបាលនិងការផ្សះផ្សាមួយកម្រិត ។

## ៦) សេចក្តីបញ្ចប់

អ្នកដែលចូលរួមទាំងអស់យល់ឃើញថា ការប្រជុំនេះគឺមានប្រយោជន៍ណាស់ ។ ជាពិសេស ពួកគាត់បានទទួលនូវការយល់ដឹងច្បាស់ជាងមុនទាក់ទងទៅនឹងទ្រឹស្តីនៃពាក្យប្រល័យពូជសាសន៍




អ្នកភូមិសួរសំណួរទៅវាគ្មិន

ស្លាប់ នោះយើងមិនអាចរកឃើញ «សន្និងខ្មៅ» នៃអំពើប្រល័យពូជសាសន៍បានឡើយ ។

អស់រយៈពេលជាង៣០ឆ្នាំមកហើយបន្ទាប់ពីរបបខ្មែរក្រហមនេះបានដួលរលំ ឌុច គឺជាមនុស្សទីមួយដែលត្រូវបានយកមកកាត់ទោសនៅសាលាក្តីខ្មែរក្រហម ។ យុវសិស្ស ម៉ៃ រស់ ជាសិស្សថ្នាក់ទី៩ មកពីខេត្តកំពង់ឆ្នាំងបាននិយាយថា ខ្លួនពេញចិត្តសាលក្រម ឌុច ដែលកាត់ទោសឲ្យគាត់ជាប់គុករយៈពេល៣៥ឆ្នាំ ។ នេះគឺច្បាស់លាស់ណាស់ដែលថា សាលាក្តីនេះនឹងបម្រើការតាមរយៈការពន្យល់ដ៏លម្អិតរបស់អ្នកជំនាញ ។ បទបង្ហាញបន្ទាប់ទៀតគឺផ្តោតសំខាន់ទៅលើប្រវត្តិនៃពាក្យប្រល័យពូជសាសន៍ថាអំពើនេះកើតឡើងនៅក្នុងបរិបទសកលលោក ក៏ដូចជាការទទួលស្គាល់ថាអំពើនេះជាឧក្រិដ្ឋកម្មអន្តរជាតិ ។ អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ បានការពារក្រុម «ជនជាតិ ជាតិពន្ធុ ពូជសាសន៍ និងសាសនា» មិនឲ្យទទួលរងការបំផ្លិចបំផ្លាញដោយផ្នែក ឬទាំងស្រុង ។ យោងទៅតាមការយល់ឃើញរបស់អ្នកចូលរួម ភាគច្រើនមានយោបល់ថា

ការបង្ការអំពើប្រល័យពូជសាសន៍អាចធ្វើឡើងតាមរយៈអន្តរាគមន៍ពីសំណាក់រដ្ឋនីមួយៗ ការផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយ និងយន្តការផ្លូវច្បាប់មួយក្នុងការកាត់ទោសមេក្លោងនៃអំពើប្រល័យពូជសាសន៍នេះ ។ អ្នកចូលរួមមានការស្វែងយល់អំពីនីតិវិធីច្បាប់ខ្លះៗជុំវិញបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានចោទប្រកាន់មកលើអតីតមេដឹកនាំខ្មែរក្រហមទាំងបួនរូបនៅសាលាក្តីខ្មែរក្រហម ។

គួរឲ្យកត់សម្គាល់ដែរថា ក្រុមជនជាតិភាគតិចចាមនិងវៀតណាម ត្រូវបានចាត់ចូលជាក្រុមជនជាតិភាគតិចក្នុងចំណោមជនជាតិភាគតិចជាច្រើនក្រុមផ្សេងទៀត ដែលទទួលបានការការពារពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់បុគ្គលដែលស្ថិតក្នុងក្រុមប្រជាជាតិ ឬជាតិពន្ធុ ជាតិសាសន៍ និងសាសនា ។ ដោយសារអង្គហេតុនេះហើយ ជនរងគ្រោះទាមទារឲ្យមានការពិតជាងនេះ ទាក់ទងទៅនឹងការឈឺចាប់និងបាត់បង់អ្នកជាទីស្រឡាញ់កាលពីអតីតកាលរបស់គាត់នៅក្នុងរបបខ្មែរក្រហមនោះ ។ ក្រៅពីការពិតដែលត្រូវបានលាតត្រដាងនៅក្នុងសវនាការរបស់សាលាក្តីខ្មែរក្រហម យ៉ាងហោចណាស់គួរតែអាចផ្តល់នូវការពិតជាផ្លូវការនិងសាធារណៈអំពីការសម្លាប់រង្គាលនេះ ។

ជាពិសេសទៅទៀត ការប្រជុំនេះក៏ជួយឲ្យក្រុមជនជាតិភាគតិចយល់ដឹងពីគ្នាទៅវិញទៅមក ។ នេះគឺបានបើកផ្លូវឲ្យមានការយល់ចិត្តនិងភាពសុខដុមកើតមានឡើងនៅក្នុងចំណោមក្រុមនីមួយៗ ។ អ្នកចូលរួមបានសន្យាថានឹងធ្វើការចែករំលែកនូវការយល់ដឹងរបស់ខ្លួនទៅឲ្យក្រុមគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់គាត់ ។ អ្នកចូលរួមយល់ឃើញថា ការនិយាយពីបទពិសោធន៍ផ្លូវចត់ចេញមកក្រៅ ធ្វើឲ្យគាត់មានអារម្មណ៍ឈឺចាប់នៅថ្ងៃនេះ ប៉ុន្តែដើម្បីប្តូរមកនូវការធូរស្បើយនៅថ្ងៃក្រោយ ។

ទោះបីជាកិច្ចប្រជុំនេះបានសម្រេចនូវគោលបំណងរបស់ខ្លួនក៏ដោយ ក៏យើងនៅតែជួបការលំបាកមួយចំនួនដដែល ។ យើងទទួលស្គាល់ថា ការប្រជុំរយៈពេលមួយថ្ងៃនេះគ្រាន់តែអាចផ្តល់នូវការយល់ដឹងតិចតួចប៉ុណ្ណោះទាក់ទងនឹងអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ យន្តការផ្លូវច្បាប់ និងពាក្យច្បាប់ផ្សេងៗ ។ បន្ថែមពីនេះទៅទៀត ដោយសារតែចំនួនបុរសមកចូលរួមច្រើនជាងស្ត្រី ធ្វើឲ្យបុរសបានទទួលនូវផលប្រយោជន៍ច្រើនជាងពីកម្មវិធីនេះ ។ នេះគឺមិនមែនជាការភ្ញាក់ផ្អើលអ្វីនោះទេ ដោយសារតែបុរសៗដែលចូលរួមទាំងនោះគឺជាមេដឹកនាំសាសនានិងសហគមន៍ ។ ស្ត្រីមានសារសំខាន់នៅក្នុងការអប់រំកូនចៅពីអំពើប្រល័យពូជសាសន៍ និងជាពិសេសការយល់ឃើញរបស់ស្ត្រី ។ កិច្ចខិតខំប្រឹងប្រែងនេះក៏អះអាងផងដែរថា បទពិសោធន៍ និងការតស៊ូរបស់ស្ត្រីនៅក្នុងអំឡុងរបបខ្មែរក្រហមត្រូវបានទទួលស្គាល់ស្មើគ្នា ។ គម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើននូវការចូលរួមរបស់ស្ត្រីច្រើនជាងមុននៅក្នុងការប្រជុំលើកទីពីរនេះ ដែលក្នុងមានស្ត្រីជនជាតិភាគតិចប្រហែលជា៦០នាក់ត្រូវបានអញ្ជើញមកចូលរួម ។

ជាងនេះទៅទៀត អ្នកចូលរួមភាគច្រើនបានស្នើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការរៀបចំនូវការប្រជុំបន្តបន្ទាប់ទៀតដូចដែលបានបង្ហាញនៅក្នុងតារាងស្ទាបស្ទង់មតិនិងបទសម្ភាស ។ ក្រៅពីតម្រូវការទាំងនេះ យើងយល់ឃើញថាឯកសារដែលបានចែកជូននោះគឺអាចជួយផ្តល់នូវការយល់ដឹងឲ្យពួកគាត់កាន់តែប្រសើរឡើងទាក់ទងនឹងដំណើរការនីតិវិធីច្បាប់នៅសាលាក្តីខ្មែរក្រហម និងចោទបទពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកលើអតីតមេដឹកនាំទាំងបួនរូប ។ ទាក់ទងនឹងចំណុចនេះ អ្នកចូលរួមទទួលបាននូវឯកសារមួយកញ្ចប់ដែលមានឯកសារដូចជា : «សៀវភៅសាលក្រម ឌុច» ទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អត្ថបទសង្ខេបរបស់លោក វីលៀម សាបាស់ និងបទបង្ហាញរបស់វាគ្មិនជាភាសាខ្មែរ ។

ក្រុមការងាររបស់គម្រោងក៏ទទួលបាននូវការស្នើសុំជាលាយលក្ខណ៍អក្សរនូវសៀវភៅមេរៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអ្នកតំណាងជនជាតិចាមម្នាក់មកពីស្រុកឆ្លូង ខេត្តក្រចេះ ។ អ្នកតំណាងរូបនេះធ្វើការស្នើសុំនូវឯកសារទាំងនេះដើម្បីយកទៅឲ្យកូនសិស្សរបស់គាត់ ។ អ្នកចូលរួមខ្លះទៀតបានប្រគល់នូវស្ថិតិភូមិ រូបថត វិហារ និងប្រវត្តិវិហារក្នុងស្រុកភូមិរបស់គាត់ឲ្យទៅប្រធានគម្រោងប្រវត្តិសាស្ត្រដើម្បីឲ្យធ្វើការចុះផ្សាយនៅលើគេហទំព័រ ។ **លី សុខឃាង**

# អង្គហេតុពិត : ប៉ុល ពត និងអ្នកទោសនៅមន្ទីរ ស-២១

ដោយសារចំហាយក្លិនសាច់សាកសពដែលស្អុយរលួយ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានធ្វើដំណើរទៅកាន់កន្លែងមួយដែលហ៊ុមព័ទ្ធទៅដោយខ្សែលួសបន្លា ដែលជាមន្ទីរសន្តិសុខជាន់ខ្ពស់បំផុតរបស់របបខ្មែរក្រហម ។ នៅឯមន្ទីរសន្តិសុខមួយដែលមានលេខកូដ ស-២១ : «ស» មានន័យថា សន្តិបាល ហើយនៅក្នុងភាសាខ្មែរមានន័យថា «អង្គភាពការពារសន្តិសុខរបស់ប្រទេស» និង «២១» គឺជាលេខអាយកូមរបស់អតីតប្រធានគុកដែលមានឈ្មោះថា (ណាត) អ្នកទោសត្រូវបាននាំទៅថតរូប សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ទាំងជាប់ចំណងខ្នោះ ។


ប៉ុល ពត

អ្នកទោសភាគច្រើនដែលបានបញ្ជូនទៅមន្ទីរស-២១គឺជាកម្មាភិបាលខ្មែរក្រហម រួមទាំងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនដូចជារដ្ឋមន្ត្រី និងសាច់ញាតិរបស់ខ្លួន ។ អ្នកទោសទាំងនោះត្រូវបានចោទប្រកាន់ថា ចូលដៃជើងជាមួយរដ្ឋាភិបាលបរទេស ដោយស៊ើបការណ៍ដើម្បីបម្រើឲ្យចលនា សេ.អ៊ី.អា និងកា.ហ្សេ.បេ និងជាពិសេសនោះគឺថា អ្នកទោសទាំងនោះត្រូវបានចោទថាក្បត់នឹងអង្គការ ។ ខ្មែរក្រហមជឿជាក់ថា អ្នកទោសទាំងនោះបានរួមគំនិតជាមួយអ្នកផ្សេងទៀត ដូចច្នេះអ្នកទោសទាំងអស់ត្រូវបានបង្ខំឲ្យលាតត្រដាងពី «ខ្សែក្បត់» ដែលជួនកាលមានរហូតដល់ទៅរាប់រយនាក់ឯណោះ ។

អ្នកសួរចម្លើយបានប្រើប្រាស់វិធីសាស្ត្រសួរចម្លើយ ដោយអនុលោមតាមវិន័យសន្តិបាលទាំងដប់ដែលក្នុងនោះរួមមាន «វាយ ប្អូនក់ខ្សែភ្លើងមិនឲ្យស្រែកដាច់ខាត» ។ ទោះបីជាអ្នកទោសមិនដឹងថាខ្លួនត្រូវបានចាប់ដោយមូលហេតុអ្វីក៏ដោយ ក៏អ្នកសួរចម្លើយនៅតែបង្ខំអ្នកទាំងនោះឲ្យសារភាពពីកំហុសដែលបានប្រព្រឹត្តដែរ ។ ប្រសិនបើអ្នកទោសមិនព្រមសារភាព នោះនឹងត្រូវទទួលទារុណកម្ម ។ ប៉ុន្តែ បន្ទាប់ពីសារភាពរួច អ្នកទោសទាំងនោះនឹងត្រូវយកទៅសម្លាប់ ។ នៅដំណាក់ដំបូង អ្នកទោសត្រូវបានសម្លាប់នៅក្នុងបរិវេណមន្ទីរ ស-២១ ប៉ុន្តែដោយសារសាកសពមានចំនួនកាន់តែច្រើន និងមានក្លិនស្អុយរលួយកាន់តែខ្លាំងឡើងៗ មិនអាចទ្រាំទ្របាន អ្នកទោសទាំងអស់ត្រូវបានដឹកតាមរថយន្តទ្រុងធំៗទៅកាន់ទីវាលមួយដែលមានចម្ងាយប្រមាណជា១៥គីឡូម៉ែត្រដែលមានឈ្មោះថា «បឹងជើងឯក» ដើម្បីសម្លាប់ចោល ។ ពេជ្ឈឃាតមួយក្រុមដែលមានគ្នាចំនួន១០នាក់ដឹកនាំដោយ គេង រង់ចាំនៅទីនោះរួចជាស្រេច ។ គេង មានអាយុប្រហែលជាម្ភៃឆ្នាំជាង ហើយសមាជិកក្នុងក្រុមរបស់ គេង គឺជាក្មេងជំទង់ៗដែលរស់នៅក្នុងផ្ទះមួយមានកម្ពស់ពីរជាន់សង់ក្នុងឆ្នាំ១៩៧៧ នៅជិតវាលជើងឯក ។ ក្រុមពេជ្ឈឃាតទាំងអស់នោះត្រូវបានជូនដំណឹងជាមុនរួចជាស្រេចអំពីចំនួនអ្នកទោសដែលនឹងត្រូវបញ្ជូនទៅ ដូច្នេះក្រុមរបស់ គេង បានជីករណ្តៅរួចជាស្រេចដើម្បីត្រៀមកប់សាកសព ។ អតីតឆ្មាំគុកស-២១ ហ៊ឹម ហ៊ុយ បាននិយាយថា គេង ហើយនិងក្រុមរបស់ខ្លួនគឺជាអ្នកសម្លាប់អ្នកទោសពេលមកដល់ភ្លាម ។

គុកទួលស្លែង ឬ ស-២១ ដែលមានទីតាំងនៅរាជធានីភ្នំពេញនៃប្រទេសកម្ពុជាគឺជាកន្លែងដែលពោរពេញដោយភាពតក់ស្លុត ភាពសង្ស័យដ៏ឆ្កួតលីលា និងអំពើសាហាវឃោរឃៅដែលកើតឡើងពេញផ្ទៃប្រទេសក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ គុក ស-២១ គឺជាគុកមួយក្នុងចំណោមគុកចំនួន១៩៦ ដែលកើតឡើងកាលជំនាន់នោះ ទោះបីជាខ្មែរក្រហមអះអាងថា កាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យមិនមានគុកជាផ្លូវការក៏ដោយ ។ ចំនួនទូរលេខនៃអ្នកស្លាប់ប្រហែលជា១៨.០០០នាក់ និងអ្នករួចរស់ជីវិត ចំនួនប្រាំពីរនាក់បានធ្វើឲ្យគុកនេះក្លាយជាកន្លែងដ៏គ្រោះថ្នាក់ជាងគេមួយប្រចាំសតវត្សរ៍ទី២០នេះ ។ ទោះបីជាយ៉ាងនេះក៏ដោយ អ្នកជំនាញនិងបញ្ញវន្តជាច្រើននៅតែមិនយល់ស្របគ្នាចំពោះចំនួនទាំងនេះនៅឡើយទេ ។ នៅពេលថ្មីៗនេះ សាលាក្តីខ្មែរក្រហមដែលជាតុលាការកូនកាត់បានបង្កើតចំនួនថ្មីរបស់ខ្លួន ដោយផ្អែកទៅលើសំណុំរឿងព្រហ្មទណ្ឌរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរស-២១ ។

ចំនួនអ្នកទោសដែលត្រូវបញ្ជូនទៅស-២១ មានចំនួនចាប់ពី១២.២៧៣នាក់ ដែលប៉ាន់ប្រមាណដោយតុលាការ រហូតដល់ប្រមាណ២ម៉ឺននាក់ ដែលជាចំនួនប៉ាន់ប្រមាណរបស់អ្នកជំនាញមួយចំនួន ។ ចំនួនអ្នកនៅរស់ក៏មិនបានឆ្លងកាត់ការស្រាវជ្រាវច្រើនដែរ ប៉ុន្តែសារព័ត៌មានរបស់បស្ចិមប្រទេសបានយល់ស្របថាមានអ្នកនៅរស់មានចំនួនប្រាំពីរនាក់ ។ ចំនួនអ្នកនៅរស់ប្រាំពីរនាក់នេះ ត្រូវបានប្រើប្រាស់ជាងសាបសិបឆ្នាំមកហើយ ដែលធ្វើឲ្យស-២១ ត្រូវបានមើលឃើញថាជាកន្លែងដ៏សាហាវ ។ ចំនួននេះត្រូវបានគេរកឃើញតាមរយៈខ្សែភាពយន្តផលិតឆ្នាំ១៩៨១ ដែលមានចំណងជើងថា «អន្តការ» ដែលផលិតដោយ Studio H&S របស់អាល្លឺម៉ង់ខាងជើង ។ នៅក្នុងខ្សែភាពយន្ត មានការបង្ហាញរូបថតអ្នកនៅរស់ពីស-២១ ទាំងប្រាំពីរនាក់ ។ រូបថតនេះក៏បានបង្ហាញនៅក្នុងស្នាដៃស្រាវជ្រាវមួយចំនួនដែរ ដូចជាសៀវភៅមួយក្បាលបោះពុម្ពនៅឆ្នាំ១៩៩៨ មានចំណងជើងថា «*A Cambodian Prison Portrait: One Year in the Khmer Rouge´s S-21*» សរសេរដោយអតីតអ្នករស់រានមានជីវិតម្នាក់ គឺ វ៉ាន់ ណាត ដែលផ្តល់ប្រភពព័ត៌មានដ៏សំខាន់មួយសម្រាប់អ្នកសិក្សាស្រាវជ្រាវនិងអ្នកជំនាញ ។ មានការយល់ឃើញខ្លះៗថា ចំនួនប្រាំពីរនាក់ដែលត្រូវបានបង្ហាញនោះគឺដើម្បីសម្របទៅតាមថ្ងៃទី៧ ខែមករា ដែលជា «ថ្ងៃជ័យជម្នះ» ដែលវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហម ។

ប៉ុន្តែ ឆ្លងតាមការស្រាវជ្រាវជាច្រើនឆ្នាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថា យ៉ាងហោចណាស់ក៏មានអ្នកទោសចំនួន១៧៩នាក់ដែរ ដែលត្រូវបានដោះលែងក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ និងមានអ្នកនៅរស់ប្រហែលជា២៣នាក់ បន្ទាប់ពីវៀតណាមផ្តួលរំលំខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

លក្ខន្តិកៈដោះលែងអ្នកទោសចំនួន១៧៩នាក់ (ក្នុងនោះ ១០០នាក់ ជាទាហាន) គឺផ្អែកទៅលើបទសម្ភាសន៍និងឯកសារខ្មែរក្រហមដ៏ច្រើនសន្ធឹកសន្ធាប់ដែលចងក្រងដោយអ្នករក្សាបណ្ណសារជាន់ខ្ពស់នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង យិន នាន ។ ភាគច្រើននៃអ្នកដែលបានដោះលែងទាំង១៧៩នាក់បានបាត់ខ្លួន ហើយមានចំនួនតិចតួចប៉ុណ្ណោះដែលនៅរស់ក្រោយឆ្នាំ១៩៧៩ ។ រីឯក្នុងចំណោមអ្នកនៅរស់ទាំង២៣នាក់ក្រោយឆ្នាំ១៩៧៩ ច្រើនជាងពាក់កណ្តាលនៃអ្នកទាំងនោះបានបាត់ខ្លួន ឬក៏ស្លាប់ ។ អ្នកនៅរស់មួយចំនួនដែលនៅរស់រហូតដល់សព្វថ្ងៃបានធ្វើឲ្យដំណឹងនេះកាន់តែរីកសុសសាយឡើងគឺ : នង ចាន់ផល សាក្សីនៅក្នុងសំណុំរឿង០០១ នៅសាលាក្តីខ្មែរក្រហម វ៉ាន់ ណាត និង ជុំ ម៉ី បានថតនៅក្នុងខ្សែភាពយន្តឯកសារ និង ប៊ូ ម៉េង ត្រូវបានសរសេរនិងបោះពុម្ពជាសៀវភៅរៀបរាប់ពីប្រវត្តិរបស់គាត់ ។

ជាងនេះទៅទៀត អ្នកនៅរស់ពីមន្ទីរស-២១ ម្នាក់កំពុងដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ក្នុងសាលាក្តីខ្មែរក្រហម ។

ឈ្មោះមួយចំនួនខាងក្រោម (នាមត្រកូលមុន) គឺជាកំណត់ត្រាថ្មីៗបំផុតអំពីឈ្មោះរបស់អ្នកនៅរស់ពីមន្ទីរស-២១ ដែលត្រូវបានដោះលែងមុនឆ្នាំ១៩៧៩ និងអ្នកដែលនៅរស់បន្ទាប់ពីវៀតណាមចូលមកដល់ប្រទេសកម្ពុជា ។ ឈ្មោះក្រៅ ឬឈ្មោះផ្សេងទៀតត្រូវបានដាក់ក្នុងវង់ក្រចកប្រសិនបើមាន ។

**ក្មេងនៅរស់ដែលរកឃើញដោយទាហានវៀតណាមនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩**

១) មករា (មិនស្គាល់ឈ្មោះពេញ)

២) មិនស្គាល់ឈ្មោះ (ទារកម្នាក់នេះស្លាប់ដោយហេវហត់ក្រោយកងទ័ពវៀតណាមមកដល់)

៣) នង ចាន់លី (នៅរស់)

៤) នង ចាន់ផល (សាក្សីក្នុងករណី០០១)

៥) សុជាតិ (មិនស្គាល់ឈ្មោះពេញ)

**អ្នកនៅរស់ពីរបបខ្មែរក្រហមដែលនៅរស់សព្វថ្ងៃ**

៦) ប៊ូ ម៉េង

៧) ជុំ ម៉ាញ (ជុំ ម៉ី)

៨) ហេង ណាត (វ៉ាន់ ណាត)

៩) ញ៉ែម សល់

១០) គួច តែម

**អ្នកនៅរស់ពីរបបខ្មែរក្រហម ប៉ុន្តែស្លាប់បន្ទាប់ពីឆ្នាំ១៩៧៩**

១១) អៀម ចាន់

១២) ផាន់ ថនចាន់

១៣) រុយ នាគង់

១៤) អ៊ឹង ប៉ិច

**អ្នកនៅរស់ពីរបបខ្មែរក្រហមប៉ុន្តែបានបាត់ខ្លួន (សាក្សីបានរាយការណ៍ថាបុរសទាំងនេះនៅរស់ក្រោយឆ្នាំ១៩៧៩ ប៉ុន្តែបានបាត់ខ្លួនចាប់ពីពេលនោះមក)**

១៥) ឌី ជុន

១៦) អេង (មិនស្គាល់ឈ្មោះពេញ)

១៧) ឡេង (មិនស្គាល់ឈ្មោះពេញ)

១៨) ម៉ុក សុនខុន

១៩) ប៉ុល ទូច

២០) ឆួន (មិនស្គាល់ឈ្មោះពេញ)

**អ្នកនៅរស់ដែលត្រូវបានគិតថានៅរស់ ប៉ុន្តែមិនដឹងស្ថានភាពច្បាស់លាស់**

២១) មិនស្គាល់ឈ្មោះ (ប្រហែលរស់នៅខេត្តរតនគិរី)

២២) កៀច ឃឿន

២៣) សុខ សុផាត

**អ្នកទោស (យោធាខ្មែរក្រហមក្នុងកងពលលេខ៩២០) ត្រូវបានដោះលែងរវាងឆ្នាំ១៩៧៥និង១៩៧៨ មុនពេលវៀតណាមចូលមកកម្ពុជា (អ្នកទាំងនោះបានបាត់ខ្លួនរហូតមក) ព័ត៌មានទាក់ទងនឹងអ្នកទោសទាំងនេះ មាននៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា**

២៤) បូ បឿន (ផល)

២៥) ចាន់ ចន

២៦) ចាន់ ឈឿន (ថន)

២៧) ជា វ៉ា (តូ)

២៨) ឆាយ សី

២៩) ឈឹម ហ៊ុន (សី)

៣០) ឈឿង សឿង

៣១) ឈុំ ប៊ិន

៣២) ឈុំ ថន (ជាតិ)

៣៣) ជិន សេងអ៊ាម (វ័រ)

៣៤) ជុំ ចាន់ (ខែម)

៣៥) ជុំ ម៉ុំ (វ៉ឺន)

៣៦) ដួប ម៉េងអួរ (ចេវ)

៣៧) ដួន ស្រី

៣៨) ឌី ឌុន (វី)

៣៩) ឌឹប ថូ (រីន)

៤០) ឌៀប ផន

៤១) ឌួង ឆេងប៉ាត (រិត)

៤២) ដួង សំបាត់ (ជុំ)

៤៣) អ៊ាន ហុន (ហាក់)

៤៤) ហៃ រុន (រិន)

៤៥) ហាម ចឹម (ខុម)

៤៦) ហង់ ហាន់ (ហួន)

៤៧) ហង់ ឡាយ









241


17-5-78


320




85


220




78


40

៤៨) ហែម មួន (មូន)
៤៩) ហេង រួន
៥០) ហេង (នា)
៥១) ហ៊ីង មួន (វុធ)
៥២) ហូ ដាន (ដាត)
៥៣) ហ៊ុន អ៊ុយ (ជឿម)
៥៤) ហួន សំដៃ (មួន)
៥៥) ហួត សុក (សុខា)
៥៦) អ៊ឹម បឿន (លី)
៥៧) អ៊ិត អូន
៥៨) កែវ ឡុញ (រ៉េត)
៥៩) ខឹម ស៊ាមមួយ (ពៅ)
៦០) ឃួន តៃអេង (ឡួន)
៦១) ឃុត ក្រូច
៦២) គីម ឡេង (ហេង)
៦៣) ឡាច សោម
៦៤) ឡាច សារុន (វ៉ាន)
៦៥) លឹម អួង (រិន)
៦៦) ឡុំ លន់
៦៧) ម៉ាក់ ធឿន (ថុន)
៦៨) ម៉ម រិន (បុល)
៦៩) មាស ឡាន (លឿន)
៧០) មាស នឿន (ថែង)
៧១) មាស សែត
៧២) មឿន ចិន
៧៣) មៀច ដុន (ដល)
៧៤) នៅ ណន (អុល)
៧៥) ញ៉ែម ឆុន
៧៦) ណឹម ណែម (ស៊ុម)
៧៧) ណុក ណន (ណែម)
៧៨) នូ ឈឿន (សិត)
៧៩) នៅ សំនៀង (វ៉ាន់)
៨០) អឿ ផាត (រឿន)
៨១) បក្ស ធៀវ (ថុន)
៨២) ប៉ាន់ គង់
៨៣) ប៉ាត់ ហ៊ី (យ៉ាង)
៨៤) ពេជ សោម
៨៥) ប៉ែន គាក់ (វ៉ាន់)
៨៦) ផល ញឿន (ខន)
៨៧) ភោគ សាំ (ស៊ុម)
៨៨) ផុន ស៊ុន (ស្រ៊ុន)
៨៩) ពាន់ ពិន
៩០) ប្រាក់ សំណាង (ទេព)
៩១) ព្រឹក ឆុន (វ៉ុង)
៩២) ព្រំ អន (វ៉ៃ)
៩៣) ព្រំ លាប (យន)
៩៤) សំ ម៉ក់ (រិន)
៩៥) សំ រិទ្ធ (ហង់)
៩៦) សំ ម៉ាប់ (ម៉ា)
៩៧) សេង ហ៊ុន (ហាត)
៩៨) សេង យ៉ន (អឿន)
៩៩) សៀក អេន (ក្រេន)
១០០) សោម ផុន (ណាន)
១០១) សឹង ថា (វ៉ន)
១០២) ស្រី យុន (ស្តើង)
១០៣) សួន អឿន (ដែរ)
១០៤) សួស វ៉ាម (ភាព)
១០៥) ស៊ុយ អាត
១០៦) ស៊ុយ គីមសាត (សាន)
១០៧) ស៊ុយ ថន (ស៊ុម)
១០៨) ស្វាយ កិញ (ឡា)
១០៩) តែ ណា (ធី)
១១០) ទេព សារី (វ៉ន)
១១១) ថាប់ រួន





១១២) ធី ថន
១១៣) ថ្វាង រិន (រុំ)
១១៤) អុក វ៉ាន់
១១៥) អ៊ុម វីរ (ឃី)
១១៦) អ៊ុន សៅ (សែន)
១១៧) វ៉ាន់ ង៉ូវ (ប៉ន)
១១៨) វ៉ែន ចំរើន (យ៉េន)
១១៩) យ៉ាន យឹន
១២០) យ៉ង់ ខេ (សៀង)
១២១) យ៉ែម យឿន
១២២) យូ ហាន់ (ដល)
១២៣) យុ ម៉ុន

**អ្នកទោសដែលត្រូវបានដោះលែងពីឆ្នាំ១៩៧៥ ដល់១៩៧៨ មុនវៀតណាមចូលមកដល់ប្រទេសកម្ពុជា (ចំនួនតិចតួចប៉ុណ្ណោះដែលអាចនៅរស់រានមានជីវិត ភាគច្រើនបានបាត់ខ្លួនមិនដឹងនៅទីណា)**

១២៤) បេង ពុំ
១២៥) ប៉ូ ផនលី
១២៦) បេង ស្រ៊ិន
១២៧) ឈាន វ៉ុក
១២៨) ឈាង ប៊ុច
១២៩) ឈាង ប្រាំង
១៣០) ឆែម ចន
១៣១) ឈៀវ ស៊ុនហេង
១៣២) ឈឹម ប៉ូច
១៣៣) ដូ ព្រិន
១៣៤) ដៃ ប៉េង
១៣៥) អ៊ា ឆៃប៉ូវ
១៣៦) អ៊ា ហ៊ា
១៣៧) អ៊ា កុក
១៣៨) ហន ញ៉ូវ
១៣៩) ហែម សម្បត្តិ
១៤០) ហ៊ិន ជី
១៤១) ហ៊ុង ជិន
១៤២) អ៊ិក ឆេងអ៊ាង
១៤៣) អ៊ឹម ផល
១៤២) អ៊ឹម សោម
១៤៥) ខៀវ អេង
១៤៦) ឃ្លោក ស្រាន
១៤៧) ឃុន គួយ
១៤៨) គឹម ស្រួ
១៤៩) គង់ វ៉ាន់ថា
១៥០) គង់ វ៉ាន់ថន
១៥១) គ្រុយ ជាតិ
១៥២) គ្រី សុខហេង
១៥៣) ឡោ សេងគឹម
១៥៤) ឡុង ណេង
១៥៥) ម៉ែន អុល
១៥៦) ម៉ឹន យ៉េង
១៥៧) មី ស្រី
១៥៨) មិន កាន
១៥៩) មូ ប៊ិច
១៦០) មួង នី
១៦១) មុយ រស់
១៦២) ងិន ហុន
១៦៣) ញ៉ែម ម៉ាន
១៦៤) នៅ ភាព
១៦៥) ប៉ា ឈុនទ្រី
១៦៦) ប៉ាវ ឆេង
១៦៧) ប៊ិច មុំ
១៦៨) ប៊ិច ភួង
១៦៩) ផៃ ឃឹម
១៧០) ផន យឿន
១៧១) ផេង អឿន
១៧២) ប៉ុង ប៉ាន់
១៧៣) ប្រាជ ទន
១៧៤) ព្រឿង ស៊ីលាង
១៧៥) រុង អាន
១៧៦) រឿន ឡេង
១៧៧) ស កិ
១៧៨) ស សំអាង
១៧៩) សំ សាស់
១៨០) សាន ខ្មៅ
១៨១) សន សុង
១៨២) សៅ រឿន
១៨៣) សោម សុងហ៊ាង
១៨៤) សូត្រ ឈន
១៨៥) ស៊ាង គ្រី
១៨៦) សិត កាលខាន់
១៨៧) ស៊ឹម យ៉េង
១៨៨) ស៊ិន អ៊ិននី
១៨៩) ស្វ ដែក
១៩០) តា ជីវេង
១៩១) តៅ គឹមហ៊ុយ
១៩២) ថុង ង៉ែត
១៩៣) ទឹម គឹមអ៊ាង
១៩៤) ទឹម ស៊ុ
១៩៥) ទឹង ហៃ
១៩៦) ទិត ដួន
១៩៧) ទិត កាន
១៩៨) ទ្រី ចក់
១៩៩) ទ្រី ជា
២០០) វ៉ាន់ យ៉េង
២០១) វ៉ែន សុវ៉ាន់នី
២០២) យន់ លឿន

**វ៉ែង ជាស៊ីល**

# ជីវិតបដិវត្តន៍របស់យុទ្ធនារី ឡៃ ស៊ឹម

សម័យបដិវត្តន៍ខ្មែរក្រហម ប្រជាជនខ្មែរដែលបានចូលក្នុងចលនាបដិវត្តន៍បានដូរឈ្មោះ ឬ ប្រើឈ្មោះថ្មីដើម្បីផ្តាច់ខ្លួនកុំឲ្យមានជាប់ពាក់ព័ន្ធជាមួយរបបមុនៗ និងដើម្បីលាក់ការណ៍សម្ងាត់ពេលបម្រើក្នុងចលនាបដិវត្តន៍ ។ ឡៃ ស៊ឹម គឺជាឈ្មោះដើមរបស់ស្ត្រីម្នាក់ ។ ពេលចូលបដិវត្តន៍ខ្មែរក្រហមក្នុងទសវត្សរ៍៧០ ឡៃ ស៊ឹម បានប្រើឈ្មោះថ្មីជំនួសវិញគឺ ស្វាយ បូ ។

ឡៃ ស៊ឹម កើតនៅភូមិអំពិល ឃុំពន្លៃ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ នៅក្នុងរបបខ្មែរក្រហម ឡៃ ស៊ឹម បានឆ្លងកាត់ការងារជាច្រើនដូចជា នារីពេទ្យ ប្រធាននារីភូមិ និរសារឃុំ យុទ្ធនារីកងពិសេស និងជានារីធ្វើស្រែអំបិល ។ បច្ចុប្បន្ន ឡៃ ស៊ឹម មានអាយុ ៥៦ឆ្នាំ រស់នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ម៉ាឡៃ ជាស្រុកមួយដែលយើងអាចធ្វើដំណើររយៈពេលប្រាំនាទីពីព្រំដែនប្រទេសថៃ និងប្រហែលប្រាំបីម៉ោងពីទីក្រុងភ្នំពេញដោយបត់តាមផ្លូវលំខាងត្បូងឃុំកូនដំរី ក្នុងស្រុកអូរជ្រៅ ។ យើងអាចទៅដល់ស្រុកនេះដោយត្រូវធ្វើដំណើរនៅលើផ្លូវរលាក់ និងរអិលដែលបណ្តាលមកពីទឹកភ្លៀងរដូវវស្សា និងរថយន្តដឹកសម្ភារពោត សណ្តែក ហួសចំណុះ ។ នៅអមសងខាងផ្លូវលំនេះ ឃើញមានស្លាកសញ្ញាគ្រាប់មីន និងដីដែលសម្បូរដោយដីជាតិ និងមានភូមិជាប់ៗគ្នាជាច្រើនដែលជាកន្លែងរស់នៅរបស់អតីតខ្មែរក្រហមក្នុងកម្ពុជាប្រជាធិបតេយ្យ ។

ប្រហែលជា៩៥ភាគរយក្នុងចំណោមប្រជាជនសរុបចំនួន៨៣៥០នាក់ នៅឃុំម៉ាឡៃ គឺជាអតីតខ្មែរក្រហមមកពីខេត្តផ្សេងៗមករស់នៅតំបន់នេះតាំងពី១៩៧៩មក ។ ចំណែកអ្នកខ្លះទៀតបានរត់ភៀសខ្លួនទៅរស់នៅប្រទេសថៃ ដោយសារភ័យខ្លាចនឹងពាក្យបរិហាមអារ៉ាមថា វៀតណាមចាប់កាត់ក្បាល ។

ក្នុងអំឡុងទសវត្សរ៍៨០ និងដើមទសវត្សរ៍៩០ ម៉ាឡៃជាតំបន់ប្រយុទ្ធមួយ ដោយខ្មែរក្រហមយកភ្នំម៉ាឡៃដែលមានផ្ទៃដី ៤០០ម៉ែត្រការ៉េធ្វើជាទីបញ្ជាការយោធា ។ ក្នុងអំឡុងពេលនោះមេដឹកនាំខ្មែរក្រហមបានព្រមានប្រជាជនណាដែលចង់ទៅរស់នៅតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ហើយប្រសិនបើមិនស្តាប់ប្រជាជនទាំងនោះនិងក្លាយជាគោលដៅសម្លាប់ ។ រហូតមកដល់ថ្ងៃទី៦ ខែ សីហា ឆ្នាំ១៩៩៧ ក្រោមការដឹកនាំរបស់ អៀង សារី ប្រជាជនរស់នៅស្រុកម៉ាឡៃទាំងអស់បានចុះចូលជាមួយរដ្ឋាភិបាល និងបច្ចុប្បន្នលោក ទេព ឃុនណាល់ (អតីតទីប្រឹក្សារបស់ ប៉ុល ពត) ជាអភិបាលស្រុក ។

កាលពីកុមារភាព ឡៃ ស៊ឹម បានចូលរៀននៅសាលាបឋមសិក្សាកំពែង ហើយរៀងរាល់ថ្ងៃ ឆៀតពីរៀនសូត្រ គាត់តែងតែឆៀតពេលទៅទិញពោតពីផ្សារព្រៃល្វាមកលក់នៅក្នុងភូមិ ។ ឡៃ ស៊ឹម រៀនដល់ថ្នាក់ទី៦ (សង្គមចាស់) ក៏ឈប់រៀន ហើយនៅឆ្នាំ ១៩៧០ គាត់ក៏ស្ម័គ្រចិត្តចូលធ្វើពេទ្យបដិវត្តន៍ នៅឃុំកំពែងតាមការជ្រើសរើសរបស់អង្គការ ។ ឡៃ ស៊ឹម និងនារីបដិវត្តន៍ជាច្រើនទៀតត្រូវអង្គការលើកទឹកចិត្តនិងផ្តល់តួនាទីផ្សេងៗ រហូតមានតួនាទីជាយុទ្ធនារីប្រយុទ្ធនៅក្នុងសមរភូមិ ។ ចំណែកនារីនៅក្នុងភូមិខ្លះទៀតដែលមិនមានការលះបង់ និងមិនមានចិត្តដាច់ខាត អង្គការមិនបានជ្រើសរើសឲ្យចូលបម្រើបដិវត្តន៍ទេ ។

នៅឆ្នាំ១៩៧២ ឡៃ ស៊ឹម ត្រូវបានអង្គការជ្រើសរើសឲ្យធ្វើជាប្រធាននារីភូមិអំពិល ដឹកនាំកងនារីប្រូតកាត់ និងដកស្ទូង ។ នៅក្នុងតួនាទីជាប្រធាននារីភូមិ ឡៃ ស៊ឹម បានចូលរួមប្រជុំជីវភាពនៅផ្ទះមួយនៅក្នុងភូមិ ដែលសង់ពីថ្មហើយនៅសល់រហូតមកដល់សព្វថ្ងៃ ។ ចំណែកសមាជិកកងនារីពីរនាក់របស់ ឡៃ ស៊ឹម ដែលបានចូលរួមប្រជុំជីវភាពជាមួយគាត់នៅពេលនោះក៏នៅរស់រានមានជីវិតរហូតមកដល់ពេលនេះដែរ ។

រហូតដល់ឆ្នាំ១៩៧៣ ឡៃ ស៊ឹម ត្រូវបានអង្គការផ្លាស់ឲ្យមកធ្វើជានិរសារឃុំវិញ ដោយត្រូវជិះកង់យកសំបុត្រពីភូមិមួយទៅប្រគល់ឲ្យទៅភូមិមួយទៀត ។ ឡៃ ស៊ឹម ពេញចិត្តការងារនេះជាងការងារមុនៗ ។ គាត់មិនបានដឹងថាក្នុងសំបុត្រនោះសរសេរពី

អ្វីក៏ដោយ ហើយគាត់ក៏មិនដែលលួចបើកសំបុត្រនោះអានដែរមុនពេលយកទៅប្រគល់ឲ្យកម្មាភិបាលខ្មែរក្រហម ។ នៅក្នុងសម័យខ្មែរក្រហម និរសារជាតួនាទីដែលមានតម្លៃ មានអំណាច និងសង្គមកោតសសើរ ហើយជាទូទៅអង្គការបានជ្រើសរើសក្មេងដែលខ្លួនទុកចិត្តឲ្យធ្វើការងារនេះ ។ រហូតមកដល់ពេលនេះ ខ្លែ ស៊ីម នៅតែមានមោទនភាពចំពោះការងារដែលគាត់បានបំពេញ ។

មួយរយៈក្រោយមក អង្គការធ្វើការជ្រើសរើសនារីដែលមានឪពុកម្តាយក្រីក្រ និងជាវណ្ណៈអធនឲ្យចូលបម្រើកងទ័ពបដិវត្តន៍ ។ ពេលនោះ ខ្លែ ស៊ីម និងនារីនៅក្នុងភូមិជាច្រើននាក់ទៀតបានស្ម័គ្រចិត្តចូលធ្វើយោធា ព្រោះ ខ្លែ ស៊ីម មានឪពុកជាអ្នកធាក់ស៊ីក្លូនៅក្នុងសម័យសាធារណរដ្ឋខ្មែរ ។ ចំណែកឪពុកម្តាយ ខ្លែ ស៊ីម ក៏មិនហ៊ានជំទាស់នឹងការសម្រេចចិត្តរបស់គាត់ដែរ ។ ពេលចូលដំបូង អង្គការបានបញ្ជូន ខ្លែ ស៊ីម ឲ្យទៅហាត់បាញ់កាំភ្លើងលូន ក្រាប និងវាឡើងទៅបោកគ្រាប់បែកដាក់ ខ្មាំងនៅព្រៃក្មេង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ បន្ទាប់មក ទើបអង្គការបែងចែក ខ្លែ ស៊ីម ចូលក្នុងកងពិសេស១០១ តំបន់៣៣ ដោយនៅពេលនោះ



ខ្លែ ស៊ីម

ប្រជាជនជាអ្នកជួយខបត្តម្ភស្បៀងអាហារ និងដាំបាយដាក់ស្នុកឲ្យគាត់ ហើយនៅពេលរដូវបុណ្យភ្ជុំម្តងៗ ប្រជាជនតែងតែយកនំអន្សម និងនំជាលមកឲ្យគាត់ហូបទៀតផង ។

ក្រោយពីហាត់ក្បួនយោធាចប់ មេបញ្ជាការកងវរៈឈ្មោះ ហ៊ីម បានបញ្ជូន ខ្លែ ស៊ីម ឲ្យឡើងទៅវាយនៅសមរភូមិពេជ្រនិលដោះកញ្ចូរ មហាសាំង និងត្រពាំងក្រឡឹងដោយភាគច្រើនយោធារបស់គាត់ទទួលបានជ័យជម្នះ ។ ប៉ុន្តែមានពេលខ្លះ ខ្លែ ស៊ីម ក៏ទទួលបរាជ័យ និងរត់ចោលសមរភូមិដែរ ដោយបន្សល់ទុកយោធាស្លាប់ និងរងរបួសជាច្រើន ។ ទោះបីជាកងរបស់ ខ្លែ ស៊ីម ទទួលបរាជ័យយ៉ាងនេះក៏ដោយ ក៏មេបញ្ជាការមិនដែលស្តីបន្ទោសឲ្យគាត់ដែរ ហើយពេលនោះ ដោយសារអង្គការគិតដល់វីរភាពយោធា ទើបតម្រូវឲ្យយោធាទាំងអស់ដឹកនាំកម្លាំងប្រជាជនទៅសែងយកអ្នករងរបួសនិងសាកសពមកសមរភូមិក្រោយ ។ សាកសពយោធាទាំងនោះ ត្រូវខ្មែរក្រហមវះពោះច្រកអំបិលកុំឲ្យស្អុយ រួចដឹកមកស្រុកកំណើតដើម្បីឲ្យបងប្អូនធ្វើបុណ្យ ។ មិត្តនារីពីរនាក់របស់ ខ្លែ ស៊ីម (ជាមិត្តភក្តិនិងរស់នៅក្នុងភូមិជាមួយគ្នា) ដែលបាក់ទ័ពនៅពេលប្រយុទ្ធ និងមិនហ៊ានរត់គេចខ្លួនព្រោះខ្លាចកងទ័ពអាមេរិកកាំងបាញ់ ក៏ត្រូវរថក្រោះកិនស្លាប់នៅក្នុងលេណដ្ឋាន ហើយសាកសពទាំងពីរនោះត្រូវខ្មែរក្រហមបញ្ជូនមកឲ្យបងប្អូនធ្វើបុណ្យនៅស្រុកកំណើត ។ រហូតមកដល់សព្វថ្ងៃនេះ នៅពេល ខ្លែ ស៊ីម ទៅជួបម្តាយរបស់មិត្តភក្តិទាំងពីរនាក់នោះ គាត់ទាំងពីរនាក់តែងតែយំដោយសារសោកស្តាយកូនដែលស្លាប់ទៅ ។

នៅរាល់ពេល ខ្លែ ស៊ីម ចេញទៅប្រយុទ្ធម្តងៗ មេបញ្ជាការបែងចែកកម្លាំងយុទ្ធជនមួយកង និងកម្លាំងយុទ្ធនារីមួយកងទៀតនៅក្នុងលេណដ្ឋានដាច់ដោយឡែកពីគ្នា ប៉ុន្តែបានកំណត់ពេលវេលាច្បាស់លាស់ដើម្បីបាញ់សម្រុកព្រមគ្នាទៅលើសត្រូវហើយនៅពេលចល័តកងទ័ព ខ្លែ ស៊ីម ត្រូវដើរថ្មើរជើងដោយខ្ចប់បាយដាក់ស្នុកទុកហូប និងកាច់ស្លឹកឈើគ្របពីលើក្បាលដើម្បីកុំឲ្យកងទ័ពអាកាសអាមេរិកាំង មើលឃើញនិងទម្លាក់គ្រាប់បែក ។ នៅពេលនោះ ខ្មែរក្រហមមិនបាននិយាយពីកងទ័ព លន់ នល់ ទេ ប៉ុន្តែបានបំផុសយោធារបស់ខ្លួនឲ្យធ្វើសង្គ្រាមជាមួយអាមេរិកវិញ ។

នៅក្រោយថ្ងៃរំដោះ ឆ្នាំ១៩៧៥ មេបញ្ជាការបានចាត់

តាំង ឡៃ ស៊ីម ឲ្យមកយាមការពារនៅកំពង់ទួល ក្រុងភ្នំពេញ ប៉ុន្តែគាត់មិនដឹងថាយាមការពារអ្វី និងនៅទីតាំងត្រង់ណាច្បាស់លាស់ដែរ ។ រហូតដល់ឆ្នាំ១៩៧៦ ទើបអង្គការដកគាត់យកទៅនៅកងនារីធ្វើស្រែអំបិល នៅខេត្តកំពតវិញ ។ នៅទីនោះ ឡៃ ស៊ីម ត្រូវធ្វើការរហូតដល់យប់ជ្រៅទើបឈប់ ។ ដោយសារ ឡៃ ស៊ីម បែកពីឪពុកម្តាយតាំងពីអាយុ១៥ឆ្នាំ និងខ្វាចឪពុកម្តាយព្រួយបារម្ភ គាត់ក៏បានសរសេរសំបុត្រមួយច្បាប់បញ្ជាក់ថាគាត់នៅរស់ ហើយសរសេរកានៅលើខ្នងសំបុត្រថា ឡៃ ស៊ីម ឬ ស្វាយ បូ ផ្ញើឲ្យឪពុកឈ្មោះ ស្វាយ មុយ នៅភូមិអំពិល ឃុំពន្លៃ ។ ពេលមួយប្រធានកងនារីបានជ្រើសរើសនារីជាច្រើននាក់ ដែលមានសមត្ថភាពធ្វើការងារសកម្មនិងអង្គការទុកចិត្តឲ្យមកទស្សនកិច្ចនៅភ្នំពេញ និងមើលកុនឯកសារអំពីនារីស្រែអំបិលនៅរោងកុនចេនឡា (ខាងត្បូងផ្សារដើមគរ) ។ ពេលនោះ ឡៃ ស៊ីម ក៏ត្រូវបានជ្រើសរើសឲ្យទៅភ្នំពេញដែរ ។

ក្រោយពីត្រឡប់ទៅកងវិញ ឡៃ ស៊ីម ធ្វើការនៅស្រែអំបិល រហូតដល់កងទ័ពវៀតណាមវាយចូលមកដល់ទើបគាត់រត់ត្រឡប់មករស់នៅស្រុកកំណើតវិញ ហើយរស់នៅទីនោះបាន ១១ខែ ។ ប៉ុន្តែក្រោយមក ដោយសារអ្នកភូមិមិនពេញចិត្តគាត់ ព្រោះគាត់ជាអតីតប្រធាននារីភូមិ និងជាយុទ្ធនារីខ្មែរក្រហម ទើប ឡៃ ស៊ីម សម្រេចចិត្តភៀសខ្លួនជាមួយប្រជាជន និងខ្មែរក្រហមជាច្រើនទៀតទៅ នៅតំបន់ជិតព្រំដែនថៃដូចជា ប៉ៃលិន សាលាក្រៅ បឹងឆ្នាំង និង ភ្នំបារាំងធ្លាក់ ដោយប្រកបរបរលក់ដូរជាមួយថៃដើម្បីយកអាហារហូប ។ នៅទីនោះ មានមនុស្សជាច្រើនបានស្លាប់ដោយសារអត់អាហារ និងជំងឺគ្រុនចាញ់ ចំណែក ឡៃ ស៊ីម ក៏មានជំងឺហើមជើង និងហើមដៃដែរ ហើយក្រោយមកទើបគាត់ទទួលការឧបត្ថម្ភស្បៀងអាហារពីកាកបាទក្រហម ។

នៅពេលថ្មីៗនេះ ដោយសារ ឡៃ ស៊ីម មានការនឹករឭកឪពុកឈ្មោះ ស្វាយ មុយ ដែលមានអាយុ៨៤ឆ្នាំហើយ ទើបយើងនាំគាត់ត្រឡប់មកលេងភូមិកំណើតវិញ ។ នៅតាមផ្លូវធ្វើដំណើរ ឡៃ ស៊ីម មានអារម្មណ៍សប្បាយរីករាយ និងរៀបរាប់យ៉ាងក្បោះក្បាយពីប្រវត្តិការងាររបស់គាត់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែប្រជាជនក្នុងភូមិមិនពេញចិត្តនឹងការងាររបស់គាត់នៅសម័យនោះទេ ។ ប្រសិនបើ ឡៃ ស៊ីម រស់នៅក្នុងភូមិនេះ ប្រជាជននឹងមើលឃើញថាគាត់ជាប្រធាននារីភូមិ នីរសារ យុទ្ធនារី ហើយគាត់ខ្លួនឯងនឹងមានការរង្គាសចិត្ត និងខ្មាសអៀនពីអតីតកាលដែលគាត់ធ្លាប់ធ្វើ ហើយប្រសិនបើគាត់ក្រីក្រ គាត់នឹងត្រូវទទួលការមាក់ងាយ និងមិនពេញចិត្តពីអ្នកភូមិថែមទៀត ។ ដូច្នេះហើយ ទើប ឡៃ ស៊ីម សម្រេចចិត្តទៅរស់នៅម៉ាឡៃវិញ ។

រឿងរ៉ាវរបស់ ឡៃ ស៊ីម បានឆ្លុះបញ្ចាំងពីការផ្សះផ្សាជាតិ ។ សំណួរមួយសួរថាតើ ឡៃ ស៊ីម ដែលបច្ចុប្បន្នរស់នៅស្រុកម៉ាឡៃនោះ អាចផ្សះផ្សាជាមួយអ្នកភូមិបានល្អជាងដែរឬទេ? ឬមួយ ឡៃ ស៊ីម មករស់នៅក្នុងភូមិវិញដែលត្រូវទទួលការមាក់ងាយ ហើយក្រោយមកទទួលបានផ្សះផ្សានោះ?

ចំណែកនៅតំបន់ផ្សេងទៀត ដែលខ្មែរក្រហមមិនបានរត់ភៀសខ្លួនទៅនៅម៉ាឡៃ ដូច ឡៃ ស៊ីម ហើយមករស់នៅក្នុងភូមិជាមួយប្រជាជនក៏មានសំណួរសួរថា តើខ្មែរក្រហមទាំងនោះផ្សះផ្សាជាមួយអ្នកភូមិបានដែរឬទេ? ហើយប្រហែលជាវិធីនេះមានការផ្សះផ្សាល្អជាង ឡៃ ស៊ីម ដែលរស់នៅឆ្ងាយពីអ្នកភូមិ ព្រោះជាទូទៅប្រជាជនមានការអត់ឱនតាមរយៈកាយវិការ និងការជជែកគ្នាក្នុងចំណោមជនរងគ្រោះដែលអាចធ្វើឲ្យមានការផ្សះផ្សាបាន ។ ដោយឡែក ឡៃ ស៊ីម ដែលរស់នៅឆ្ងាយពីប្រជាជននោះ បង្កឲ្យមានផ្សះផ្សាជាតិបានទេ?

អ្នកភូមិមួយចំនួនបានស្តីបន្ទោស ឡៃ ស៊ីម ពីការស្លាប់ក្មួយរបស់គាត់ដោយគ្រោះថ្នាក់ចរាចរនៅមុនពេលគាត់ទៅដល់ភូមិថា បណ្តាលមកពីកម្មពៀររបស់ ឡៃ ស៊ីម ដែលធ្លាប់ធ្វើជាប្រធាននារីភូមិ ។ ប្រជាជនមួយចំនួនទៀតបាននិយាយថា ប្រសិនបើ ឡៃ ស៊ីម មិនបានរត់គេចខ្លួនពីចេញពីភូមិទេ គាត់ក៏មិនមានជីវភាពធូធារ និងរស់នៅបានសុខស្រួលដូចសព្វថ្ងៃនេះដែរ ។

រឿងរ៉ាវរបស់ ឡៃ ស៊ីម ក៏បានឆ្លុះបញ្ចាំងផងដែរថា តើយន្តការណាមួយមានប្រសិទ្ធភាពជាង រវាងការរស់នៅដាច់ពីគ្នារវាងជនដៃដល់ និងជនរងគ្រោះ ការរស់នៅក្បែរគ្នារវាងជនដៃដល់ និងជនរងគ្រោះ ហើយបន្ទាប់មកតាមរយៈវប្បធម៌ និងសាសនាធ្វើឲ្យមនុស្សចេះអត់ឱន ឬផ្សះផ្សាគ្នាបានឬយ៉ាងណា ។

**សោម ប៊ុនថន**

# តស៊ូចិញ្ចឹមឪពុកម្ដាយក្មេកក្នុងរបបខ្មែរក្រហម




លោកយាយ ឃាម យី គឺជាស្ត្រីវ័យ៧៨ឆ្នាំម្នាក់ រស់នៅឃុំពង្រ ស្រុកឆ្លូង ខេត្តក្រចេះ ។ ដោយសារខេត្តក្រចេះស្ថិតនៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហមតាំងពីឆ្នាំ ១៩៧០ ប្រជាជនស្ទើរតែទាំងអស់នៅក្នុងតំបន់នេះ ត្រូវបានចាត់ទុកជាអ្នកមូលដ្ឋាន ឬ ប្រជាជនចាស់ ហើយទទួលបាននូវលក្ខខណ្ឌរស់នៅប្រសើរជាងប្រជាជននៅតាមតំបន់ផ្សេងៗទៀត ។ ទោះជាយ៉ាងនេះក្ដី លោកយាយ យី មានប្រសាសន៍ថា ការរស់នៅរបស់ប្រជាជននៅតែមានការរឹតត្បិត និងប្រកបដោយភាពភ័យខ្លាចជារៀងរាល់ថ្ងៃ ។ ខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរមកលើជនជាតិចាមនៅក្នុងឃុំពង្រ ជាឃុំមួយដែលមានជនជាតិចាមរស់នៅច្រើន ។ ខ្មែរក្រហមបានបង្ខំជនជាតិចាមឲ្យទៅរស់នៅលាយឡំគ្នាជាមួយនឹងជនជាតិខ្មែរ មិនឲ្យគោរពជំនឿសាសនាអ៊ីស្លាម បង្ខំឲ្យហូបសាច់ជ្រូក និងលះបង់ចោលទាំងអស់នូវអត្តសញ្ញាណជាចាម ។

នៅក្នុងរយៈកាលនៃរបបខ្មែរក្រហម លោកយាយ យី និងប្ដីឈ្មោះ ម៉ុត វិន រស់នៅក្នុងភូមិដងក្ដោង ជាមួយកូន៨នាក់ និងម្ដាយក្មេកចាស់ជរាម្នាក់ ។ កូនស្រីឈ្មោះ ម៉ុត វេត និងកូនប្រុសឈ្មោះ ម៉ុត គន្ធូ ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ ។ ឪពុកក្មេករបស់ យី រស់នៅជាមួយបងថ្លៃស្រីឈ្មោះ ម៉ុត ឡូ ដែលត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងភូមិចាមក្សែរគ្នានោះដែរ ។ ម្ដាយក្មេករបស់ យី ត្រូវបានចាត់តាំងឲ្យវៃអំបោះធ្វើក្រមានៅផ្ទះ ។ យី មានប្រសាសន៍ថា ឪពុកម្ដាយក្មេកចាស់ជរារបស់គាត់មិនអាចទៅហូបបាយរួមនៅតាមរោងបាយរបស់សហករណ៍ជាមួយប្រជាជនដទៃទៀតបានទេ ។ ជាសំណាងល្អ ខ្មែរក្រហមបានអនុញ្ញាតឲ្យម្ដាយក្មេករបស់គាត់ស្នាក់នៅឯផ្ទះ ហើយទទួលបានរបបបបរបន្តិចបន្តួច ។ ទោះបីជាឪពុកក្មេកមិននៅផ្ទះជាមួយខ្លួនក្ដី យី នៅតែលួចទៅមកដើម្បីនាំយកអាហារបន្ថែមបន្តិចបន្តួច ដែលលួចលាក់បានទៅឲ្យឪពុកក្មេកពិសា ។

ដោយសារការហូបចុកមានការខ្វះខាតខ្លាំង ហើយឪពុកម្ដាយក្មេកមានវ័យចាស់ជរា កូនប្រុសរបស់ យី ឈ្មោះ ម៉ុត ផាច ដែលត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅតាមកងចល័តបានទៅលួចរកត្រីដោយលាក់នៅតាមជើងខោ យកមកអាំងធ្វើជាម្ហូបអាហារបន្ថែមសម្រាប់ជីដូនជីតារបស់ខ្លួន ។ សមាជិកគ្រួសារផ្សេងទៀតបានខិតខំប្រឹងប្រែងរកអាហារបន្ថែម ដើម្បីយកមកផ្គត់ផ្គង់គាត់ទាំងពីរនៅឯផ្ទះ ។ យី និយាយថា គាត់បានដាច់សីលដាច់ទានអស់ហើយនៅក្នុងរបបខ្មែរក្រហម ដោយសារគាត់ត្រូវតែលួចម្ហូបអាហារបន្ថែមដើម្បីរស់ និងចិញ្ចឹមឪពុកម្ដាយក្មេកចាស់ជរា ។

យី ត្រូវបានចាត់បញ្ចូលជាកម្លាំងទីមួយ ដែលត្រូវចុះទៅច្រូតស្រូវជារៀងរាល់ថ្ងៃ ហើយបន្ទាប់ពីឡើងពីវាលស្រែវិញ យី ត្រូវមកជួយដាំបបរសម្រាប់ប្រជាជននៅក្នុងសហករណ៍ ។ ចំណែកប្ដីរបស់គាត់ត្រូវបានចាត់តាំងឲ្យទៅកាន់ម៉ាស៊ីនបូមទឹកដាក់ស្រែ ។ យី បានរៀបរាប់ថា សម្ភារទាំងអស់ ដែលរួមទាំងសម្ភារផ្ទះបាយផង ត្រូវបានខ្មែរក្រហមប្រមូលដាក់រោងបាយទាំងអស់ ប៉ុន្តែគាត់បានលួចលាក់ទុកសម្ភារមួយចំនួនសម្រាប់ប្រើប្រាស់នៅក្នុងគ្រួសារ ដូចជាកំសៀវសម្រាប់ដាំទឹកហូបជាដើម ។ ដោយសារខ្លួនធ្វើការនៅក្នុងផ្ទះបាយ ថ្ងៃមួយ យី បានលួចផ្អកដោយដាក់នៅក្នុងក្រមា ហើយចងភ្ជាប់ទៅនឹងក្បាលរបស់គាត់យកមកផ្ទះ ។ គាត់បានចែកផ្អកនោះជាពីរចំណែក ដោយមួយចំណែកយកទៅឲ្យឪពុកក្មេកដែលកំពុងរស់នៅជាមួយបងថ្លៃស្រីនៅភូមិផ្សេង ហើយមួយចំណែកទៀតទុកសម្រាប់ម្ដាយក្មេកនិងក្រុមគ្រួសារ ។

ថ្ងៃមួយគាត់សប្បាយចិត្តយ៉ាងខ្លាំង ដោយគាត់ទទួលបាន

បាយមួយចានយកទៅជូនម្តាយក្មេករបស់គាត់ ។ អ្នកជិតខាងដែលមានប្តីធ្វើជាកម្មាភិបាលខ្មែរក្រហមបានដាំបាយហូប ហើយបានដួសបាយមួយចានមកឲ្យគាត់ ។ ឃី បានយកបាយនោះទៅជូនម្តាយក្មេកដែលកំពុងសម្រាកនៅលើគ្រែ ។ ម្តាយក្មេករបស់គាត់មានការត្រេកអរយ៉ាងខ្លាំងពេលឃើញបាយក្ងាម ព្រោះគាត់ហូបរបបរយូរណាស់មកហើយ ។ ម្តាយក្មេករបស់គាត់បានលាន់មាត់ស្រែកខ្លាំងៗថា «ហើយចុះបានបាយមកពីណា»? ឃី បានលើកដៃធ្វើសញ្ញាឲ្យគាត់ស្ងាត់ក្រែងលោកម្មាភិបាលខ្មែរក្រហមស្តាប់ឮដោយចៃដន្យ ដែលអាចបង្កគ្រោះថ្នាក់ដល់ក្រុមគ្រួសារទាំងមូល ។ ឃី បានប្រាប់ម្តាយក្មេកថា «ពិសាទៅ គេឲ្យ» ។ ម្តាយក្មេករបស់ ឃី បានយកបាយនោះមកពិសាជាមួយនឹងចៅតូចម្នាក់ ដែលត្រូវជាកូនពៅរបស់ ឃី ឈ្មោះ ម៉ុត ដុប ។ ដុប ដែលខានហូបបាយអស់រយៈពេលជាយូរមកហើយបានសួរជីដូនថា «ស្អីគេនឹងម៉ា ផ្អែមៗ»? ឃី បានសម្លឹងមើលម្តាយក្មេកហូបបាយដោយក្តីអាណិត ដោយសារគាត់មានវ័យចាស់ជរា ហើយ ឃី មិនហ៊ានធ្វើម្ហូបអ្វីច្រើនជូនគាត់ពិសាទេ ព្រោះខ្មែរក្រហមតាមដានសកម្មភាពរបស់ប្រជាជនយ៉ាងតឹងតែង ។ ឃី បានបន្ថែមទៀតថា «គេឲ្យខ្ញុំធ្វើការនៅរោងបាយ តែមិនហ៊ានយកបាយហូប ។ អង្ករអី បើលួចបាន តែមិនហ៊ាន ខ្លាចគេដឹង ។ អ៊ីចឹងទៅសុខចិត្តហូបបបររាវៗនឹងទៅ ។ ជួនទៅយើងសម្រិតយកទឹកបបរទៅ ហើយសល់កាកយកទៅជូនគាត់ទៅ» ។

ក្នុងពេលធ្វើការនៅក្នុងរោងបាយរបស់សហករណ៍ ឃី បានមើលឃើញការធ្វើបាបរបស់ខ្មែរក្រហមមកលើជនជាតិចាម ។ ខ្មែរក្រហមបានបង្ខំឲ្យជនជាតិចាមទាំងនោះហូបសាច់ជ្រូក ។ «ទៅសុំអំបិលគេ ក៏គេមិនឲ្យ គេឲ្យស៊ីសាច់ជ្រូក ។ ស៊ីរួច ខ្ទប់មាត់រត់» ។ ឃី មានចិត្តអាណិតអាសូរដល់ជនជាតិចាមទាំងនោះ ប៉ុន្តែមិនហ៊ានលួចឲ្យអំបិល ព្រោះខ្លាចខ្មែរក្រហមយកទៅកសាង និងយកទៅវាយចោល ។ ឃី បាននិយាយថា «មិនដឹងធ្វើម៉េចទេ ទ្រាំតាមបុណ្យតាមកម្មអញ្ចឹងទៅ» ។ ខ្មែរក្រហមតម្រូវឲ្យជនជាតិចាមនិងខ្មែរប្តូរផ្ទះគ្នានៅ «ដូរពីចាមមកខ្មែរ ហើយពីខ្មែរទៅចាម ជួនណាទៅនៅផ្ទះជាមួយគ្នាទៅ ចាមនិងខ្មែរនោះ» ។ ជនជាតិចាមនិងជនជាតិខ្មែរត្រូវហូបអាហាររួមគ្នា ។ អ្នកខ្លះក្អួតក្រោយពេលហូបម្ហូបដែលមានលាយសាច់ជ្រូករួចមក ហើយគ្មានកម្លាំងក្នុងការធ្វើការនោះទេ ។ ជនជាតិចាមមួយចំនួន ដែលនៅមានអំបិលជាប់ខ្លួនបានយកអំបិលមកតាមខ្លួន ហើយរោយនៅលើបបរហូបជំនួសឲ្យសម្លដែលមានលាយសាច់ជ្រូក ។ ឃី មិនដែលបានឃើញការសម្លាប់មនុស្សទេ ប៉ុន្តែធ្លាប់ឮអ្នកភូមិខ្សឹបប្រាប់គ្នាថា ខ្មែរក្រហមបានយកជនជាតិចាមជាច្រើនទៅវាយទម្លាក់ទឹកទន្លេមេគង្គដែលនៅក្បែរភូមិ ។ ឃី បានរៀបរាប់ថា «ជួនទៅគេវាយទម្លាក់ទន្លេ ជួនទៅគេយកទៅព្រៃខ្លះទៅ ។ យើងអត់ហ៊ានសួរអត់ហ៊ានដឹងអីទេ គ្រាន់តែលួចស្តាប់គ្នាតិចៗនៅតាមកន្លែងធ្វើការនឹង» ។


ឃាម ឃី

សហករណ៍ដែល ឃី រស់នៅក៏មានប្រជាជនជម្លៀសមកពីភ្នំពេញដែរ ។ ប្រជាជនថ្មីទាំងនេះ មករស់នៅក្នុងផ្ទះជាមួយនឹងប្រជាជនចាស់ ។ មួយរយៈក្រោយមកប្រជាជនថ្មីទាំងនេះត្រូវបានដឹកតាមរទេះគោបញ្ជូនឲ្យទៅរស់នៅភូមិផ្សេងជាប់ស្រយាល ដែលនៅទីនោះអ្នកភ្នំពេញទាំងនេះបានស្លាប់ ដោយសារជំងឺគ្រុនចាញ់អស់ជាច្រើន ។ ឃី មិនដែលហ៊ានទៅនិយាយលេងឬសួរនាំអ្នកដែលមកពីភ្នំពេញទេ ។ ខ្មែរក្រហមបានហាមឃាត់យ៉ាងតឹងរ៉ឹង មិនឲ្យអ្នកមូលដ្ឋានទៅទាក់ទងជាមួយនឹងអ្នកជម្លៀសមកពី

ភ្នំពេញទេ ។ «គេថាកុំទៅទំនាក់ទំនងអីជាមួយគ្នា បើជួបគ្នា ទៅជួបនៅឯវាលកន្លែងធ្វើការឯណោះ» ។ សូម្បីតែបងប្អូនគាត់បង្កើតដែលរស់នៅត្រើយម្ខាងនៃទន្លេមេគង្គក្នុងស្រុកព្រែកប្រសប់ ក៏ខ្មែរក្រហមហាមមិនឲ្យធ្វើទំនាក់ទំនងជាមួយគ្នាដែរ ។ ប៉ុន្តែ ដោយសារនឹកម្តាយពេកយូរៗម្តង យី បាន លួចឆ្លងទៅជួបបងប្អូននិងម្តាយបង្កើត ។

អ្នកភ្នំពេញនិងអ្នកមូលដ្ឋានធ្វើការដូចៗគ្នា ។ យី បាន និយាយថា «ការងារប៉ុនគ្នា ដូចដកសំណាបហ្នឹងក៏ប៉ុនគ្នាដែរ លើកភ្លឺអីចឹងដែរ ដាក់យើងប៉ុន្មានម៉ែត្រ ដាក់ពួកនឹងក៏ប៉ុណ្ណឹងដែរ» ។ ការហូបចុកមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ខ្មែរក្រហមចែករបបឲ្យស្មើៗគ្នាមិនថាអ្នកមូលដ្ឋានឬអ្នកថ្មីនោះទេ នេះបើតាមសម្តីរបស់ យី ។ ប៉ុន្តែជាញឹកញយ យី ឧស្សាហ៍ឮថាមានអ្នកថ្មីមួយចំនួនបានបាត់ខ្លួន ។


ឌី ខាំបូលី

យី និងក្រុមគ្រួសាររស់នៅក្នុងភូមិដងក្តោងរហូតដល់ថ្ងៃដួលរលំនៃរបបខ្មែរក្រហមនៅដើមឆ្នាំ១៩៧៩ ។ នៅពេលកងទ័ពវៀតណាមនិងកងកម្លាំងរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយចូលមកក្នុងខេត្តក្រចេះ ខ្មែរក្រហមបានប្រកាសតាមមីក្រូឲ្យប្រជាជនទាំងអស់នាំគ្នាចុះទូកធ្វើដំណើរទៅក្រោម ។ ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនទាំងអស់ធ្វើដំណើរទៅជួបជុំគ្នានៅវត្តព្រែកសំរោង ហើយនឹងបន្តដំណើរតាមទូកឆ្លងទៅត្រើយម្ខាងទៅកាន់ស្រុកព្រែកប្រសប់ ។ យី បានរៀបរាប់ថា នៅតាមផ្លូវមានមនុស្សយ៉ាងច្រើនបានធ្វើដំណើរភៀសខ្លួន ។ អ្នកខ្លះរែកជីដូនជីតាចាស់ដែលអង្គុយនៅក្នុងល្អី ។ អ្នកខ្លះពរជីដូនជីតារត់ ។ យី បាននាំឪពុកម្តាយក្មេកជម្លៀសទៅខាងក្រោមជាមួយនឹងគេដោយដាក់ឲ្យគាត់ទាំងពីរអង្គុយនៅក្នុងរទេះឈើមួយ ហើយអូសទៅ ។ សមាជិក គ្រួសារផ្សេងទៀតដែលមិនមានតួនាទីអូសរទេះត្រូវនាំគ្នាទូលអីវ៉ាន់ ។ ដោយសារវ័យចាស់ជរា និងការភ័យតក់ស្លុតនឹងការប្រកាសឲ្យចេញពីផ្ទះសម្បែងជាថ្មីម្តងទៀត ម្តាយក្មេករបស់ យី បានធ្លាក់ខ្លួនឈឺនៅតាមផ្លូវ ។ យី និងសមាជិកគ្រួសារទាំងអស់ត្រូវស្នាក់នៅឯភូមិអន្លង់សាលិរយៈពេលបីយប់ទើបធ្វើដំណើរបន្តទៅឃុំចំបក់ក្នុងស្រុកព្រែកប្រសប់ ដែលជាស្រុកកំណើតរបស់ យី ។ ទៅដល់ឃុំចំបក់ ម្តាយក្មេករបស់ យី បានស្លាប់ដោយសារជំងឺគ្មានថ្នាំព្យាបាល និងការអស់កម្លាំងដោយសារការធ្វើដំណើរវែងឆ្ងាយ ។ យី នឹងក្រុមគ្រួសារបានរៀបចំធ្វើបុណ្យសពម្តាយក្មេក ប៉ុន្តែនៅពេលនោះមិនមានលោកសង្ឃសូត្រមន្តអ្វីទេ ។

ក្រោយរៀបចំបុណ្យនិងទុកដាក់សពម្តាយក្មេករួចហើយ យី ប្តីនិងកូនៗបានវិលត្រឡប់មកផ្ទះនៅឯភូមិដងក្តោងវិញ ។ នៅតាមផ្លូវ អ្នកភូមិបានប្រាប់ យី ថាមានកុមារជាច្រើនបានស្លាប់នៅក្នុងចម្ការដំឡូង ។ កុមារទាំងនោះឃ្លានខ្លាំងពេក បានទៅជីកដំឡូងយកមកហូប ហើយក៏ស្លាប់នៅក្នុងរងដំឡូង ដោយសារអស់កម្លាំងពីខ្លួន ។ ត្រឡប់មកដល់ផ្ទះវិញ គោ រទេះ និងរបស់របរផ្សេងៗទៀតត្រូវបាត់ទាំងអស់ ។ អ្នកភូមិដែលមកដល់មុន បានទៅរើសយករបស់របរទាំងនោះមកប្រើប្រាស់ ។ យី ក៏ដូចជាអ្នកភូមិផ្សេងៗទៀត បាននាំគ្នាទៅច្រូតស្រូវដែលនៅសល់ពីរត់យកមកហាលហើយបុកដាំបបរហូប ។

បទពិសោធន៍របស់លោកយាយ ឃាម យី នៅក្នុងរបបខ្មែរក្រហម គឺជាឧទាហរណ៍មួយនៃទុក្ខវេទនារបស់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈទាំងអស់នៅក្នុងរបបខ្មែរក្រហម ។ ទោះបីជាប្រជាជនចាស់ ឬអ្នកមូលដ្ឋានទទួលបានការទុកចិត្ត និងត្រូវបានដាក់ឲ្យកាន់តំណែងជាច្រើននៅក្នុងរបបខ្មែរក្រហមក៏ដោយ ក៏ប្រជាជនមូលដ្ឋានជាច្រើនទទួលរងនូវការធ្វើទុក្ខបុកម្នេញនិងមានបងប្អូន កូនចៅ និងឪពុកម្តាយស្លាប់នៅក្នុងរបបខ្មែរក្រហមដែរ ។ លោកយាយ យី បានមានប្រសាសន៍នៅចុងបញ្ចប់នៃបទសម្ភាសន៍ថា «ជីវិតមានភាពវេទនាខ្លាំងណាស់នៅក្នុងរបបខ្មែរក្រហម» ។

**ឌី ខាំបូលី**

# អតីតកម្មាភិបាលនៅជំរំថ្មដា

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការរៀបការត្រូវបានរៀបចំតាមការចាត់តាំងរបស់អង្គការដោយគ្មាននរណាម្នាក់មានសិទ្ធិសម្រេច ឬប្រឆាំងនឹងការចាត់តាំងនេះបានឡើយ ។ ប៉ុន្តែ សឿន ដែលពេលនោះគ្រាន់តែជាកម្មាភិបាលថ្នាក់ទាបប៉ុណ្ណោះ បែរជាអង្គការមិនយកទោសពៃរ៍នឹងគាត់ទេ ទោះបីជាគាត់បដិសេធនឹងបញ្ហានេះក៏ដោយ ព្រោះតែគាត់ធ្វើការបានល្អ និងទទួលបានការទុកចិត្តពីអង្គការ ។ តើ សឿន លះបង់អ្វីខ្លះចំពោះបដិវត្តន៍បានជាទទួលបានការទុកចិត្តពីអង្គការ?


ប៉ុល សឿន

សឿន មានស្រុកកំណើតនៅស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ដោយសារ សឿន មានបងប្អូន៧នាក់ និងជាកូនស្រីច្បងទីពីរនៅក្នុងគ្រួសារ នៅពេលដែលរៀនបានត្រឹមថ្នាក់ទី១០ ឪពុកម្តាយរបស់គាត់បានឲ្យឈប់រៀនមកជួយធ្វើស្រែចម្ការនិងធ្វើនំបញ្ចុកលក់ដើម្បីចិញ្ចឹមប្អូនៗរបស់គាត់វិញ ។ នៅពេលដែលខ្មែរក្រហមចូលមកដល់ក្នុងភូមិ នៅឆ្នាំ១៩៧២ និងបានឃោសនាឲ្យប្រជាជនចូលគស៊ូបម្រើជាតិ សឿន និងក្មេងៗដែលមានអាយុស្របាលនឹងគាត់ក៏នាំគ្នាចូលបដិវត្តន៍ ។ ពេលនោះ ដោយសារតែស្រឡាញ់បដិវត្តន៍ខ្លាំងពេក ទោះបីជាឪពុកម្តាយហាមឃាត់យ៉ាងណាក៏ដោយ ក៏ សឿន នៅតែមិនស្តាប់គាត់ទាំងពីរដែរ ។ មុនពេលចាកចេញ សឿន បានដោះក្រវិល និងខ្សែក ដែលពាក់ជាប់នឹងខ្លួនទុកនៅក្នុងកន្ត្រកស្លា រួចរត់ចេញពីផ្ទះទៅបម្រើបដិវត្តន៍តែម្តង ។

នៅក្នុងភូមិ បងស្រីជីដូនមួយរបស់ សឿន ដែលធ្វើជាប្រធាននារីស្រុកបានចាត់តាំង សឿន ឲ្យធ្វើជានិរសាររត់សំបុត្រទៅតំបន់ និងខេត្តផ្សេងៗ ដោយមានកង់មួយសម្រាប់ជាមធ្យោបាយធ្វើដំណើរ ។ នៅឆ្នាំ១៩៧៤ សឿន ត្រូវបានផ្លាស់ឲ្យមកធ្វើជាអនុប្រធានឃុំអង្គរបុរីវិញ ដោយមានស្មៀនម្នាក់ជាជំនួយការក្រោមការគ្រប់គ្រងរបស់ ភាព ។ ការងាររបស់ សឿន គឺចុះទៅប្រជុំនៅតាមភូមិឃុំនិងអប់រំប្រជាជនឲ្យបេះតស៊ូប្រយុទ្ធជាមួយខ្មាំង បន្ទាប់មកធ្វើរបាយការណ៍អំពីការប្រជុំនេះទៅអង្គការថ្នាក់លើ ។

នៅចុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានជ្រើសរើស សឿន និងសមាជិកជាច្រើននាក់ផ្សេងទៀតឲ្យទៅធ្វើស្រែអំបិលនៅសេះស (ជាស្រែអំបិលភូមិភាគ) មានបែងចែកជាច្រើនក្រុម ដូចជាកងវែក ដឹកជញ្ជូននិងបុកអង្គប់ជាដើម ។ ចំណែក សឿន ស្ថិតនៅក្នុងកងវែកវរសេនាតូចលេខមួយមានតួនាទីវែកអំបិលដែលមានសមាជិកប្រហែល៨០នាក់ ក្រោមការគ្រប់គ្រងរបស់ សន ។ សឿន បានរៀបរាប់ពីវិធីធ្វើអំបិលថា ដំបូងកម្មករទាំងអស់ត្រូវជីកប្រឡាយមួយដើម្បីធ្វើអ្វី រួចបង្ហាប់ដីឲ្យហាប់ បន្ទាប់មកបញ្ចូលទឹកដាក់ក្នុងស្រែ ។ ក្រោយពីអំបិលដុះហើយ កម្មករទាំងអស់គ្នាត្រូវនាំគ្នាជញ្ជូនអំបិលទាំងនេះដាក់ឃ្លាំង ។ សឿន បន្តថា ទោះបីជាមានការបែងចែកការងារគ្នាច្បាស់លាស់យ៉ាងណាក៏ដោយ ប៉ុន្តែប្រសិនបើមេឃជិតភ្លៀង កម្មករទាំងអស់ត្រូវតែជួយគ្នាដើម្បីវែកអំបិលនោះរហូតដល់ភ្លឺ ។ ការងារនេះពិតមែនតែមានការលំបាកបន្តិច ប៉ុន្តែកម្មករទាំងអស់ទទួលបានអាហារហូបចុកគ្រប់គ្រាន់ ថែមទាំងមានបង្អែមម្តងក្នុងមួយសប្តាហ៍ ។

នៅទីនេះ មានឃ្លាំងចំនួនបួនសម្រាប់ផ្ទុកអំបិល ។ សឿន បានរៀបរាប់ថា នៅពេលដែលប្រមូលទិន្នផលអំបិល គឺឃើញមានរថយន្ត និងរទេះគោជាច្រើនគ្រឿងមកដឹកអំបិលនេះយកទៅ ដោយមានក្រុមសម្រាប់ប្រេកអំបិល និងដឹកជញ្ជូនដាក់ឡាន ។

នៅឆ្នាំ១៩៧៧ សឿន ស្រាប់តែទទួលបានដំណឹងថា ឪពុកម្តាយរបស់គាត់ទទួលមរណភាព ។ ពេលនោះ សឿន មានអារម្មណ៍ខឹងរបបខ្មែរក្រហមជាខ្លាំង ព្រោះគាត់ខិតខំបម្រើអង្គការ

អស់ពីកម្លាំងកាយចិត្ត និងថែមទាំងស្មោះត្រង់ចំពោះអង្គការទៀត នៅទីបំផុតសំណើរបស់គាត់ដែលសុំអនុញ្ញាតឲ្យមកស្រុកកំណើត ដើម្បីមើលឪពុកម្តាយជាលើកចុងក្រោយ បែរជាត្រូវបដិសេធទៅវិញ ។ ដោយសារតែខឹងខ្លាំងពេក សឿន បានធ្វើពុតជាឈឺមិនទៅធ្វើការ ។ សឿន បានរៀបរាប់ថា «ខ្ញុំមិនដឹងជាខិតខំតស៊ូដើម្បីអ្វីនោះទេ គ្រាន់តែជួបមុខឪពុកម្តាយលើកចុងក្រោយក៏មិនបានដែរ» ។ ដោយសារតែ សឿន ធ្វើការសកម្ម និងទទួលការទុកចិត្តពីអង្គការ ខ្មែរក្រហមក៏មិនបានយកទោសពៃរ៍គាត់ដែរ ។ ក្រោយពីសម្រាកពីរ-បីថ្ងៃហើយ ទើប សឿន ក្រោកទៅធ្វើការដូចធម្មតាវិញ ។

នៅឆ្នាំ១៩៧៨ សឿន ត្រូវផ្លាស់ឲ្យទៅធ្វើការនៅស្ទឹងហាវ ខេត្តកំពង់សោមវិញ ដោយមានតួនាទីសែងថ្មដើម្បីសាងសង់ផ្ទះ ។ នៅទីនោះបានមួយរយៈ ខ្មែរក្រហមបានរៀបចំឲ្យ សឿន រៀបការជាមួយបុរសម្នាក់ឈ្មោះ លី ដែលធ្វើការនៅក្នុងកងជាមួយគ្នា និងមានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត ។ ដោយសារតែមិនដឹងប្រវត្តិរូបច្បាស់អំពី លី ពេលនោះបងស្រីរបស់ សឿន បានឃាត់គាត់មិនឲ្យយកប្តីទេ ដោយប្រាប់ថា «ឯងចាំយកប្តីនៅកោះប៉ូឡូវៃវិញ ព្រោះថាប្តីយើងស្គាល់ថានរណាជាមនុស្សល្អ» ។ ដោយសារតែពាក្យទាំងអស់នេះ សឿន មិនព្រមរៀបការជាមួយ លី ដែលអង្គការចាត់តាំងឲ្យជាដាច់ខាត ដោយប្រាប់ថាចាំជួបបងប្រុសគាត់សិន ។ ដោយសារស្ថានការណ៍មិនសូវតឹងតែងខ្លាំង អង្គការក៏មិនបានបង្ខំគាត់ដែរ ។

បីថ្ងៃក្រោយមក កងទ័ពវៀតណាមក៏ចូលមករំដោះខេត្តនេះ រួចកៀរកម្មាភិបាលខ្មែរក្រហមទាំងអស់ឲ្យធ្វើដំណើរទៅព្រៃ ។ ពេលនោះ ទោះបីជា សឿន បានសម្ងំលាក់ខ្លួននៅក្នុងព្រៃក៏ដោយ ក៏ លី នៅតែធ្វើដំណើរមករក សឿន ដើម្បីស្នើគាត់រៀបការម្តងទៀតដែរ ។ ប៉ុន្តែ ដោយសារតែ សឿន មិនដែលស្រឡាញ់ លី ទាល់តែសោះ ទោះបីជាមានការអង្វរយ៉ាងណាក៏ដោយ ក៏ សឿន នៅតែមិនព្រមទទួលយក លី ជាប្តីដែរ ។

នៅឆ្នាំ១៩៨០ កងរបស់ សឿន ក៏ត្រូវផ្លាស់មករស់នៅជំរំថ្មដាជិតព្រំដែនខ្មែរ-ថៃវិញ ក្រោមការគ្រប់គ្រងរបស់ តាសេន ។ នៅទីនោះ សឿន មានតួនាទីដឹកជញ្ជូនគ្រាប់ទៅឲ្យសមរភូមិមុខ ដូចជា គ្រាប់អាកាមួយកេះ សម្លៀកបំពាក់ ថ្នាំពេទ្យ អង្ករ៦០ កំប៉ុងសម្រាប់ហូបខ្លួនឯង និងត្រីខជាដើម ។ ដោយសារតែការងារនេះត្រូវតែពេលធ្វើដំណើរឆ្ងាយ និងស្ពាយរបស់ជាច្រើនផង ពេលត្រឡប់មកវិញ សឿន តែងតែកើតជំងឺគ្រុនចាញ់ជាញឹកញាប់ ។ ទោះជាយ៉ាងណាក៏ដោយ ក្រោយពីជាសះស្បើយពីជំងឺហើយ សឿន នៅតែធ្វើការងារនេះដដែល ដោយការរស់នៅមិនខុសពីពេលមុនទេ ។ សឿន បន្តថា «ម្នាក់ៗមិនអាចប្រព្រឹត្តខុសសីលធម៌ឡើយ បើមិនអ៊ីចឹងទេនឹងបាត់ខ្លួនជាមិនខាន ព្រោះខ្ញុំបានឃើញសមាជិកកងរបស់ខ្ញុំបាត់ខ្លួនជាច្រើននាក់» ។

នៅឆ្នាំ១៩៨៧ សឿន បានរៀបការជាមួយបុរសម្នាក់ដែលមានស្រុកកំណើតនៅខេត្តតាកែវដែរ ដោយគាត់មានតួនាទីធ្វើទាហាននៅកោះប៉ូឡូវៃ ។ អាពាហ៍ពិពាហ៍របស់ សឿន មិនមានលក្ខណៈអធិកអធមទេ ដោយគ្រាន់តែមានពិធីជប់លៀងតូចមួយ ព្រមទាំងមានភ្ញៀវដែលជាកម្មាភិបាលដូចគ្នាចូលរួម និងឡើងប្តេជ្ញាចិត្តថា «ស្រឡាញ់គ្នាអស់មួយជីវិត» ។ ក្រោយពីរៀបការហើយ ខ្មែរក្រហមបានចែកដីឲ្យគាត់រស់នៅមានលក្ខណៈជាភូមិប្រជាជន ដោយទទួលបានរបបអាហារហូបចុកគ្រប់គ្រាន់ ដូចជាបើកជារបបអង្ករ ខ្លាញ់ ប៊ីចេង និងត្រីខជាដើម ។

នៅឆ្នាំ១៩៩៧ រដ្ឋាភិបាលក៏បានរៀបចំឲ្យប្រជាជនដែលនៅថ្មដាទាំងអស់ត្រឡប់មករស់នៅខេត្តកោះកុងទាំងអស់ ។ ពេលនោះ សឿន ក៏ចង់ត្រឡប់មកស្រុកកំណើតដែរ ប៉ុន្តែដោយសារតែនៅស្រុកកំណើតឪពុកម្តាយស្លាប់អស់ និងគ្មានដីសម្រាប់ធ្វើស្រែ ដូច្នេះគាត់បានសម្រេចចិត្តមករស់នៅភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុងវិញ ដោយរដ្ឋាភិបាលចែកដីឲ្យមានទទឹង១៥ម៉ែត្រ និងបណ្តោយ៤០ម៉ែត្រ ។ ភូមិនេះមានអតីតកម្មាភិបាលខ្មែរក្រហម (ប្រជាជនផ្តាច់ខ្លួន) ដែលរស់នៅជំរំថ្មដាចំនួន៤០គ្រួសារ បានផ្លាស់មករស់នៅទីនេះដែរ ក្រោយពេលដែលខ្មែរក្រហមបានធ្វើសមាហរណកម្មនៅឆ្នាំ១៩៩៧ ។ ជីវភាពនៅទីនេះដំបូងមានការលំបាកជាខ្លាំង ព្រោះ សឿន និងប្តីត្រូវរកឈើ សង្កសី និងរបស់ផ្សេងៗមកសង់ផ្ទះដោយខ្លួនឯង ។ សព្វថ្ងៃនេះ សឿន ប្រកបមុខរបររបន្តិចបន្តួចដើម្បីចិញ្ចឹមកូនបីនាក់ ។ **គាត លក្ខិណា**

# ឃឹម សុធា : កុមាររើសអាចម៍គោ



ឃឹម សុធា

សុធា មានស្រុកកំណើតនៅភូមិត្រពាំងវែង ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ សុធា នៅចងចាំថា នៅអំឡុងឆ្នាំ១៩៧៣ «មានយន្តហោះអាមេរិកាំងប្រហែលបីគ្រឿង ហោះមកទម្លាក់គ្រាប់បែកទៅលើភូមិត្រពាំងវែងបណ្តាលឲ្យប្រជាជនភ័យស្លន់ស្លោយ៉ាងខ្លាំង ប៉ុន្តែមិនបណ្តាលឲ្យនរណាម្នាក់គ្រោះថ្នាក់ដល់ជីវិតទេ» ។ ក្រោយមក ប្រជាជនទាំងនេះក៏នាំគ្នារត់ភៀសខ្លួនទៅរស់នៅជាមួយបងប្អូននៅស្រុកផ្សេង ចំណែកអ្នកខ្លះទៀតបានរត់ទៅលាក់ខ្លួននៅក្នុងព្រៃ ។ ដោយឃើញសភាពការណ៍ប្រឬកប្របល់ ដូច្នេះឪពុកម្តាយ សុធា ក៏សម្រេចចិត្តនាំគ្រួសារចាកចេញពីស្រុកកំណើតមករស់នៅជាមួយបងប្រុសនៅទីក្រុងភ្នំពេញវិញ ។

គ្រួសារ សុធា រស់នៅភ្នំពេញបានរយៈពេលពីរឆ្នាំប៉ុណ្ណោះ យោធាខ្មែរក្រហមក៏វាយរំដោះបាន ។ សុធា រំឭកថា នៅក្នុងខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជិះឡានធំមួយគ្រឿងចូលមកផ្ទះរបស់គាត់ រួចហើយស្រែកប្រកាសឲ្យគ្រួសារគាត់រៀបចំអីវ៉ាន់ចាកចេញពីផ្ទះរយៈពេលបីថ្ងៃសិន ដើម្បីឲ្យអង្គការរៀបចំបោសសម្អាតទីក្រុង ។ ក្រោយពីបានស្តាប់ការប្រកាសរួចមក ឪពុកម្តាយរបស់ សុធា ប្រញាប់ប្រញាល់រៀបចំខោអាវ ចាន ឆ្នាំង មាស ប្រាក់ និងនាឡិកាដៃទុក រួចធ្វើដំណើរឆ្លងកាត់មកផ្លូវជាតិលេខ៦ ។ ធ្វើដំណើរបានបន្តិច ឪពុក សុធា ឃើញយោធាជាច្រើននាក់ឈរយាម និងបញ្ជាឲ្យប្រជាជនដែលជម្លៀសមកពីទីក្រុងទាំងអស់ធ្វើដំណើរតាមទិសដៅកំណត់របស់អង្គការ ។ ស្រាប់តែពេលនោះ បុរសចំណាស់ម្នាក់បានប្រកែកតវ៉ាក៏ត្រូវយោធាខ្មែរក្រហមបាញ់សម្លាប់ចោលនៅទីនោះតែម្តង ។ ឃើញដូច្នេះ ឪពុករបស់ សុធា បានប្រាប់ទៅប្រពន្ធថា «ប្រសិនបើគេចង់បានអ្វីសូមប្រគល់ឲ្យគេទាំងអស់ទៅ មិនចាំបាច់យកទៅជាមួយទេ» ។ នៅពេលគ្រួសារ សុធា មកដល់ប្រកផ្លូវមួយ ស្រាប់តែមានយោធាម្នាក់បានមកឆែកឆេរដកយក ចាន ឆ្នាំង ខោអាវ និងនាឡិកាដៃអស់ ។ ចំណែក មាស យោធានោះរកមិនឃើញទេ ព្រោះម្តាយរបស់ សុធា បានយកទៅលាក់ក្នុងថង់សំពត់របស់គាត់តាំងពីពេលធ្វើដំណើរមកម្ល៉េះ ។

រយៈពេលប្រមាណបីខែក្រោយមក ខ្មែរក្រហមបានមកដឹកគ្រួសារ សុធា ទៅនៅសហករណ៍ក្នុងស្រុកតាំងគោក ដោយមាន តាទាវ និង យាយណាង ជាអ្នកគ្រប់គ្រង ។ ចំណែកម្តាយរបស់ សុធា ត្រូវបានអង្គការចាត់តាំងឲ្យទៅរស់នៅសហករណ៍ផ្សេងដែលមានចម្ងាយប្រមាណ១០គីឡូម៉ែត្រពីកន្លែងឪពុកគាត់រស់នៅ ។ រាល់ថ្ងៃ អង្គការបង្ខំឲ្យឪពុករបស់ សុធា ធ្វើការងារដកស្ទូង ជីកប្រឡាយ លើកទំនប់គ្មានពេលសម្រាកឡើយ ចំណែករបបអាហារមានតែបបររាវៗប៉ុណ្ណោះ ។ មិនយូរប៉ុន្មាន ឪពុក សុធា និងប្រជាជនដែលធ្វើការជាច្រើនចាប់ផ្តើមបាក់កម្លាំង និងខ្លះទៀតបានស្លាប់ដោយសារការខ្វះអាហារបរិភោគ និងមានជំងឺរាគ ។ ថ្ងៃមួយ ពេលតែកំពុងស្ទូង ឪពុករបស់ សុធា ឈរច្រត់ចង្កេះ ស្រាប់តែកងឈ្លបមកឃើញ ហើយក៏ស្រែកសំឡុតថា «ហ៊ានក្បត់សមូហភាពត្រូវបញ្ជូនមិត្តឯងទៅនៅកន្លែងថ្មី» ។ ទទួលបានដំណឹងនេះភ្លាម ម្តាយរបស់ សុធា បានទៅសុំអង្វរ តាទាវ ឲ្យប្តីមកនៅកងដាំបន្លែវិញ ដោយគាត់យកមាសមួយចំនួនដែលបានលាក់ទុកយូរហើយទៅឲ្យ តាទាវ ទៀតផង ។ ប៉ុន្តែទោះបីជាមានការយល់ព្រមហើយក៏ដោយ ក៏ តាទាវ បានដាក់ផែនការឲ្យម្តាយ សុធា «ត្រូវតែធ្វើការងារដកស្ទូងជំនួសប្តីឲ្យរួចរាល់សិន» ។ ដោយមិនចង់ឲ្យប្តីទៅធ្វើការនៅកន្លែងឆ្ងាយ ម្តាយរបស់ សុធា ខិតខំធ្វើការគ្រប់បែបយ៉ាងតាមបញ្ជារបស់អង្គការ ។

ចំណែក សុធា ដែលមានអាយុប្រហែលបួនឆ្នាំ និងប្អូនប្រុសត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅជាមួយយាយដែលនៅថែទាំក្មេងៗនៅក្នុងកងកុមារ ។ នៅទីនោះ សុធា រស់នៅជាមួយក្មេងតូចៗ

ប្រមាណ២០នាក់ និងយាយៗបីនាក់នៅលើផ្ទះចាស់មួយខ្នង នៅក្នុងភូមិខ្វយ ។ សុធា នៅចាំថា ថ្ងៃមួយពេលមេឃកំពុងភ្លៀង អង្គការមកហៅយាយរបស់គាត់ទៅប្រជុំនៅសហករណ៍ដោយដៃម្ខាងដឹកដៃ សុធា និងដៃម្ខាងទៀតដឹកដៃប្អូនប្រុស សុធា ទៅជាមួយដែរ ។ ពេលមកដល់ពាក់កណ្តាលផ្លូវ សុធា បានឃើញយាយរបស់គាត់យំ ប៉ុន្តែគាត់មិនយល់ថាមានរឿងអ្វីកើតឡើងនោះទេ ព្រោះគាត់នៅក្មេង ។ ប៉ុន្តែនៅពេលទៅដល់សហករណ៍ ទើបសុធាដឹងថាពូរបស់គាត់ឈ្មោះ ឃឹម ខុន ធ្វើជាគ្រូបង្រៀនផ្នែកគណិតវិទ្យាត្រូវបានអង្គការចាប់ខ្លួនហើយ ។

នៅពេលយប់មួយ ក្នុងឆ្នាំ១៩៧៧ ឪពុកម្តាយ សុធា បានលួចធ្វើដំណើរពីសហករណ៍មកមើលកូន ដោយគាត់ទាំងពីរលួចមាន់យកមកសោរក្នុងកំសៀវទឹកទៀតផង ។ បន្ទាប់ពីស្ងោរឆ្អិន ឪពុកម្តាយ សុធា បានយកមាន់ឲ្យ សុធា និងប្អូនៗហូបក្នុងមុង ព្រោះខ្លាចឈ្លបខ្មែរក្រហមដឹង ។ យប់នោះ សុធា ហូបមាន់ស្ទើរតែបែកពោះ ព្រោះគាត់មិនដែលបានហូបជាយូរណាស់មកហើយ ។

ព្រឹកឡើងអង្គការហៅឪពុករបស់ សុធា ទៅរៀនសូត្រ ដោយចោទថាគាត់ជាឋានៈអភិជន ព្រោះមានសំបុរសដូចកូនចៅចិន ។ ប៉ុន្តែពេលនោះអ្នកភូមិដែលរស់នៅភូមិជាមួយធានា ទើបអង្គការដោះលែងឲ្យត្រឡប់មកផ្ទះវិញ ។ មួយរយៈក្រោយមក អង្គការបានចាត់តាំងឪពុករបស់ សុធា ទៅដាំបន្លែនៅភូមិចម្ការលើ ខេត្តកំពង់ចាម ។ ប៉ុន្តែដោយសារនៅទីនោះ ឪពុក សុធា ធ្វើការងារធ្ងន់ធ្ងរទើបបណ្តាលឲ្យគាត់ឈឺក្អកធ្លាក់ឈាម និងឈឺស្ទេកស្ទាំង ។ ឃើញដូច្នេះអង្គការក៏បញ្ជូនគាត់ឲ្យទៅសម្រាកព្យាបាលនៅមន្ទីរតាំងគោករហូតជាសះស្បើយទើបអង្គការសម្រេចឲ្យគាត់ត្រឡប់មកវិញ ។ ចំណែកយាយរបស់ សុធា វិញ អង្គការមិនត្រឹមតែឲ្យគាត់មើលថែទាំក្មេងៗនោះទេ ថែមទាំងបន្ថែមការងារក្រៅម៉ោងឲ្យធ្វើទៀតផង ដោយក្នុងមួយថ្ងៃត្រូវតែដេរស្លឹកឲ្យបាន៥០ស្លឹក បើពុំដូច្នេះទេអង្គការនឹងដាក់ពិន័យជាមិនខាន ។

ថ្ងៃមួយ នៅពេលអង្គការរវល់ចែករបបអាហារទៅឲ្យប្រជាជនតាមសហករណ៍ យាយរបស់ សុធា ក៏ទៅលួចប្រមែប្រមូលស្រូវនៅក្នុងឃ្លាំងដាក់ក្នុងថ្នក់សំពត់មកបុកឲ្យចៅៗហូប ។ ក្រោយមកដោយសារស្រេកឃ្លាន និងខ្វះខាតអាហារកាន់តែខ្លាំង សុធា ក៏ពរប្អូនដើររើសធ្យូងយកហូបបន្ថែម ។ ឃើញដូច្នេះបងប្រុសរបស់សុធា ឈ្មោះ ឃឹម សុធី និងក្មេងៗជាច្រើនបាននាំគ្នាទៅលួចស្រូវនៅឃ្លាំង ប៉ុន្តែមិនយូរប៉ុន្មានអង្គការក៏តាមដានដឹង ។

ពីមួយថ្ងៃទៅមួយថ្ងៃ ជីវភាពរបស់ប្រជាជនរស់នៅក្នុងភូមិខ្វយកាន់តែលំបាក និងរឹតបន្តឹងយ៉ាងខ្លាំង ដោយរៀងរាល់យប់អង្គការតែងតែមកតាមដានប្រជាជនដល់ផ្ទះដើម្បីរកអ្នកណាដែលប្រឆាំងនឹងអង្គការទៅរៀនសូត្រ ។ នៅពេលនោះ ឪពុកម្តាយ សុធា ក៏អង្គការហៅទៅរៀនសូត្រដែរ ប៉ុន្តែបានដោះលែងមកវិញ ដោយរកមិនឃើញពីកំហុសរបស់គាត់ ។ ចំណែកអ៊ំរបស់គាត់ម្នាក់បានបាត់ខ្លួនរហូត ហើយក្រោយមកទើបដឹងថាឈ្លបយកទៅសម្លាប់បាត់ហើយ ។

នៅចុងឆ្នាំ១៩៧៧ បងប្អូន សុធា ទាំងអស់រស់នៅជាមួយយាយ ហើយមួយរយៈក្រោយមក អង្គការក៏បំបែកគាត់ឲ្យធ្វើការនៅកន្លែងផ្សេង ។ នៅទីនោះ អង្គការបង្ខំឲ្យបង សុធា ដើររើសអាចម៍គោឲ្យគ្រប់ផែនការកំណត់ទើបអនុញ្ញាតឲ្យឈប់សម្រាក ។

រហូតដល់កងទ័ពវៀតណាមវាយចូលឆ្នាំ១៩៧៩ សុធា ឃើញប្រជាជននៅក្នុងភូមិជាច្រើនប្រញាប់ប្រញាល់រៀបចំអីវ៉ាន់ត្រឡប់ទៅកាន់ស្រុកកំណើតរបស់គេវិញ ។ ចំណែកឪពុកម្តាយគាត់ក៏យកបានរទេះគោមួយ រួចហើយនាំក្រុមគ្រួសារធ្វើដំណើរមកដល់ភូមិត្រពាំងវែងវិញ ។ សុធា ចូលរៀននៅសាលាបឋមសិក្សានៅត្រពាំងវែង និងនៅវិទ្យាល័យកំពង់ធំរហូតប្រឡងជាប់ផ្នែកគ្រូនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ សព្វថ្ងៃនេះ សុធា បង្រៀនផ្នែកប្រវត្តិសាស្ត្រនៅវិទ្យាល័យជាស៊ីមកំពង់ថ្ម ។ **ស៊ិន សុធីតា**


ឃឹម សុធា ពេលកំពុងផ្តល់បទសម្ភាសនៅវិទ្យាល័យជាស៊ីមកំពង់ថ្ម

# តើអ្វីជាអំពើប្រល័យពូជសាសន៍? តើអ្វីជាចំណុចខ្វះខាតនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍? តើត្រូវទប់ស្កាត់អំពើប្រល័យពូជសាសន៍ដោយរបៀបណា?

អនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានអនុម័តនៅទីក្រុងប៉ារីសនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ នៅក្នុងកិច្ចប្រជុំលើកទីបីនៃមហាសន្និបាតអង្គការសហប្រជាជាតិ ។ អនុសញ្ញានេះបានចូលជាធរមានជាងពីរឆ្នាំក្រោយមក គឺនៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១ បន្ទាប់ពីទទួលបានសច្ចាប័នដែលចាំបាច់ចំនួន២០ ។ ទោះបីជាអនុសញ្ញានេះមានសារសំខាន់សម្រាប់ផែនការទូទៅរបស់សន្ធិសញ្ញាសិទ្ធិមនុស្ស និងអាចទទួលស្គាល់បទបញ្ញត្តិជាច្រើនថាជាច្បាប់ប្រពៃណីអន្តរជាតិក៏ដោយ ក៏អនុសញ្ញានេះមានភាគីចូលរួមត្រឹមតែ១៤០ប្រទេសប៉ុណ្ណោះ ដែលជាចំនួនដ៏តិចតួចមួយ ។ នេះគឺជាព្រឹត្តិការណ៍សំខាន់មួយដែលបានប្រារព្ធទូទាំងពិភពលោកដើម្បីគម្រប់ខួបលើកទី៦០នៃការអនុម័តអនុសញ្ញានេះ ។ កាលពីមួយទសវត្សរ៍មុន មិនមានការចាប់អារម្មណ៍ច្រើនទៅលើព្រឹត្តិការណ៍នេះទេ ។ ប៉ុន្តែ ចំណាប់អារម្មណ៍ទៅលើអនុសញ្ញា និងទស្សនៈច្បាប់ស្តីពីអំពើប្រល័យពូជសាសន៍បានកើនឡើងជាលំដាប់ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះនៅពេលដែលអនុសញ្ញានេះគឺជាផ្នែកមួយនៃសកម្មភាពច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ប្រាំឆ្នាំមុន មានការចេញសេចក្តីសម្រេចរបស់តុលាការស្តីពីអំពើប្រល័យពូជសាសន៍សំខាន់ជាងកាលពី៥០ឆ្នាំមុនទៅទៀត ។

នៅពេលជាមួយគ្នានេះដែរ សារសំខាន់ផ្នែកច្បាប់ស្តីពីអំពើប្រល័យពូជសាសន៍ដែលជាបាតុភូតមួយទាក់ទងនឹងការរីករាលដាលជាលំដាប់នូវក្រុមនៃបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានធ្លាក់ចុះ ។ បច្ចុប្បន្ន មានបទល្មើសតិចតួចប៉ុណ្ណោះដែលត្រូវបានកំណត់ថាជាអំពើប្រល័យពូជសាសន៍ ដែលជាបទល្មើសមួយដែលមានសណ្ឋានធំជាងនិងអាចបត់បែនបានជាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប៉ុន្តែ ចំពោះជនរងគ្រោះ ការបកស្រាយពីការធ្វើទុក្ខបុកម្នេញថាជាអំពើប្រល័យពូជសាសន៍ជាការគោរពមួយ ហើយការបដិសេធមិនបកស្រាយបែបនោះគឺជាការធ្វេសប្រហែសមួយ ។ ករណីបច្ចុប្បន្នដែលកើតឡើងដ៏គួរឲ្យចាប់អារម្មណ៍គឺសហព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិកំពុងធ្វើការចោទប្រកាន់ទៅលើប្រធានាធិបតីស៊ូដង់នៅក្នុងអង្គបុរេជំនុំជម្រះលើកទីមួយ ។

អ្នករៀបចំការពិភាក្សាបានស្នើឲ្យមានការដោះស្រាយលើបញ្ហា «ចំណុចខ្វះខាត» នៃអនុសញ្ញាប្រល័យពូជសាសន៍ ។ នេះជាការរំឭកមួយនូវអ្វីដែលមនុស្សជាតិបានធ្វើនៅក្នុងវិស័យអប់រំនិងការសិក្សាអស់រយៈពេលជាង៦០ឆ្នាំកន្លងមកហើយក្នុងការស្នើឲ្យមានការធ្វើវិសោធនកម្មទៅលើអនុសញ្ញា និងពាក្យបណ្តឹងនានាដែលពិបាកនឹងដោះស្រាយជាយូរណាស់មកហើយ ។ ការពិភាក្សាបែបនេះបានមើលរំលងនូវបរិបទប្រវត្តិសាស្ត្រ និងសារសំខាន់នៃអនុសញ្ញាអំពើប្រល័យពូជសាសន៍ ។ នេះគឺជាអនុសញ្ញាសិទ្ធិមនុស្សនៃប្រព័ន្ធច្បាប់ទំនើបដំបូងគេ ដែលបានបញ្ឆាក់ពីទំនៀមទម្លាប់អន្តរជាតិសម្រាប់ការពារសិទ្ធិរស់រានមានជីវិត និងវត្តមាននៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ និងសាសនារបស់ក្រុមជនជាតិភាគតិច ។ អនុសញ្ញានេះបានបង្កើតគោលការណ៍សំខាន់ជាច្រើនទាក់ទងនឹងការធ្វើទុក្ខបុកម្នេញ និងការទប់ស្កាត់ ហើយអនុសញ្ញានេះត្រូវបានគេយកទៅប្រើប្រាស់ជាឧបករណ៍ផ្សេងនៅក្នុងស្ថាប័ននានា ។ មាត្រា៦បានបង្កើតចំណុចចាប់ផ្តើមនៃលក្ខន្តិកៈទីក្រុងរ៉ូម ។ បញ្ហានៃចំណុច «ខ្វះខាត» នៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ប្រៀបបីដូចជាការធ្វើការទស្សន៍ទាយទៅលើ «ដំណើរវិវឌ្ឍ» នៃគំនូររបស់ពីកាសូ ឬអត្ថបទរបស់ ម៉ាក អេនថូនី ឬភ្លេងបុណ្យខ្មោចរបស់សេចប្រហ្វាយ ឬប្រៀបដូចជាការសាកសួរថាតើគួរតែបន្ថែមគ្រឿងផ្សំថ្មីទៅលើស្រាក្រឡុកឬថាតើមានអ្នកណាអាចធ្វើឲ្យម្ហូបផាវអាំងរ៉ែកហ្វេលឡឺដោយយកសាច់មាន់ជំនួសវិញ ។ អនុសញ្ញាប្រល័យពូជសាសន៍គឺជាការវិវឌ្ឍមួយនៅក្នុងច្បាប់អន្តរជាតិ ការបញ្ឆាក់ពីគោលការណ៍ដ៏មានសារសំខាន់ ការឆ្លុះបញ្ចាំងនូវតម្លៃនិងស្តង់ដារមួយ ព្រមទាំងទស្សនៈដ៏ច្បាស់មួយ

សម្រាប់ដើរតាម ។ វាមិនមានចំណុចខ្វះខាតអ្វីឡើយ ។

អំពើប្រល័យពូជសាសន៍គឺជាទស្សនៈច្បាប់មួយ ។ ក៏ដូចជាការសម្លាប់ ការរំលោភសេពសន្ថវៈ និងចោរកម្មដែរ អំពើប្រល័យពូជសាសន៍ក៏ត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងបរិបទផ្សេងនិងដោយការកំណត់ផ្សេងដែលធ្វើឲ្យអត្ថន័យមានភាពខុសប្លែកពីគ្នាដែរ ។ ប្រវត្តិវិទូ និងសង្គមវិទូបានបកស្រាយអំពើប្រល័យពូជសាសន៍ថាជាអំពើសាហាវឃោរឃៅមួយដែលមានជាប់ពាក់ព័ន្ធនឹងការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ។ ប៉ុន្តែនៅក្នុងច្បាប់ វាមិនមានភាពច្បាស់លាស់ក្នុងការលើកឡើងពីអត្ថន័យតែមួយនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានគេទទួលស្គាល់នៅលើពិភពលោកទេ ។ អំពើប្រល័យពូជសាសន៍មាននិយមន័យមួយដែលត្រូវបានទទួលស្គាល់និងមានចែងនៅក្នុងមាត្រា២នៃអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ដូចគ្នានឹងនិយមន័យច្បាប់ភាគច្រើនដែរ និយមន័យនៃអំពើប្រល័យពូជសាសន៍អាចត្រូវបានគេយកមកបកស្រាយខុសពីគ្នា ប៉ុន្តែបញ្ហាចម្រូងចម្រាសគឺវិសាលភាពនៃនិយមន័យរបស់ពាក្យប្រល័យពូជសាសន៍ ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានលាយជាមួយប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសជាច្រើន ហើយអ្នកបង្កើតច្បាប់ក្នុងស្រុកគឺជាអ្នកបកស្រាយនិយមន័យទៅតាមទស្សនៈរបស់ខ្លួន ។ អ្នកខ្លះធ្វើការបកស្រាយខុសគ្នាបន្តិចបន្តួចពីនិយមន័យ ដែលបង្កើតឡើងជាអន្តរជាតិ រីឯអ្នកខ្លះធ្វើការបកស្រាយខុសទាំងស្រុង ។ ជាលទ្ធផលសូម្បីតែនៅក្នុងច្បាប់ ក៏យើងអាចលើកឡើងពីនិយមន័យ ឬធ្វើការបកស្រាយទៅលើទស្សនៈនៃអំពើប្រល័យពូជសាសន៍ខុសគ្នាដែរ ។

ពាក្យប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដោយមេធាវីម្នាក់ដែលមានឈ្មោះថា រ៉ាហ្វែល លឹមគិន ។ គាត់មានបំណងបំពេញចំណុចខ្វះខាតរបស់ច្បាប់អន្តរជាតិបន្ទាប់មកពាក្យប្រល័យពូជសាសន៍នេះបានលេចរូបរាងឡើងនៅថ្ងៃបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ ។ អស់រយៈពេលជាងពីរទសវត្សរ៍ លឹមគិន បានធ្វើការទាក់ទងនឹងកិច្ចការងារក្នុងកម្រិតអន្តរជាតិដើម្បីកំណត់ក្រុមនៃឧក្រិដ្ឋកម្មអន្តរជាតិ ដែលពាក់ព័ន្ធនឹងអំពើសាហាវឃោរឃៅប្រឆាំងនឹងប្រជាជនស៊ីវិលដែលងាយនឹងទទួលគ្រោះថ្នាក់ ។ នៅមុនពេល លឹមគិន បង្កើតនិយមន័យនោះ ច្បាប់អន្តរជាតិបានទទួលស្គាល់ឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនតូចប៉ុណ្ណោះ ។ នៅក្នុងវិធានទូទៅ ឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានគាត់តែងឡើង មិនមែនដោយសារតែទំហំនៃភាពសាហាវឃោរឃៅនិងការរីករាលដាលនៃឧក្រិដ្ឋកម្មប៉ុណ្ណោះទេ គឺដោយសារតែឧក្រិដ្ឋកម្មនោះហួសពីយុត្តាធិការរបស់ប្រទេសដែលបានជួបបញ្ហានេះ ។ ការប្លន់តាមសមុទ្រ គឺជាឧទាហរណ៍មួយនៃឧក្រិដ្ឋកម្មប្រព្រឹត្តនៅលើផ្ទៃសមុទ្រ ។ លឹមគិន និងអ្នកដទៃទៀតបានធ្វើការអះអាងដោយប្រើទស្សនៈផ្សេងគ្នាដើម្បីស្នើឲ្យមានការទទួលស្គាល់ឧក្រិដ្ឋកម្មអន្តរជាតិដែលតំណាងឲ្យការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ។

ការចាប់ផ្តើមនេះបានចេញជារូបរាងច្បាស់នៅអំឡុងសង្គ្រាមលោកលើកទីមួយគឺនៅពេលដែលប្រទេសអង់គ្លេស បារាំង និងរុស្ស៊ីបានព្រមានថាខ្លួននឹងដាក់ឲ្យជនដៃដល់ទទួលខុសត្រូវចំពោះ «ឧក្រិដ្ឋកម្មថ្មីដែលប្រទេសទួគីបានប្រព្រឹត្តទៅលើជនស៊ីវិល» ។ ប៉ុន្តែទស្សនៈដែលថាប្រទេសមួយត្រូវទទួលខុសត្រូវចំពោះអំពើសាហាវឃោរឃៅដែលបានធ្វើទៅលើប្រជាជនខ្លួនឯងជាបញ្ហាចម្រូងចម្រាសមួយ ដូច្នេះនេះគឺជាចំណុចខ្វះខាតនៅក្នុងច្បាប់ដែល លឹមគិន ត្រូវបំពេញ ។ សំណើដំបូងរបស់ លឹមគិន បានបង្ហាញពីទស្សនៈនៃអំពើប្រល័យពូជសាសន៍ទូលាយជាងអ្វីដែលមានចែងនៅក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ។ លឹមគិន បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចចរចាដែលនាំទៅរកការអនុម័តរបស់អនុសញ្ញា ប៉ុន្តែខណៈពេលដែលលទ្ធផលមិនដូចនឹងអ្វីដែលគាត់ចង់បាន លឹមគិន នៅតែធ្វើការជាមួយដើម្បីកំណត់និយមន័យរបស់អនុសញ្ញានោះទៀត ។ ជាងនេះទៅទៀត បន្ទាប់ពីអនុសញ្ញានោះត្រូវបានអនុម័ត គាត់បានធ្វើយុទ្ធនាការដោយស្នើសុំសច្ចាប័ន ។

សំណើដ៏ល្បីល្បាញរបស់ លឹមគិន រួមមានជំពូកមួយដែលមានចំណងជើងថា «អំពើប្រល័យពូជសាសន៍» ។ នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា *“Axis Rule in Occupied Europe”* លឹមគិន បានស្នើឲ្យមាន «ការដាក់កំហិត» មិនឲ្យមានអំពើប្រល័យពូជសាសន៍នៅក្នុងសង្គ្រាម និងស្នើឲ្យមានសន្តិភាព ។ លឹមគិន បានចងភ្ជាប់ទំនាក់ទំនងរវាងអំពើប្រល័យពូជសាសន៍និងបង្កើនផលប្រយោជន៍សម្រាប់ការការពារប្រជាជន

និងប្រជាជនភាគតិចដែលត្រូវបានគេលើកឡើងនៅក្នុងសន្ធិសញ្ញា និងការប្រកាសខ្លះដែលត្រូវបានអនុម័តបន្ទាប់ពីសង្គ្រាមលោកលើកទីមួយ ។ លឹមគិន បានលើកឡើងពីភាពចាំបាច់សម្រាប់កែប្រែឧបករណ៍ច្បាប់អន្តរជាតិ ដោយលើកឡើងពីភាពខ្វះខាតរបស់អនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៩៧ដែលក្នុងនោះមិនមានរួមបញ្ចូលការការពារប្រជាជនទេ ។ ដូច្នេះ យោងទៅតាម លឹមគិន និយមន័យអំពើប្រល័យពូជសាសន៍នៅក្នុងបទបញ្ញត្តិទីក្រុងឡាអេ គួរតែមានផ្នែកសំខាន់ពីរគឺ ៖ ទីមួយគួរតែរួមបញ្ចូលរាល់សកម្មភាពបំពារបំពានទៅលើជីវិត សេរីភាព សុខភាព បូរណភាពរូបរាងកាយ វត្ថុមាននៃសេដ្ឋកិច្ច និងការគោរពដល់ប្រជាជនពីព្រោះអ្នកទាំងនោះ គឺជាក្រុមជាតិ សាសនា ឬពូជសាសន៍ ហើយទីពីរគួរតែរួមបញ្ចូលគោលនយោបាយនីមួយៗដែលមានបំណងបំផ្លិចបំផ្លាញ ឬដើម្បីគ្រប់គ្រងទៅលើក្រុមណាមួយក្នុងគោលបំណងធ្វើបាបក្រុមនោះ ។

## អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ទស្សនៈច្បាប់នៃអំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងនៅក្រោយសង្គ្រាមលោកលើកទីពីរដើម្បីកាត់ទោសអំពើព្រៃផ្សៃរបស់ណាហ្ស៊ី ។ ការវិវឌ្ឍរបស់ទស្សនៈច្បាប់នេះកើតឡើងជាមួយនឹងការវិវឌ្ឍរបស់ឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតជាពិសេសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានទំនាក់ទំនងជិតស្និទ្ធប៉ុន្តែស្មុគស្មាញនិងពិបាកយល់ ។ យើងនឹងមិនយល់ពីការវិវឌ្ឍន៍ និងប្រវត្តិសាស្ត្រស្តីពីអំពើប្រល័យពូជសាសន៍ក្នុងទស្សនៈច្បាប់ ប្រសិនបើយើងមិនបានពិចារណាទៅលើវត្ថុមានរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ទោះបីជាអ្នកចូលរួមគណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិដែលបានបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ១៩៤៣ និងសន្និសីទនៅទីក្រុងឡុនដុនកាលពីចុងខែមិថុនា ដល់ដើមខែសីហា ឆ្នាំ១៩៤៥ ដើម្បីរៀបចំតុលាការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាមនៅនូរ៉ែមប៊ើកបានជ្រើសរើសពាក្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដើម្បីធ្វើការចោទប្រកាន់ក៏ដោយ ក៏គេបានចាត់ទុកថាពាក្យប្រល័យពូជសាសន៍មានន័យស្រដៀងនឹងគ្នាដែរ ។ នៅក្នុងអនុស្សរណៈផែនការដែលផ្ញើឲ្យគណៈប្រតិភូនៅសន្និសីទនៅទីក្រុងឡុនដុនកាលពីខែមិថុនា ឆ្នាំ១៩៤៥ ដែលលោក ចាស៊ីស រ៉ូប៊ឺត ជែកសុន បានលើកពីភស្តុតាងដើម្បីយកទៅអះអាងនៅក្នុងតុលាការនៅនូរ៉ែមប៊ើក លោក ជែកសុន បានរៀបរាប់ពីអំពើប្រល័យពូជសាសន៍ ឬការបំផ្លាញក្រុមពូជសាសន៍ ឬការគ្រប់គ្រងទៅលើក្រុមប្រជាជនដោយមធ្យោបាយ ១) មិនផ្តល់អាហារគ្រប់គ្រាន់ ២) រារាំងមិនឲ្យមានការបង្កកំណើត ៣) ដកហូតនូវសម្លៀកបំពាក់ ទីជម្រក ម្ហូបអាហារ ការថែទាំសុខភាព និងអនាម័យ ៤) និរទេសឲ្យធ្វើការងារធ្ងន់ ៥) បង្ខំឲ្យធ្វើការនៅក្នុងស្ថានភាពមិនល្អ ។

តុលាការយោធាអន្តរជាតិបានចោទប្រកាន់ចុងចោទណាហ្ស៊ីពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយចេតនានិងជាប្រព័ន្ធដែលរួមមានការសម្លាប់ផុតពូជនូវក្រុមជាតិ និងពូជសាសន៍ប្រឆាំងនឹងប្រជាជនស៊ីវិលដែលរស់នៅក្នុងតំបន់ជាក់លាក់មួយ ដើម្បីកម្ចាត់ពូជសាសន៍និងវណ្ណៈរបស់ប្រជាជន និងក្រុមជាតិពូជសាសន៍ ឬសាសនា ដូចជាជនជាតិជ្វីហ្វ ជនជាតិប៉ូឡូញ និងជីបស៊ីស៍ ។ ពាក្យប្រល័យពូជសាសន៍ជានិច្ចកាលត្រូវបានព្រះរាជអាជ្ញាយកមកប្រើប្រាស់នៅអំឡុងពេលជំនុំជម្រះក្តី ។ លោក ដេវីឌ ម៉ាកស៍វេលហ្វាយ ដែលជាព្រះរាជអាជ្ញាជនជាតិអង់គ្លេសបានរំឭកដល់ វ៉ុន ណឺរាដ ដែលជាជនត្រូវចោទថា ជននោះត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ដែលយើងហៅថាការសម្លាប់ផុតពូជនូវ ក្រុមជាតិនិងពូជសាសន៍ ហើយបើតាមសៀវភៅដ៏ល្បីឈ្មោះរបស់លោកសាស្ត្រាចារ្យ លឹមគិន «វាគឺជាផែនការដែលបានរៀបចំទុកសម្រាប់បំផ្លាញទាំងស្រុងនូវក្រុមជាតិ» ។ ក្រោយមក លឹមគិន បាននិយាយថា «ភស្តុតាងនៅក្នុងសវនាការបានឆ្លើយតបទាំងស្រុងនឹងករណីប្រល័យពូជសាសន៍» ។

ទោះបីជាយ៉ាងណាក៏ដោយ ធម្មនុញ្ញតុលាការយោធាអន្តរជាតិមិនបានប្រើប្រាស់ពាក្យប្រល័យពូជសាសន៍ទេ ហើយពាក្យនេះក៏មិនបានលេចឡើងនៅក្នុងសេចក្តីសម្រេចចុងក្រោយដែលចេញនៅថ្ងៃទី៣០ ខែកញ្ញា និងថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ ដែរ ។ ដូចដែលបានកំណត់ដោយតុលាការនៅនូរ៉ែមប៊ើក ទស្សនៈច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានដែនកំណត់ជាក់លាក់មួយ គឺថាពាក្យប្រល័យពូជសាសន៍ត្រូវបានកំណត់ទំហំមកត្រឹមជាអំពើព្រៃផ្សៃដែលប្រព្រឹត្តឡើងនៅក្នុងសង្គ្រាម ។ ពាក្យប្រល័យ

ពូជសាសន៍ត្រូវបានបង្កើតឡើងទៅតាមចេតនារបស់អ្នកព្រាងបទបញ្ញត្តិច្បាប់គ្រប់គ្រងទៅលើការចោទប្រកាន់ ជាពិសេសមហាអំណាចទាំងបួនគឺ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស បារាំង និងសហភាពសូវៀត ។ ជាងនេះទៅទៀត ការពង្រីកច្បាប់អន្តរជាតិពីឧក្រិដ្ឋកម្មសង្គ្រាមមានជាប់ពាក់ព័ន្ធនឹងបទល្មើសសង្គ្រាមនិងទម្រង់ផ្សេងៗនៃការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនស៊ីវិលនៅក្នុងតំបន់ដែលខ្លួនកាន់កាប់ ដូច្នេះទើបអាចគ្របដណ្តប់លើអំពើសាហាវឃោរឃៅដែលប្រព្រឹត្តដោយរដ្ឋាភិបាលប្រឆាំងនឹងប្រជាជនស៊ីវិល និងគំរាមដល់ប្រទេសដែលកំពុងតែរៀបចំការធ្វើទុក្ខបុកម្នេញ ។ ភាពខុសប្លែកគ្នាត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់ដោយគណៈប្រតិភូសហរដ្ឋអាមេរិក ចាស៊ីស រ៉ូបឺត ជែកសុន នៅក្នុងកិច្ចប្រជុំនៅសន្និសីទនៅទីក្រុងឡុនដុនកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៤៥ ថា៖




គោលការណ៍ទូទៅនៃគោលនយោបាយបរទេសរបស់រដ្ឋាភិបាលគឺថាកិច្ចការផ្ទៃក្នុងរបស់រដ្ឋាភិបាលផ្សេងមិនមែនជាកិច្ចការរបស់យើងទេ ។ នេះមានន័យថា ការដែលប្រទេសអាល្លឺម៉ង់ធ្វើទៅលើប្រជាពលរដ្ឋរបស់ខ្លួន ឬការដែលប្រទេសផ្សេងធ្វើទៅលើប្រជាជនខ្លួនឯង មិនមែនជាការងាររបស់យើងទៀតទេ វាគឺជាកិច្ចការរបស់រដ្ឋាភិបាលដែលមានជាប់ពាក់ព័ន្ធនឹងបញ្ហានោះ ។ ហេតុផលដែលថា ការសម្លាប់ផុតពូជជនជាតិជ្វីហ្វនិងការរំលោភសិទ្ធិរបស់ក្រុមជនជាតិភាគតិចក្លាយទៅជាការព្រួយបារម្ភរបស់អន្តរជាតិគឺដោយសារតែវាគឺជាផ្នែកមួយនៃផែនការបង្កើតសង្គ្រាមខុសច្បាប់ ។ ទាល់តែយើងមានសង្គ្រាមដែលជាប់ពាក់ព័ន្ធជាមួយប្រទេសណាមួយដើម្បីយកធ្វើជាមូលហេតុ ខ្ញុំនឹងគិតថាយើងមិនមានមូលដ្ឋានសម្រាប់ដោះស្រាយទេ ។ នោះគឺជាផ្នែកមួយនៃការរៀបចំសង្គ្រាម ឬការអនុវត្តសង្គ្រាមដូចដែលបានកើតឡើងនៅក្នុងប្រទេសអាល្លឺម៉ង់ ដូច្នេះបញ្ហានេះបានក្លាយទៅជាការព្រួយបារម្ភរបស់យើង ។

លោក ចាស៊ីស រ៉ូបឺត ជែកសុន បាននិយាយអំពីឧក្រិដ្ឋកម្មនៃការសម្លាប់ ការធ្វើទុក្ខបុកម្នេញ និងការនិរទេសដោយហេតុផលនយោបាយ

ពូជសាសន៍ ឬសាសនាដែលអាចហៅថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ហើយលោកបានបង្ហាញពីប្រភពនៃការព្រួយបារម្ភរបស់រដ្ឋាភិបាលរបស់លោកថា ៈ

តាមធម្មតា យើងមិនពិចារណាថាសកម្មភាពរបស់រដ្ឋាភិបាលទៅលើប្រជាពលរដ្ឋខ្លួនឯងថាជាការជ្រៀតជ្រែករបស់យើងទេ ។ យើងធ្លាប់ជួបប្រទះស្ថានភាពគួរឲ្យសោកស្តាយកើតឡើងនៅក្នុងប្រទេស ដែលនៅពេលនោះប្រជាជនភាគតិចនៅក្នុងប្រទេសត្រូវទទួលការធ្វើបាប ។ យើងគិតថាជាការស្របច្បាប់ដែលយើងធ្វើអន្តរាគមន៍ឬព្យាយាមផ្តល់យុត្តិធម៌តាមរយៈការកាត់ទោសដល់បុគ្គល ឬ ប្រទេសណាមួយពីព្រោះដំរិប្រមូលផ្តុំនិងការនិរទេសគឺដើរទៅតាមផែនការមួយឬការបង្កើតសង្គ្រាមខុសច្បាប់ដែលធ្វើឲ្យយើងមានជាប់ពាក់ព័ន្ធ ។ យើងមិនមានមូលដ្ឋានផ្សេងដែលអាចឲ្យយើងជ្រៀតជ្រែកលើអំពើសាហាវយោរយៅដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសអាល្លឺម៉ង់ក្រោមច្បាប់អាល្លឺម៉ង់ ឬសូម្បីការរំលោភទៅលើច្បាប់អាល្លឺម៉ង់ដោយអាជ្ញាធរប្រទេសអាល្លឺម៉ង់ទេ ។

មិនមានអ្វីគួរឲ្យសង្ស័យឡើយថា ប្រទេសអង់គ្លេស បារាំង និង សូវៀត មានមូលហេតុផ្ទាល់ខ្លួន ដែលធ្វើឲ្យប្រទេសទាំងនេះមានបញ្ហាដូចគ្នា ។ សរុបមក និយមន័យនៃពាក្យថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា៦(C) នៃរដ្ឋធម្មនុញ្ញនូរ៉េមប៊ើកទាមទារឲ្យអំពើសាហាវយោរយៅទាំងឡាយនោះត្រូវបានប្រព្រឹត្តឡើង «ដោយមានការជួយជ្រោមជ្រែង ឬ មានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការអន្តរជាតិ» ។ នៅក្នុងសាលក្រមចុងក្រោយរបស់ខ្លួន តុលាការយោធាអន្តរជាតិបានធ្វើការបែងចែករវាងការធ្វើទុក្ខបុកម្នេញទៅលើពួកជ្វីហ្វអាល្លឺម៉ង់ ដែលមានលក្ខណៈ «ធ្ងន់ធ្ងរនិងគាបសង្កត់ខ្លាំង» និងគោលនយោបាយរបស់អាល្លឺម៉ង់អំឡុងពេលសង្គ្រាមទៅលើតំបន់ដែលស្ថិតនៅក្រោមការគ្រួតត្រារបស់ខ្លួន ។ ទោះបីជាសេចក្តីសម្រេចនេះសំដៅទៅលើព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងអំឡុងទសវត្សរ៍៣០ ក៏មិនមានជនសង្ស័យណាម្នាក់ត្រូវបានរកឃើញថាមានទោសពីអំពើដែលបានប្រព្រឹត្តឡើងមុនខែកញ្ញា ឆ្នាំ១៩៣៩ ដែលជាពេលសង្គ្រាមផ្ទុះឡើងដែរ ។

ក្រោយពីមានសេចក្តីសម្រេចនេះ មានការផ្ទុះឡើងយ៉ាងធ្ងន់ធ្ងរអំពីការដាក់កម្រិតទៅលើទស្សនៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ជាសមាជិកម្នាក់នៅក្នុងក្រុមព្រះរាជអាជ្ញានូរ៉េមប៊ើក ហិនរី ឃីង បានធ្វើការពិពណ៌នាអំពីជំនួបគ្នារបស់គាត់ជាមួយនឹងលោក រ៉ាហ្វែល លឹមគិន នៅបន្ទប់ទទួលភ្ញៀវនៅសណ្ឋាគារហ្គ្រេនហូតែលនៅទីក្រុងនូរ៉េមប៊ើកនៅខែតុលាឆ្នាំ១៩៤៦ ពីរបីថ្ងៃបន្ទាប់ពីតុលាការយោធាអន្តរជាតិបានបំពេញការងាររបស់ខ្លួនស្រេចបាច់យ៉ាងដូច្នេះថាៈ

ពេលដែលខ្ញុំបានជួបគាត់នៅនូរ៉េមប៊ើក លឹមគិន មើលទៅដូចជាមានការអន់ចិត្តជាខ្លាំង ។ គាត់មានការព្រួយបារម្ភថា តុលាការយោធាអន្តរជាតិ (តុលាការនូរ៉េមប៊ើក) មិនបានធ្វើដំណើរទៅឲ្យបានឆ្ងាយគ្រប់គ្រាន់ក្នុងការដោះស្រាយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ ។ នេះក៏ព្រោះតែតុលាការយោធាអន្តរជាតិបានកំណត់ការសម្រេចរបស់ខ្លួនត្រឹមតែអំពើប្រល័យពូជសាសន៍នៅក្នុងពេលសង្គ្រាម តែមិនបានបញ្ចូលអំពើប្រល័យពូជសាសន៍នៅក្នុងពេលសន្តិភាពទេ ។ នៅពេលនោះ លឹមគិន ពិតជាព្យាយាមជំរុញឲ្យខ្ញុំស្តាប់ការបកស្រាយរបស់គាត់ ។ ពេលនោះ ខ្ញុំត្រូវតែប្រាប់គាត់ថា ខ្ញុំគ្មានអំណាចទៅធ្វើអ្វីមួយពីរឿងការកម្រិតទោសនៅក្នុងសាលក្រមនោះទេ ។

សេចក្តីខកបំណងនោះបានសម្តែងចេញមកដោយខ្លួនឯងនៅពេលដែលមានការប្រជុំនៅមហាសន្និបាតអង្គការសហប្រជាជាតិនៅទីក្រុងឡុនដុននៅពេលនោះ ។ ប្រទេសឥណ្ឌា គុយបា និងប៉ាណាម៉ា បានធ្វើការសម្រេចជាផ្លូវការមួយដើម្បីដោះស្រាយភាពខ្វះខាតរបស់សវនាការនូរ៉េមប៊ើកនេះ ដោយកំណត់ថា អំពើទាំងឡាយណាដែលប្រព្រឹត្តឡើងមុនសង្គ្រាមនឹងត្រូវទុកចោលមិនយកមកធ្វើការវិនិច្ឆ័យទេ ។ នៅក្នុងកថាខណ្ឌដំបូងរបស់សេចក្តីព្រាងបានបញ្ជាក់ថាៈ «អាស្រ័យហេតុនេះ ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដ៏ធ្ងន់ធ្ងរ ដែលប្រព្រឹត្តនៅក្នុងពេលសន្តិភាពស្ថិតនៅក្នុងយុត្តាធិការកំណត់មួយដាច់ដោយឡែកនៅក្នុងតុលាការនៃរដ្ឋដែលពាក់ព័ន្ធ ។ ផ្ទុយពីឧក្រិដ្ឋកម្មដែលមានទំហំតូចជាងនេះដូចជា ការឆក់ប្លន់ ការជួញដូរស្ត្រី កុមារ គ្រឿងញៀន ការបោះពុម្ពផ្សាយរឿងអាសអាភាសត្រូវបានចាត់ចូលជាឧក្រិដ្ឋកម្ម

អន្តរជាតិ និងត្រូវបានចាត់ទុកជាបញ្ហារបស់អន្តរជាតិ...» ។

សេចក្តីសម្រេចនេះមិនដែលត្រូវបានសម្រេចឲ្យក្លាយជាសេចក្តីសម្រេចចុងក្រោយនៃសេចក្តីសម្រេច៩(I) ដែលបានសម្រេចនៅខែធ្នូ ឆ្នាំ១៩៤៦ ដោយសារតែសមាជិកសន្និបាតភាគច្រើនមិនបានរៀបចំក្នុងការទទួលយកយុត្តាធិការសកលចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ ។ ទោះបីជាយ៉ាងនេះក៏ដោយ សេចក្តីសម្រេចនេះទម្លាក់សេចក្តីសង្ឃឹមរបស់អ្នកដែលបានចាប់ផ្តើមធ្វើកាលពីដំបូងបានចាប់ផ្តើមដំណើរការដែលសម្រេចពីរឆ្នាំក្រោយមកដោយការបង្កើតនូវសន្ធិសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សំណើឲ្យដាក់សន្ធិសញ្ញាប្រល័យពូជសាសន៍ ជាសំអាងយោងទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាជាទស្សនៈមានការទំនាក់ទំនងគ្នា ឬជាន័ត្រមួយទូលាយដែលអាចឲ្យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចជ្រកជ្រៀតបាននោះត្រូវបានបដិសេធចោលដោយអ្នកធ្វើសេចក្តីព្រាង ដើម្បីកុំឲ្យមានការច្របូកច្របល់អំពីរឿងដែលថាអំពើប្រល័យពូជសាសន៍អាចប្រព្រឹត្តឡើងនៅក្នុងពេលសន្តិភាពក៏ដូចជាក្នុងពេលសង្គ្រាម ។ នេះមិនអាចនិយាយឲ្យច្បាស់លាស់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនាពេលនោះទេ ជាក់ស្តែងដោយ ហេតុតែមានតុលាការនូរ៉ឹមប៊ើកពីមុនមក ។

ហេតុនេះ ការទទួលស្គាល់អំពើប្រល័យពូជសាសន៍ថាជាឧក្រិដ្ឋកម្មអន្តរជាតិដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៦ ហើយនិងការប្រមូលជាក្រុមសន្ធិសញ្ញានៅឆ្នាំ១៩៤៨ អាចត្រូវបានយល់ថាជាប្រតិកម្មទៅនឹងច្រកចង្អៀតទៅកាន់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងសាលក្រមនូរ៉ឹមប៊ើកនៃតុលាការយោធាអន្តរជាតិ ។ នេះគឺជាបរាជ័យរបស់តុលាការនូរ៉ឹមប៊ើកក្នុងការទទួលស្គាល់ថាឧក្រិដ្ឋកម្មដ៏សាហាវយោរយៅនេះជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងពេលសន្តិភាព និងដែលធ្វើឲ្យមានការផ្តួចផ្តើមគំនិតនៅក្នុងការទទួលស្គាល់និងកំណត់និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ប្រសិនបើតុលាការនូរ៉ឹមប៊ើកអាចអះអាងថា អំពើឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងពេលសន្តិភាពពិតជាបានចាត់ចូលទៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិមែនអនុសញ្ញាអំពើប្រល័យពូជសាសន៍ក៏ប្រហែលជាមិនបានសម្រេចបង្កើតដែរ ។ ពាក្យថា «អំពើប្រល័យពូជសាសន៍» ប្រហែលជានឹងនៅតែជាពាក្យដ៏មានប្រជាប្រិយឬពាក្យដែលមិនផ្លូវការប្រើប្រាស់ដោយអ្នកកាសែត អ្នកប្រវត្តិសាស្ត្រ និងអ្នកវិទ្យាសាស្ត្រសង្គមប៉ុណ្ណោះ ប៉ុន្តែប្រហែលជាមិនមានវត្តមាននៅក្នុងការប្រើប្រាស់ផ្នែកផ្លូវច្បាប់ទេ ។

## អនុសញ្ញាអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨

អនុសញ្ញានៃការការពារទប់ស្កាត់និងការដាក់ទណ្ឌកម្មទៅលើអំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដោយសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ ។ អនុសញ្ញានេះបានឲ្យនិយមន័យអំពើប្រល័យពូជសាសន៍យ៉ាងដូច្នេះថា ៖

នៅក្នុងអនុសញ្ញាបច្ចុប្បន្ន អំពើប្រល័យពូជសាសន៍មានន័យថាអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងស្រុងឬដោយផ្នែកនៃជាតិជាតិពន្ធុ ពូជសាសន៍ ឬក្រុមសាសនាណាមួយដូចជាៈ

ក) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

ខ) ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម

គ) ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក ។

ឃ) ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក ។

ង) ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅឲ្យក្រុមមួយទៀត ។

និយមន័យនេះត្រូវបានចាត់ទុកថា មានភាពចង្អៀតជាងនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលអាចអនុវត្តទៅលើអំពើធ្វើទុក្ខបុកម្នេញទាំងឡាយណានិងអំពើឧក្រិដ្ឋកម្មផ្សេងៗទៀតដែលបានប្រព្រឹត្តឡើងប្រឆាំងនឹង «ជនស៊ីវិល» ។ ផ្ទុយទៅវិញ និយមន័យនៃពាក្យនេះមានអត្ថន័យទូលំទូលាយជាង ដោយសារតែពាក្យនេះគ្មានតម្រូវការក្នុងការភ្ជាប់ន័យទៅនឹងសង្គ្រាមឈ្លានពាន ។

ក្រៅពីការកំណត់និយមន័យឧក្រិដ្ឋកម្ម អនុសញ្ញានេះ

បានបង្ខំរដ្ឋទាំងឡាយណាដែលបានចុះហត្ថលេខាអនុវត្តនូវកាតព្វកិច្ចមួយចំនួន ។ រដ្ឋទាំងឡាយនោះត្រូវបានតម្រូវឲ្យធ្វើការអនុម័តនូវច្បាប់ដាក់ទណ្ឌកម្មទៅលើអ្នកដែលបានប្រព្រឹត្តបទល្មើសប្រល័យពូជសាសន៍នៅលើទឹកដីរបស់ខ្លួន ។ ច្បាប់នេះមិនត្រូវអនុញ្ញាតឲ្យអ្នកប្រព្រឹត្តបទល្មើសការពារខ្លួនដោយលើកហេតុផលថា ខ្លួនប្រព្រឹត្តអំពើទាំងនោះជាផ្លូវការនោះទេ ។ ប្រទេសទាំងនោះក៏ត្រូវបានតម្រូវឲ្យធ្វើការសហការក្នុងការធ្វើបត្យាប័នប្រគល់អ្នកដែលសង្ស័យថាប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅទឹកដីណាផ្សេង ហើយមកសុំការស្នាក់នៅក្នុងទឹកដីរបស់ប្រទេសដែលចុះហត្ថលេខាទៅប្រទេសនោះវិញ ។ ប្រទេសទាំងឡាយនោះមិនគួរចាត់ទុកអំពើប្រល័យពូជសាសន៍ថាជាឧក្រិដ្ឋកម្មផ្នែកនយោបាយដែលក្លាយជារនាំងមួយចំពោះការធ្វើបត្យាប័នឡើយ ។ ជម្លោះរវាងរដ្ឋនិងរដ្ឋអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នឹងបញ្ជូនទៅចាត់ការក្រោមយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ ។

ចំណងជើងរបស់អនុសញ្ញានេះបានបញ្ជាក់អំពីការការពារនិងទប់ស្កាត់ ប៉ុន្តែក្រៅពីការទទួលយល់ព្រមដោយមិនបង្អង់ក្នុងការការពារ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ មិនមានមាត្រាណាមួយបញ្ជាក់ពីទំហំនៃកាតព្វកិច្ចដែលអនុសញ្ញាកំណត់ឲ្យធ្វើឡើយ ។ នៅឆ្នាំ២០០៧ នៅក្នុងសំណុំរឿងមួយ ដែលប្តឹងដោយប្រទេសបូស្នៀ និងហែហ្សេហ្គូវីណា ប្រឆាំងនឹង ស៊ែប តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់ថា អនុសញ្ញាអំពើប្រល័យពូជសាសន៍នេះនៅមានចន្លោះប្រហោងដោយសារតែ ស៊ែប មិនបានធ្វើអន្តរាគមន៍ជាមួយនឹងសម្ព័ន្ធមិត្តរបស់ខ្លួនគឺ បូស្នៀ-ស៊ែប ដើម្បីទប់ស្កាត់ការសម្លាប់រង្គាលនៅ ស្រ៊ីព្រីនីកា នៅខែកក្កដា ឆ្នាំ១៩៩៥ ។ តុលាការអន្តរជាតិបានបញ្ជាក់ថា ដោយយល់ឃើញថា ស៊ែប នៅមានឥទ្ធិពលដែលមិនអាចប្រកែកបានរដ្ឋអំណាចនៃរដ្ឋនេះគួរតែប្រើប្រាស់អំណាចរបស់ខ្លួនប្រឹងប្រែងក្នុងការទប់ស្កាត់សោកនាដកម្មនេះដែលបានកើតមានឡើងក្នុងទ្រង់ទ្រាយមួយដែលអាចប៉ាន់ស្មានបាន ទោះជាហេតុការណ៍នេះយើងមិនអាចប្រមាណទុកមុនច្បាស់លាស់ក៏ដោយ ។

សាលក្រមនេះបានធ្វើការបញ្ជាក់អះអាងថា កាតព្វកិច្ចក្នុងការទប់ស្កាត់អំពើណាមួយអាចធ្វើឡើងហួសពីព្រំដែនប្រទេសរបស់ខ្លួន ។ គោលការណ៍ដែលតុលាការនេះបង្កើតឡើងគួរតែត្រូវបានអនុវត្តទៅលើរដ្ឋទាំងឡាយណាដែលមិនបានធ្វើ ឬបានធ្វើតិចតួចក្នុងការឆ្លើយតបទៅនឹងអំពើឧក្រិដ្ឋកម្មទាំងឡាយដែលអាចចាត់ចូលជាអំពើប្រល័យពូជសាសន៍និងដែលអាចបង្កជាគ្រោះថ្នាក់ ។

សេចក្តីសម្រេចនេះមានលក្ខណៈដូចគ្នាទៅនឹងសេចក្តីថ្លែងការណ៍នៅក្នុងច្បាប់អន្តរជាតិដែលស្តែងចេញនៅក្នុងសេចក្តីសម្រេចរបស់សន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ២០០៥ ដែលបានប្រកាសថា រដ្ឋមាន «ទំនួលខុសត្រូវក្នុងការការពារ» ប្រជាជនដែលរងគ្រោះដោយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការបោសសំអាតក្រុមជាតិពន្ធុ ។

អនុសញ្ញានេះ បានគូសបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវយកមកកាត់ទោសដោយតុលាការប្រទេសណាដែលឧក្រិដ្ឋកម្មនេះបានកើតឡើង ឬ «ដោយតុលាការអន្តរជាតិណាដែលមានយុត្តាធិការទៅលើភាគីហត្ថលេខីដែលបានទទួលស្គាល់យុត្តាធិការនេះ» ។ សេចក្តីសម្រេចរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិដែលស្នើដោយប្រទេសគុយបា ឥណ្ឌា និងប៉ាណាម៉ា បានសុំឲ្យមានការទទួលស្គាល់យុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ថាជាយុត្តាធិការសកល ។ នេះមានន័យថា តុលាការរដ្ឋទាំងឡាយអាចដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មនេះ ដោយមិនគិតពីទីកន្លែងដែលឧក្រិដ្ឋកម្មប្រព្រឹត្តទេ ។ គំនិតនេះត្រូវបានបដិសេធចោលដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដោយផ្អែកទៅលើវិធីសាស្ត្រប្រចាំបញ្ចូលគ្នានូវយុត្តាធិការតាមតំបន់គ្រប់គ្រងនិងស្ថាប័នអន្តរជាតិ ។ តុលាការអន្តរជាតិនេះមិនដែលបានបង្កើតទេរហូតដល់កន្លះសតវត្សក្រោយមក នៅពេលដែលកតិកាសញ្ញាតុលាការឧក្រិដ្ឋកម្មអន្តរជាតិទីក្រុងរ៉ូម បានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ។ ទោះបីជាអនុសញ្ញានេះបានបដិសេធនូវយុត្តាធិការជាសកលនៅក្នុងការកាត់ទោសលោក អ៊ីចមែន តុលាការអ៊ីស្រាអែលបានសម្រេចថា បញ្ហានេះត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ។ ទោះបីជាគ្មានសន្ធិសញ្ញាណាមួយផ្តល់អំណាចដល់យុត្តាធិការសកលឲ្យគ្រប់គ្រងលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក៏ដោយ ហើយបើទោះបីជាមិនទាន់មានការកំណត់អំពី

ភាពស្របច្បាប់នៃតុលាការយុត្តិធម៌អន្តរជាតិក៏ដោយ ក៏ខក្រិដ្ឋកម្មនេះត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិដែរ ។ នៅឆ្នាំ២០០៦ និងឆ្នាំ២០០៧ តុលាការព្រហ្មទណ្ឌកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា បានអនុញ្ញាតឲ្យមានការផ្ទេរជនត្រូវចោទសម្រាប់ការកាត់ទោសដោយផ្អែកទៅលើយុត្តាធិការសកលនិងដោយមានការគាំទ្រពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជាភ័ស្តុតាងនៃការទទួលស្គាល់នៃយុត្តាធិការជាសកលទៅលើខក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

និយមន័យនៃពាក្យប្រល័យពូជសាសន៍ ដែលមានចែងនៅក្នុងមាត្រា២ នៃអនុសញ្ញាតែងតែទទួលបាននូវការរិះគន់ចំពោះអត្ថន័យដ៏តូចចង្អៀតនៃពាក្យនេះ ។ ឧទាហរណ៍ និយមន័យនេះគ្របតែលើក្រុមដែលទទួលបានការការពារតែមួយចំនួន និងតម្រូវឲ្យមានគោលបំណងសំដៅទៅលើការបំផ្លាញផ្នែករាងកាយលើក្រុមដែលងាយទទួលរងគ្រោះ ។ មានការខកចិត្តខ្លះនៅពេលដែលតុលាការយុត្តិធម៌អន្តរជាតិ (ក្នុងសំណុំរឿងបូស្នៀ និងហែហ្សេហ្គូវីណា) បានច្រានចោលនូវគោលបំណងក្នុងការពង្រីកនិយមន័យអំពើប្រល័យពូជសាសន៍ដោយព្យាយាមបកស្រាយពាក្យ «បំផ្លាញ» ដោយរួមបញ្ចូលន័យ «ការបោសសំអាតក្រុមជាតិពន្ធុ» នៅក្នុងនោះ ។ តុលាការនេះបានបកស្រាយថា «ការបោសសម្អាតក្រុមជាតិពន្ធុ» ដែលមានន័យថា «ការនិរទេស ឬការផ្លាស់ចេញសមាជិកក្រុមណាមួយ» បើទោះជាដោយកម្លាំងក៏ដោយ ក៏មិនមានន័យស្មើនឹងការបំផ្លិចបំផ្លាញក្រុមនោះទេ ។ ការបំផ្លាញនោះក៏មិនមែនជាលទ្ធផលស្វ័យប្រវត្តិចេញពីការជម្លៀសចេញដែរ ។ វិធីសាស្ត្រដ៏អភិរក្សក្នុងការបកស្រាយនិយមន័យនិងការតស៊ូពង្រីកអត្ថន័យរបស់ពាក្យនេះតាមរយៈទង្វើផ្នែកផ្លូវច្បាប់ជាជាងធ្វើការកែប្រែអនុសញ្ញានោះ ក៏មានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី និងនៅក្នុងរបាយការណ៍របស់គណៈកម្មការស្វែងរកការពិតរបស់អង្គការសហប្រជាជាតិដែរ ។

នៅក្នុងផ្លូវនយោបាយ ក៏គ្មានការខំប្រឹងប្រែងជាក់លាក់ណាមួយដើម្បីថែមថយ ឬកែប្រែនិយមន័យនៅក្នុងមាត្រា២នៃអនុសញ្ញានេះដែរ ។ ឳកាសល្អមួយក្នុងការអភិវឌ្ឍនិយមន័យនេះគឺពេលដែលកតិកាសញ្ញាតុលាការខក្រិដ្ឋកម្មអន្តរជាតិទីក្រុងរ៉ូមត្រូវបានបង្កើតឡើង ពោលគឺនៅពេលដែលនិយមន័យរបស់ខក្រិដ្ឋកម្មអន្តរជាតិសំខាន់ៗមួយចំនួនខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងខក្រិដ្ឋកម្មសង្គ្រាម ត្រូវបានធ្វើទំនើបកម្ម ។ នៅក្នុងការចរចានោះ នៅពេលដែលខក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានលើកយកមកពិភាក្សា មានសំណូមពរតូចៗតែពីរបីប៉ុណ្ណោះ ដែលសំណូមពរនេះមិនបានបង្កើតការជំរុញឲ្យមានការកែប្រែនោះទេ ។ នៅក្នុងសន្និសីទទីក្រុងរ៉ូម មានតែប្រទេសគុយបាមួយគត់ដែលបានតវ៉ាសុំឲ្យមានការកែប្រែនិយមន័យ ដោយធ្វើការស្នើពង្រីកឲ្យពាក្យនេះគ្របដណ្តប់ទាំងក្រុមសង្គមនិងក្រុមនយោបាយ ។

មានភ័ស្តុតាងខ្លះដែលបញ្ជាក់ពីការបង្កើតថ្មីដោយអ្នកច្បាប់ថ្នាក់ជាតិ ពេលដែលលក្ខខណ្ឌនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ត្រូវបានបកប្រែជាក្រមច្បាប់ខក្រិដ្ឋកម្មក្នុងស្រុក ។ ឧទាហរណ៍ ច្បាប់ព្រហ្មទណ្ឌបារាំង *(Code pénal)* បានឲ្យនិយមន័យអំពើប្រល័យពូជសាសន៍ថាជាការបំផ្លាញក្រុមណាមួយដែលអត្តសញ្ញាណក្រុមនោះមិនមានមូលដ្ឋានច្បាស់លាស់ ។ ជនជាតិកាណាដា បានធ្វើការអនុវត្តច្បាប់នៃកតិកាសញ្ញាទីក្រុងរ៉ូម ដែលមានអត្ថន័យថា «អំពើប្រល័យពូជសាសន៍» គឺជាអំពើណាមួយ ឬការបំបាត់ដែលប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លាញទាំងស្រុង ឬដោយផ្នែកនូវក្រុមជាក់លាក់ណាមួយ នៅពេលវេលានិងទីកន្លែងដែលអំពើខក្រិដ្ឋកម្មនោះបានកើតឡើង ដែលបានបង្កើតឲ្យមានអំពើប្រល័យពូជសាសន៍ ផ្អែកទៅលើច្បាប់អន្តរជាតិ ដែលច្បាប់នេះបានពន្យល់ពីនិយមន័យអំពើប្រល័យពូជសាសន៍នៅក្នុងកតិកាសញ្ញាទីក្រុងរ៉ូម ដែលមានលក្ខណៈដូចគ្នាទៅនឹងអ្វីដែលចែងនៅក្នុងអនុសញ្ញា ត្រូវបានចាត់ទុកថាជាអំពើខក្រិដ្ឋកម្ម បើយោងទៅលើច្បាប់អន្តរជាតិ ។ ច្បាប់នេះបានបន្ថែមទៀតថា «និយមន័យនេះមិនកម្រិត ឬមិនធ្វើការវិនិច្ឆ័យមុនដោយប្រការណាមួយនៃការអនុវត្តវិធាននៃច្បាប់អន្តរជាតិដែលមានរួចជាស្រេចឬដែលកំពុងតែអភិវឌ្ឍឡើយ ។ នាពេលថ្មីៗនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានទទួលស្គាល់ភាពលម្អៀងខ្លះៗនៅថ្នាក់ជាតិ ហើយដាក់ចេញនូវការបកស្រាយយ៉ាងទូលំទូលាយមួយអំពីនិយមន័យអំពើប្រល័យពូជសាសន៍ ដោយតុលាការអាល្លឺម៉ង់ឲ្យមានការស៊ីសង្វាក់គ្នាជា

មួយនឹងបម្រាមនៃការសិក្សាពីឧក្រិដ្ឋកម្មដែលចូលជាធរមានរួចមកហើយ ។ នៅថ្នាក់អន្តរជាតិ ការអាននិយមន័យរបស់អនុសញ្ញានៅតែជាច្បាប់នៅឡើយ ។

## ក្រុមដែលទទួលបានការការពារ

យោងតាមអនុសញ្ញាឆ្នាំ១៩៤៨ និយមន័យនៃ «ក្រុមដែលទទួលបានការការពារ» សំដៅទៅលើ «ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ។ ទស្សនៈនេះគឺមានលក្ខណៈស្រដៀងគ្នានឹងទស្សនៈដែលគេចាត់ទុកជា «ក្រុមជនជាតិភាគតិច» ក្នុងអំឡុងពេលអនុម័តអនុសញ្ញាអំពើប្រល័យពូជសាសន៍ ។ នេះគឺជាទស្សនៈរបស់ លីមគិន និងអ្នកប្រាជ្ញអន្តរជាតិម្នាក់ទៀតដែលបានជួយសហរដ្ឋអាមេរិកតាក់តែងសេចក្តីព្រាងលើកដំបូងនៃអនុសញ្ញានេះឡើង ។ ក្នុងអំឡុងកិច្ចចរចាមានការជជែកពិភាក្សាដ៏សំខាន់មួយស្តីពីបញ្ហាថាតើគួរតែដាក់បញ្ចូលក្រុមនយោបាយនៅក្នុងនិយមន័យនេះឬយ៉ាងណា ។ ការធ្វើទុក្ខបុកម្នេញលើសមាជិកនយោបាយត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅទីក្រុងនូរ៉ែមប៊ើក ។ ប៉ុន្តែ អ្នកធ្វើសេចក្តីព្រាងអនុសញ្ញាអំពើប្រល័យពូជសាសន៍ដូចជា លីមគិន ជាដើមបានបដិសេធមិនដាក់បញ្ចូលក្រុមនយោបាយជាដាច់ខាត ។ អត្ថបទបន្តបន្ទាប់ទាក់ទងនឹងបញ្ហានេះបានអះអាងថាការមិនដាក់បញ្ចូលក្រុមនយោបាយទៅក្នុងនិយមន័យអំពើប្រល័យពូជសាសន៍ គឺជាលទ្ធផលដែលបណ្តាលមកពីការដាក់សម្ពាធរបស់សហភាពសូវៀត ប៉ុន្តែអត្ថន័យពិតប្រាកដនៃប្រវត្តិសេចក្តីព្រាងនេះបង្ហាញឲ្យឃើញថាការប្រឆាំងមិនទទួលស្គាល់គំនិតដាក់បញ្ចូលក្រុមនយោបាយនេះបានយល់ឃើញយ៉ាងទូលំទូលាយ ។ តុលាការឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានទទូចសុំឲ្យមានការពង្រីកនិយមន័យអំពើប្រល័យពូជសាសន៍សំដៅឆ្ពោះទៅរកក្រុមអ្នកនយោបាយ ។

ការកាត់ទោសដំបូងបង្អស់ដោយប្រើប្រាស់អត្ថបទដែលទាញចេញពីមាត្រា២ នៃអនុសញ្ញាដែលជាការកត់សម្គាល់ក្រុមជនរងគ្រោះមិនបានលើកឡើងពីផលវិបាកផ្នែកច្បាប់ណាមួយឡើយ ។ ច្បាប់របស់អ៊ីស្រាអែល បានចៀសវាងការពិភាក្សាទាំងឡាយណាដែលទាក់ទងនឹងប្រភេទ «ក្រុមមនុស្ស» ដោយធ្វើការកែទម្រង់លើនិយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍ដើម្បីសម្រេចលើ «បទឧក្រិដ្ឋប្រឆាំងនឹងជនជាតិជ្វីហ្វ» ហើយគ្មានការកត់ត្រារបស់តុលាការណាមួយបានអះអាងថា អ៊ិចម៉ែន ធ្លាប់ប្រឆាំងនឹងការពិតដែលថាជនរងគ្រោះនៃអំពើសាហាវឃោរឃៅរបស់ពួកណាហ្ស៊ីគឺជា «ប្រជាជនជ្វីហ្វ» ឡើយ ។ បញ្ហានេះមិនបានចោទជាភាពចម្រូងចម្រាស់ដល់ដំណើរការរបស់តុលាការទេបើនិយាយពីបញ្ហាទាក់ទងនឹងជម្លោះនៅបូស្នៀនិងហែហ្សេហ្គូវីណា ។ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានសម្រេចថា «ជនជាតិមូស្លីមបូស្នៀ» គឺជាក្រុមជាតិ ។ នេះគឺជាសេចក្តីសម្រេចមួយដែលមិនត្រូវបានប្រឆាំងដោយបណ្តឹងឧទ្ធរណ៍ ហើយត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ។ ដោយមិនទាន់មានភាពប្រាកដប្រជាលើភាពត្រឹមត្រូវស្របច្បាប់ លើទស្សនៈ «ក្រុមពូជសាសន៍» អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានផ្តោតការយកចិត្តទុកដាក់លើការពិតដែលថា ក្រុមពូជសាសន៍ ទុតស៊ី ហ៊ូទូ និងត្វា គឺជាក្រុមជាតិពន្ធុជាមួយនឹងជនជាតិរ៉្វាន់ដានៅក្នុងអំឡុងអំពើប្រល័យពូជសាសន៍កាលពីឆ្នាំ១៩៩៤ ។

នៅក្នុងការបកស្រាយថ្មីមួយនេះ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានសម្រេចថា «ក្រុមមនុស្សដែលមិនប្រែប្រួល និងមានលក្ខណៈអចិន្ត្រៃយ៍» ត្រូវបានការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍ ប៉ុន្តែទ្រឹស្តីនៃក្រុមមនុស្សខាងលើនេះមិនទាន់មានលក្ខណៈច្បាស់លាស់នៅក្នុងច្បាប់ករណីឡើយ ។ ជាទូទៅមានតែជនដៃដល់នៃអំពើប្រល័យពូជសាសន៍តែប៉ុណ្ណោះដែលអាចធ្វើការកំណត់លក្ខណៈរបស់ជនរងគ្រោះដែលជាសមាជិកក្រុម ដែលត្រូវបានការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍នេះបាន ។ ជាឧទាហរណ៍ ពួកណាហ្ស៊ីបានបង្កើតជាក្បួនច្បាប់ដ៏លម្អិតមួយដែលធ្វើការសន្មតក្រុមណាខ្លះដែលជាជនជាតិជ្វីហ្វ ហើយក្រុមណាដែលមិនមែន យោងតាមលក្ខណៈវិនិច្ឆ័យសត្យានុម័តរបស់ខ្លួន ។ គ្មានអ្វីខុសប្លែកគ្នាទេ ប្រសិនបើបុគ្គលណាម្នាក់ ដែលជាជនជាតិជ្វីហ្វហើយមិនកាន់សាសនាជ្វីហ្វបដិសេធថា ខ្លួនមិនមែនជាក្រុមជនជាតិជ្វីហ្វនោះទេ ។ ដូចលោក ហ្សង់ ផលសាឌឺ បានសរសេរថា

: «*Le juif est un homme que les autres hommes tiennent pour juif*» ។ ដោយមានការធុញថប់ មេធាវី និងតុលាការបានធ្វើការសម្រេចស្វែងរកមើលនិយមន័យសត្យានុម័តនៃក្រុមដែលត្រូវទទួលបានការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍នេះ ។ ប៉ុន្តែ លក្ខណៈវិនិច្ឆ័យភាគច្រើនធ្វើការចាត់ទុកការទទួលស្គាល់ក្រុមការពារដោយអនុសញ្ញាជាបញ្ហាអត្តនោម័ត ។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានចែងថា «ជនដែលពាក់ព័ន្ធនឹងក្រុមដែលត្រូវបានការពារអាចត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យអត្តនោម័តមិនទទួលស្គាល់ថាជាក្រុមនេះយោងតាមឧក្រិដ្ឋកម្មរបស់ជនដែលដល់ដោយផ្អែកលើលក្ខណៈយល់ឃើញពីក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ និងសាសនារបស់អង្គជំនុំជម្រះសាលាដំបូង ។ នៅក្នុងករណីខ្លះ ជនរងគ្រោះអាចយល់ឃើញថាខ្លួនគឺជាសមាជិកណាមួយនៃក្រុមខាងលើ ។ ទស្សនៈចម្រុងចម្រាសនោះគឺថាការកំណត់ជនដែលពាក់ព័ន្ធនឹងក្រុមដែលត្រូវបានការពារដោយអនុសញ្ញាគួរតែធ្វើឡើងជាករណីៗដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត និងអត្តនោម័ត ។

## ការកម្ចាត់ជាតិពន្ធុ និងអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌

និយមន័យនៃអំពើប្រល័យពូជសាសន៍របស់អនុសញ្ញានេះសំដៅទៅលើ «ការបំផ្លិចបំផ្លាញដោយចេតនា» ប៉ុន្តែមិនមានការបញ្ជាក់ឲ្យបានច្បាស់លាស់បន្ថែមទៀតឡើយ ។ ទង្វើដែលអាចផ្តន្ទាទោសបានទាំងប្រាំខាងក្រោមនេះ រួមមានទាំងការវាយប្រហាររួមផ្សំគ្នាលើផ្នែករូបរាងកាយជីវសាស្ត្រនិងវប្បធម៌ ។ ឧទាហរណ៍ ទង្វើអំពើប្រល័យពូជសាសន៍ទីប្រាំនៅក្នុងនិយមន័យនៃការបញ្ជូនកុមារទាំងបង្ខំពីក្រុមមួយទៅក្រុមមួយទៀតមិនមានជាប់ពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញលើរូបរាងកាយរបស់កុមារទាំងនោះទេ ។ ការកម្ចាត់ចោលក្រុមមួយត្រូវបានកំណត់ថាធ្វើឡើងដោយផ្អែកលើការបំផ្លិចបំផ្លាញលើការចងចាំផ្នែកវប្បធម៌ និងភាសាជាតិរបស់ខ្លួនតាមរយៈធ្វើការបញ្ជ្រាបលើផ្នត់គំនិតរបស់ក្រុមនោះតាំងពីវ័យក្មេង ។ អត្ថន័យនៃនិយមន័យអាចគាំទ្រការបកស្រាយដែលថាទង្វើ «កម្ចាត់ជាតិពន្ធុ» ឬអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ដែលបណ្តាលឲ្យមានការបំផ្លិចបំផ្លាញលើរូបរាងកាយអាចនឹងផ្តន្ទាទោសបាន ។ នេះគឺជាទស្សនៈយល់ឃើញមួយដែលលក្ខណៈវិនិច្ឆ័យខ្លះបានគាំទ្រ ។

ខណៈពេលដែលអនុសញ្ញាអំពើប្រល័យពូជសាសន៍កំពុងត្រូវបានព្រាងទង្វើដែលអាចផ្តន្ទាទោស បានត្រូវបានបែងចែកជាបីផ្នែកគឺ អំពើប្រល័យពូជសាសន៍លើផ្នែករូបរាងកាយ ជីវសាស្ត្រ និងវប្បធម៌ ។ អង្គមហាសន្និបាតអង្គការសហប្រជាជាតិបានបោះឆ្នោតសម្រេចមិនដាក់បញ្ចូលអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ចូលទៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍នេះឡើយ ។ រដ្ឋសភាអង្គការសហប្រជាជាតិក៏បានប្រានចោលការទាមទារឲ្យមានវិសោធនកម្មពីសំណាក់ប្រទេសស៊ីរីឲ្យដាក់បញ្ចូលទង្វើនៃអំពើប្រល័យពូជសាសន៍ដែលសព្វថ្ងៃអាចទុកថាជា «ការកម្ចាត់ជាតិពន្ធុ» ។ វិសោធនកម្មរបស់ប្រទេសស៊ីរីមានអត្ថន័យដូចតទៅ : «វិធានការប្រឆាំងបានធ្វើឡើងក្នុងគោលបំណងបង្ខំឲ្យសមាជិកនៃក្រុមជាតិពន្ធុមួយក្រុមចាកចេញពីផ្ទះសំបែងរបស់ខ្លួនដើម្បីគេចចេញពីការគំរាមកំហែងពីអំពើសាហាវឃោរឃៅដែលកើតមានជាបន្តបន្ទាប់» ។ នៅពេលដែលអង្គសន្និបាតសភាអង្គការសហប្រជាជាតិយល់ព្រមដាក់បញ្ចូលការបញ្ជូនកុមារពីកន្លែងមួយទៅកន្លែងមួយដោយបង្ខំទៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍នោះ ការដាក់បញ្ចូលនេះត្រូវបានចាត់ទុកថាជាការមិនយល់ព្រមដាក់បញ្ចូលអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ ។ ជាលទ្ធផលអត្ថន័យនៃនិយមន័យអំពើប្រល័យពូជសាសន៍របស់អនុសញ្ញាដែលធ្វើការពិចារណាពីគោលបំណងរបស់អ្នកព្រាងអនុសញ្ញានេះទំនងជានិងបដិសេធមិនដាក់បញ្ចូលអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ និងការកម្ចាត់ជាតិពន្ធុឡើយ ហើយនឹងបង្កើតពាក្យថា «បំផ្លិចបំផ្លាញ» ដោយកំណត់លើ «ផ្នែករូបរាងកាយនិងជីវសាស្ត្រ» វិញ ។

មានការសួរដេញដោលយ៉ាងខ្លាំងពីការបដិសេធលើវិធីសាស្ត្រសម្រេចលើការបកស្រាយដែលបានសង្កត់ធ្ងន់លើគោលបំណងផ្នែកច្បាប់ ជាពិសេសគឺច្បាប់សិទ្ធិមនុស្ស ។ ការផ្អែកលើប្រវត្តិនៃសេចក្តីព្រាងអនុសញ្ញានេះទំនងជាបញ្ឈប់បញ្ញត្តិនេះដោយរារាំងមិនឲ្យសេចក្តីព្រាងធ្វើការវិវត្តទៅមុខបាន ដើម្បីទុកពេលពិចារណាឡើងវិញលើប្រវត្តិនៃការវិវត្តនិងឥរិយាបថផ្លាស់ប្តូររបស់សេចក្តីព្រាងអនុសញ្ញានេះ ។ យើងអាចនិយាយបានថា

តុលាការសព្វថ្ងៃនេះបានបង្ហាញការគោរពតាមទស្សនៈដែលអនុម័ត ដោយអង្គសន្និបាតសភាអង្គការសហប្រជាជាតិកាលពីឆ្នាំ១៩៤៨ ។ យ៉ាងណាមិញ បញ្ហានេះត្រូវបានពន្យល់បកស្រាយដោយមិនលំអៀងដោយការពិភាក្សា ។ ដូចគ្នានឹងឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ដែលបានលេចឡើងនៅក្នុងច្បាប់អន្តរជាតិដើម្បីធ្វើជាប្រតិកម្មទៅនឹងលក្ខខណ្ឌកំណត់របស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បច្ចុប្បន្ននេះច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានវិវត្តទៅរកដំណាក់កាលដែលថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះអាចរួមបញ្ចូលទាំងទង្វើកម្ចាត់ជាតិពន្ធុ និងអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ បើទោះបីជាឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលមានសន្តិភាពក៏ដោយ ។ ជាលទ្ធផលមិនមាន «ចន្លោះនិទ្ទណ្ឌភាព» ហើយក៏ស្ទើរតែគ្មានសម្ពាធលើផ្នែកច្បាប់ទាក់ទងនឹងការពង្រីកនិយមន័យនៃអំពើប្រល័យពូជសាសន៍នេះតាមរយៈការបកស្រាយខាងលើដែរ ។ ជារឿងប្រាកដណាស់ថា សិទ្ធិដាច់មុខខាងផ្នែកនយោបាយ និងនិមិត្តរូបនិយមមានជាប់ពាក់ព័ន្ធនឹងពាក្យ «អំពើប្រល័យពូជសាសន៍» ហើយមានជនរងគ្រោះជាច្រើនខកចិត្តយ៉ាងខ្លាំង នៅពេលដែលទុក្ខវេទនារបស់ខ្លួនត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ«ស្រាល» ។ អ្នកទាំងនោះមិនកោតសរសើរសារសំខាន់នៃច្បាប់ប៉ុន្មានទេ ដែលបញ្ហានេះកើតឡើងបណ្តាលមកពីការវែកញែកពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញ ។ ដូច្នេះ បើទោះបីជាភាពខុសគ្នារវាងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនផ្តល់ជាលទ្ធផលសំខាន់តាមផ្លូវច្បាប់ក៏ដោយ ក៏ភាពខុសគ្នារវាងពាក្យទាំងពីរនេះនៅតែមានសារសំខាន់នៅក្នុងបរិបទផ្សេងទៀតដែរ ។

## ចំនួននិងអំពើប្រល័យពូជសាសន៍

និយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍នៅឆ្នាំ ១៩៤៨ និយាយពីការបំផ្លិចបំផ្លាញលើក្រុមមនុស្ស «ទាំងស្រុង ឬដោយផ្នែក» ។ នេះគឺជាគោលដៅដ៏មានតម្លៃរបស់អ្នកព្រាងអនុសញ្ញានេះក្នុងការសម្រេចឲ្យបាននូវកិច្ចព្រមព្រៀងលើសេចក្តីព្រាង ប៉ុន្តែតាមការពិតអង្គមហាសន្និបាតនេះបានប្រើប្រាស់ពាក្យមិនច្បាស់លាស់ ហើយទុកឲ្យចៅក្រមធ្វើការបកស្រាយបញ្ហាក់នៅពេលមានដំណើរការកាត់ទោសជាបន្តបន្ទាប់ទៅវិញ ។ ទ្រឹស្តីជាច្រើនបានលេចឡើងជាមួយនឹងទស្សនៈកំណត់ពាក្យ «ដោយផ្នែក» ។ ដោយសារតែពាក្យនេះលេចឡើងនៅក្នុងកថាខណ្ឌបឋមនៃនិយមន័យពាក្យអំពើប្រល័យពូជសាសន៍ វាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាពាក្យនេះសំដៅលើចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ជាលទ្ធផល សំណួរសំខាន់ដែលត្រូវសួរមិនមែនជាសំណួរថាតើមានជនរងគ្រោះប៉ុន្មាននាក់បានស្លាប់ ឬរងរបួសទេ ផ្ទុយទៅវិញ យើងគួរតែសួរថាតើមានជនរងគ្រោះប៉ុន្មាននាក់ដែលជនដៃដល់មានចេតនាវាយប្រហារ ។ បើទោះបីជាជនរងគ្រោះមានចំនួនតិចតួច ឬក៏គ្មានក៏ដោយ ក៏អនុសញ្ញាអំពើប្រល័យពូជសាសន៍នឹងធ្វើការផ្តន្ទាទោសចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយ



ចេតនានេះឲ្យបាន ។ មានន័យថា ឧក្រិដ្ឋកម្មនោះអាចប្រព្រឹត្តឡើងបានលុះត្រាតែចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍បានបង្ហាញឲ្យឃើញ ។ ទាក់ទងនឹងចំនួនជនរងគ្រោះវិញ ចំនួនជនរងគ្រោះពិតប្រាកដនឹងមានសារសំខាន់ត្រង់ថាវាជួយដល់ការវិភាគលើចេតនារបស់ជនដៃដល់ ។ កាលណាជនរងគ្រោះពិតប្រាកដមានចំនួនកាន់តែច្រើន នោះហេតុផលមានកាន់តែច្រើនដែលអាចក្លាយជាការពិតដែលថាជនដៃដល់ពិតជាមានបំណងបំផ្លាញក្រុមមនុស្សមួយក្រុមទាំងស្រុង ឬដោយផ្នែកមែន ។ យ៉ាងណាមិញ នៅមានបញ្ហាដោយឡែកផ្សេងទៀតទាក់ទងនឹងការផ្តល់អត្ថន័យនៃពាក្យ «ដោយ

ផ្នែក» ។ តើវាអាចក្លាយជាអំពើប្រល័យពូជសាសន៍បានដែរឬទេ នៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងដើម្បីសម្លាប់មនុស្សមួយចំនួនតូចដោយសារតែមនុស្សទាំងនោះគឺជាសមាជិកនៃក្រុមជាតិពន្ធុណាមួយ? បើតាមអត្ថន័យ និយមន័យផ្ទាល់វិញ និយមន័យនេះដូចជាទំនងគាំទ្រការរៀបរាប់ខាងលើ ។ ប៉ុន្តែការបង្កើតពាក្យនេះឡើងមានលក្ខណៈហួសហេតុ ហើយមិនស្របទៅតាមប្រវត្តិនៃសេចក្តីព្រាង បរិបទ គោលដៅ និង គោលបំណងនៃអនុសញ្ញាអំពើប្រល័យពូជសាសន៍នេះឡើយ ។ វិធីសាស្ត្រពីរបានបង្កើតឡើងដើម្បីដោះស្រាយវិសាលភាពនៃពាក្យ «ដោយផ្នែក» នេះដោយធ្វើការបន្ថែមគុណនាមបញ្ជាក់ន័យឲ្យពាក្យ «ផ្នែក» នេះ


គុកទួលស្លែង

ដូចជា «ធំ» ឬ «សំខាន់» ។

យោងតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី «តុលាការបានកំណត់យ៉ាងច្បាស់ថាបើការចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ផ្អែកលើចេតនាបំផ្លិចបំផ្លាញក្រុមដែលត្រូវបានការពារ «ដោយផ្នែក» នោះការបំផ្លិចបំផ្លាញដោយផ្នែកនេះទៅលើក្រុមនោះត្រូវតែមានលក្ខណៈធំ» ។ ដោយកត់សម្គាល់ឃើញថាពួកណាហ្ស៊ីមិនមានចេតនាបំផ្លិចបំផ្លាញជនជាតិជ្វីហ្វទាំងអស់ទេ លើកលែងតែពួកណាហ្ស៊ីនៅតំបន់អឺរ៉ុបប៉ុណ្ណោះ ហើយពួកផ្តាច់ការហ៊ូទូនៅរ៉្វាន់ដាបានព្យាយាមសម្លាប់ជនជាតិទុតស៊ីរស់នៅរ៉្វាន់ដានោះ អង្គជំនុំជម្រះសាលាដំបូងបាននិយាយថា ៖ «ចេតនាបំផ្លិចបំផ្លាញដែលបង្កើតឡើងដោយជនដៃដល់ម្នាក់នៃអំពើប្រល័យពូជសាសន៍នឹងមានលក្ខខណ្ឌកម្រិតដោយសារកាលៈទេសៈនៅជុំវិញជននោះ ។ បើទោះបីជាកត្តាមួយនេះនៅតែមិនបានបញ្ជាក់ថាក្រុមដែលរងការបំផ្លិចបំផ្លាញមានទ្រង់ទ្រាយធំក៏ដោយ ក៏កត្តានេះរួមជាមួយនឹងកត្តាផ្សេងទៀតបានផ្តល់ជាលទ្ធផលវិភាគមួយដែរ ។ នៅក្នុងបរិបទពិតប្រាកដវិញ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានចាត់ទុកថាសហគមន៍ជនជាតិមូស្លីមបូស្នៀនៅស្រីព្រីនីកា បានតំណាងឲ្យជនជាតិមូស្លីមបូស្នៀដែលមាន «ទ្រង់ទ្រាយធំ» មួយ ដូច្នេះចេតនាបំផ្លិចបំផ្លាញក្រុមនេះត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍ ។

វិធីសាស្ត្រមួយផ្សេងទៀតវិញ ធ្វើការពិចារណាលើទស្សនៈស្តីពីគុណភាពជាជាងទស្សនៈស្តីអំពីចំនួនចំពោះអត្ថន័យនៃគុណនាម«សំខាន់» ។ មិនមានទស្សនៈណាមួយធ្វើការគាំទ្រវិធីសាស្ត្រនេះឡើយ បើនិយាយពីប្រវត្តិនៃការព្រាងអនុសញ្ញាអំពើប្រល័យពូជសាសន៍នេះ ហើយគំនិតនេះហាក់បីដូចជាត្រូវបានផ្តួចផ្តើមឡើងដោយលោក បេ៊នចាមីន វីថេកខឺ នៅក្នុងរបាយការណ៍ឆ្នាំ១៩៨៥ ដែលប្រគល់ជូនអនុគណៈកម្មាធិការអង្គការសហប្រជាជាតិសម្រាប់ការការពារនិងលើកតម្កើងសិទ្ធិមនុស្ស ។ លោកបានសរសេរថា ពាក្យ «ដោយផ្នែក» តំណាងឲ្យ «ចំនួនមនុស្សសំខាន់ក្នុងចំណោមចំនួនសមាជិកក្រុមទាំងអស់ ឬផ្នែកសំខាន់នៃក្រុមនោះដូចជាក្រុមមេដឹកនាំជាដើម» ។ ដោយយោង-តាមរបាយការណ៍របស់ បេ៊នចាមីន វីថេកខឺ ក្រុមអ្នកជំនាញដែលត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩២ ដើម្បីធ្វើការស៊ើបអង្កេតលើការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅអតីតយូហ្គោស្លាវីបានសម្រេចថា ពាក្យ «ដោយផ្នែក» នេះមិនត្រឹមតែមានលក្ខណៈគុណភាពប៉ុណ្ណោះទេ ថែមទាំងមានលក្ខណៈចំនួនផងដែរ ។ យោងតាមលោកប្រធានគណៈកម្មាធិការសាស្ត្រាចារ្យ ឆេរីហ្វ បាសៀនី បានឲ្យដឹងថានិយមន័យដែលមានចែងនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ត្រូវបានសន្មតថា «អាចប្រែប្រួលបានក្នុងការកំណត់ក្រុមដែលរងការបំផ្លិចបំផ្លាញទាំងស្រុងដែលមានចែងនៅក្នុងអនុ

សញ្ញានេះ ហើយផ្នែកដាក់លាក់មួយនៃក្រុមដែលរងការបំផ្លិចបំផ្លាញដូចជាក្រុមជនជាតិមូស្លីម ឬស្ត្រីជនជាតិមូស្លីម» ។ វិធីសាស្ត្រនេះត្រូវបានអនុម័តដោយព្រះរាជអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី នៅក្នុងបទចោទប្រកាន់ដំបូងមួយចំនួន ហើយបន្ទាប់មកត្រូវបានទទួលស្គាល់ដោយចៅក្រម ។ បើទោះបីជាគ្មានការប្រកាសគាំទ្រជាសាធារណៈលើការពន្យល់បកស្រាយពាក្យ «ផ្នែកសំខាន់» នៅក្នុងអនុសញ្ញានេះក៏ដោយ ក៏អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការបានពិចារណាលើការជាប់ពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញលើសហគមន៍បុរសជនជាតិមូស្លីមស្រេព្រឺនីកាប្រមាណ៧.០០០នាក់ ។ ការសំដៅទៅលើការតាមដានរបស់អង្គជំនុំជម្រះសាលាដំបូងលើបែបបទសង្គមជនជាតិមូស្លីម បូស្នៀនៅស្រេព្រឺនីកា និងឥទ្ធិពលដែលមានមកលើសហគមន៍នេះនាពេលអនាគត បណ្តាលមកពីការសម្លាប់ប្រជាជនប្រុសយ៉ាងច្រើនសន្ធឹកសន្ធាប់នេះ ។ «ភ័ស្តុតាងដែលបានលើកឡើងនៅតុលាការបានគាំទ្រសេចក្តីសម្រេចនេះដោយបង្ហាញថាដោយសារតែបុរសភាគច្រើនដែលត្រូវបានសម្លាប់ត្រូវបានចុះក្នុងបញ្ជីបាត់ខ្លួនជាផ្លូវការនោះប្រពន្ធរបស់បុរសទាំងនោះមិនអាចរៀបអាពាហ៍ពិពាហ៍ឬមានកូនទៀតឡើយ ។ ដូច្នេះ ការបំផ្លិចបំផ្លាញលើរូបរាងកាយលើក្រុមបុរសមានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំងសម្រាប់សហគមន៍ជនជាតិមូស្លីមស្រេព្រឺនីកាដែលបណ្តាលឲ្យសហគមន៍នេះឈានទៅរកការដាច់ពូជ ។ ម្យ៉ាងវិញទៀត បុរសវ័យកណ្តាលទាំងនោះគឺជា «ផ្នែកសំខាន់» នៃសហគមន៍ជនជាតិមូស្លីមស្រេព្រឺនីកា ដែលជា «ផ្នែកដ៏ធំ» នៃក្រុមមូស្លីមបូស្នៀ ។

## ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍

បើយោងតាមគោលការណ៍ អ្វីដែលធ្វើឲ្យច្បាប់ព្រហ្មទណ្ឌខុសពីផ្នែកដទៃទៀតនៃការទទួលខុសត្រូវតាមផ្លូវច្បាប់ផ្សេងៗនោះគឺការទទួចដែលថាទង្វើដែលត្រូវដាក់ទណ្ឌកម្មនោះគឺត្រូវបានប្រព្រឹត្តឡើងដោយចេតនា ។ យ៉ាងហោចណាស់ ទង្វើដែលកើតឡើងដោយសារការធ្វេសប្រហែសឬចៃដន្យនោះ គឺស្ថិតនៅក្នុងវង្វង់នៃច្បាប់ព្រហ្មទណ្ឌ ហើយច្បាស់លាស់ណាស់ដែលថាច្បាប់នេះនឹងមិនប្រើប្រាស់នៅពេលដែលទាក់ទងនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះទេ តួយ៉ាងដូចជាអំពើប្រល័យពូជសាសន៍ជាដើម ។ តាមវិធានច្បាប់ព្រហ្មទណ្ឌមិនបានពន្យល់ឲ្យបានច្បាស់លាស់នូវតម្រូវការឲ្យមានចេតនានោះទេ ដោយសារតែនេះគឺត្រូវបានយល់ឃើញថាជាភាពជាក់ស្តែងទៅហើយ ។ករណីលើកលែងនៅក្នុងនិយមន័យដែលបានចែងក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍នោះ សំដៅទៅលើចេតនារបស់ជនដៃដល់ដែលប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លាញក្រុមដែលទទួលបានការការពារដោយផ្នែកឬទាំងស្រុង ។ តាមពិត មានចេតនាពីរខុសគ្នាដែលពាក់ព័ន្ធដោយសារតែទង្វើសំខាន់នៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺត្រូវតែអនុវត្តឡើងដោយមានចេតនា ឧទាហរណ៍ ដូចជាការសម្លាប់ឬការបង្ករបួសស្នាមធ្ងន់ធ្ងរមកលើរូបរាងកាយឬផ្លូវចិត្តរបស់សមាជិកនៃក្រុមដែលទទួលបានការការពារនោះ ។

តុលាការតែងតែសំដៅទៅលើ «ចេតនាជាក់លាក់» នៃអំពើប្រល័យពូជសាសន៍ក្នុងគោលបំណងដើម្បីញែកវាចេញពីការសម្លាប់ដែលមិនមែនជាអំពើប្រល័យពូជសាសន៍ ។ ការប្រើប្រាស់គំរូច្បាប់ព្រហ្មទណ្ឌចាស់នេះមកលើអំពើប្រល័យពូជសាសន៍បានធ្វើឲ្យចៅក្រមខ្លះមានការផ្តោតសំខាន់លើសលស់មកលើបុគ្គលជាជនដៃដល់ដែលត្រូវបានយកមកកាត់ទោសដោយឡែក ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានអនុម័តនូវទស្សនៈដែលថាបុគ្គលម្នាក់ដែលធ្វើតែម្នាក់ឯងអាចប្រព្រឹត្តអំពើប្រល័យពូជសាសន៍បាននៅក្នុងកម្រិតដែលថាជននោះបានពាក់ព័ន្ធនៅក្នុងការសម្លាប់ដោយមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ បញ្ហាទាក់ទងនឹងការវិភាគបែបនេះគឺធ្វើឲ្យបាត់បង់នូវការចាប់អារម្មណ៍មកលើសារសំខាន់នៃផែនការនិងគោលនយោបាយរបស់រដ្ឋឬអង្គភាពដែលមានឋានៈស្មើ ។ តែតាមការអនុវត្តជាក់ស្តែងវិញ អំពើប្រល័យពូជសាសន៍នៅក្នុងប្រព័ន្ធច្បាប់អន្តរជាតិគឺមិនមែនជាឧក្រិដ្ឋកម្មរបស់បុគ្គលម្នាក់ឯងនោះទេ តែវាជាទង្វើរបស់រដ្ឋ ។ សារសំខាន់នៃគោលនយោបាយរបស់រដ្ឋរឹតតែមានភាពជាក់ស្តែងឡើងនៅពេលដែលបរិបទនេះងាកពីការកាត់ទោសជាបុគ្គលមកជាការសម្រេចសេចក្តីដែលមានលក្ខណៈទូលាយទាក់ទងនឹងផ្នែកនយោបាយវិញនោះ ។

**(នៅមានត)**

**ទីរៀម សាបាស់**

# ចុះបើ តាម៉ុក នៅរស់វិញ?

ឈិត ជឿន ហៅ តាម៉ុក ដែលជាលេខាភូមិភាគនិរតី នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយនាដំណាក់កាលចុងក្រោយនៃរបបនេះទទួលតំណែងជាលេខាប្រចាំភូមិភាគជាច្រើនទៀត គឺជាកម្មាភិបាលដែលមានឥទ្ធិពលម្នាក់របស់ចលនាខ្មែរក្រហម ។ រយៈពេលដប់ប្រាំបីឆ្នាំក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ តាម៉ុក មានអំណាចរហូតដល់ទៅកាត់ទោសអតីតមេរបស់ខ្លួនគឺ ប៉ុល ពត និងដាក់ទោសឲ្យនៅក្នុងផ្ទះ ។

តាម៉ុក បានចូលបម្រើចលនាកុម្មុយនីស្តតាំងពីឆ្នាំ១៩៤៩ មក នៅពេលដែលគាត់នៅមានអាយុ២៣ឆ្នាំ រហូតដល់ឆ្នាំ១៩៩៩ នៅពេលដែលគាត់ត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាលកម្ពុជាពេលដែលគាត់មានអាយុ៧៣ឆ្នាំ ។ អំឡុងពេលរបបខ្មែរក្រហម តាម៉ុក មិនគ្រាន់តែបញ្ជាឲ្យមានការសម្លាប់កម្មាភិបាលខ្មែរក្រហមដែលបក្សចាត់ទុកជាសត្រូវប៉ុណ្ណោះទេ ថែមទាំងបានចូលរួមក្នុងដំណើរការកិច្ចប្រជុំរបស់បក្សក្នុងការបង្កើតគោលនយោបាយផ្សេងៗទៀតផង ។

តាម៉ុក គឺជាកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ម្នាក់ដែលបានកាន់ដំណែងដ៏វែង ហើយក៏ជាកម្មាភិបាលដែលមានចំណេះដឹងយ៉ាងជ្រៅជ្រះ និងជឿស៊ប់ទៅលើរបបចលនាកុម្មុយនីស្តខ្មែរក្រហម ។ ការស្លាប់របស់គាត់ក្នុងឆ្នាំ២០០៦ បាននាំទៅជាមួយនូវព័ត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ នេះគឺជាការបាត់បង់នូវព័ត៌មានដ៏សំខាន់មួយអំពីរបបខ្មែរក្រហម ហើយព័ត៌មានទាំងនោះនឹងមិនអាចទទួលបានជារៀងរហូត ។ ទោះបីជាយ៉ាងណាមជ្ឈដ្ឋានផ្សេងៗបានឲ្យនិយមន័យផ្សេងៗគ្នាទាក់ទងនឹងការស្លាប់របស់តាម៉ុក ។ សម្រាប់ជនរងគ្រោះ ការស្លាប់របស់ តាម៉ុក ជាការបាត់បង់ឧក្រិដ្ឋជនម្នាក់មុននឹងទទួលបាននូវការជំនុំជម្រះទោសតាមផ្លូវតុលាការ ។ សម្រាប់តុលាការខ្មែរក្រហម ការបាត់បង់ តាម៉ុក គឺជាការបាត់បង់ជនត្រូវចោទដ៏សំខាន់ម្នាក់ និងបាត់បង់នូវប្រភពធនធានព័ត៌មានដ៏សំខាន់ដែលអាចផ្ដល់ពន្លឺដល់ជនជាប់ចោទដែលកំពុងរង់ចាំការកាត់ទោសរាល់ថ្ងៃ ដូចជា អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង នួន ជា ។

សក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅឯសាលាក្ដីខ្មែរក្រហមបានជួយសម្រួលដល់តុលាការក្នុងការដាក់បន្ទុកបន្ថែមទៅ



លើជនជាប់ចោទ នួន ជា ដែល ឌុច បាននិយាយថា នួន ជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងលើមន្ទីរឃុំឃាំងស-២១ ។ ប៉ុន្តែ ឌុច មិនមែនជាសមាជិករបស់គណៈកម្មការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាទេ ដូច្នេះ ឌុច ក៏មិនអាចដឹងពីគោលនយោបាយឲ្យស៊ីជម្រៅអ្វីដែរ ។ ចំណែកឯ តាម៉ុក វិញគឺជាសមាជិកម្នាក់របស់គណៈកម្មការនេះ ។ ប្រសិនបើ តាម៉ុក នៅរស់ គាត់អាចនឹងនិយាយច្រើនជាងជនជាប់ចោទសព្វថ្ងៃដោយហេតុផលមួយចំនួន ។ ទីមួយ គាត់មានការខឹងសម្បារនឹងមេដឹកនាំខ្មែរក្រហមដទៃទៀតដែលកំពុងមានភាពរីករាយនឹងសេរីភាពរបស់ខ្លួន ខណៈពេលដែលគាត់កំពុងតែជាប់ក្នុងពន្ធនាគារ ។ ទីពីរ តាម៉ុក មិនសូវពេញចិត្តនឹងរដ្ឋាភិបាលកម្ពុជាប៉ុន្មានទេ ដូច្នេះគាត់ក៏មិនមានការភ័យខ្លាចនឹងនិយាយពីរបបខ្មែរក្រហមដែរ ។ ទីបី តាម៉ុក អាចនឹងស្វះស្វែងរកយុត្តិធម៌សម្រាប់ខ្លួនគាត់ ឬក៏រកវិធីការពារខ្លួនដោយធ្វើការបកអាក្រាតពីមេដឹកនាំខ្មែរក្រហមដទៃទៀត ។ ទីបួន មានពេលមួយ តាម៉ុក ធ្លាប់និយាយថា គាត់នឹងនិយាយប្រាប់គ្រប់យ៉ាងបើសិនជាមានតុលាការខ្មែរក្រហម ។

គ្មានជនជាប់ចោទណាម្នាក់ដែលកំពុងជាប់ឃុំសព្វថ្ងៃបានសារភាពពីអ្វីដែលខ្លួនបានធ្វើកាលពីជំនាន់ខ្មែរក្រហមទេ ទោះបីជាមានភ័ស្តុតាងនិងឯកសារបញ្ជាក់យ៉ាងច្បាស់ពីការចូលរួមពាក់ព័ន្ធក្នុងការសម្លាប់ ឬចាប់ខ្លួនក៏ដោយ ។ ការស្លាប់របស់ តាម៉ុក ផ្តល់ជាសញ្ញាមួយដល់សាលាក្តីខ្មែរក្រហមថា ជនត្រូវចោទដទៃទៀតក៏នឹងអាចស្លាប់ដែរមុននឹងទទួលបាននូវការកាត់ទោសចប់ចុងចប់ដើមនោះ ។ បើសិនជាមានជនត្រូវចោទម្នាក់ ឬពីរនាក់ ឬទាំងអស់ស្លាប់មុននឹងទទួលបាននូវការកាត់ទោស នេះគឺជាការបាត់បង់នូវយុត្តិធម៌យ៉ាងធំសម្បើមសម្រាប់ប្រជាជន និងសង្គមទាំងមូល ។ ករណី០០២ នៅសាលាក្តីខ្មែរក្រហមគឺជាករណីដ៏សំខាន់ដោយសារតែជនជាប់ចោទទាំងបួនគឺជាមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ដែលជាអ្នកបង្កើតគោលនយោបាយផ្សេងៗដែលទីបំផុតប្រជាជនប្រមាណជាងពីរលាននាក់បានបាត់បង់ជីវិត និងនាំប្រទេសឲ្យធ្លាក់ទៅក្នុងឋាននរកមួយ ។ ករណី០០២នេះក៏នឹងធ្វើឲ្យប្រជាជនមានការខឹងសម្បា និងធុញទ្រាន់ដែរដោយសារតែភាពចាស់ជរានិងភាពទ្រុឌទ្រោមខាងសុខភាពរបស់ជនជាប់ចោទនៅពេលដែលជនជាប់ចោទទាំងនោះនិយាយថា ខ្លួនមិនអាចអង្គុយឲ្យលើសពី១៥នាទី ឬកន្លះម៉ោងបាន ។

កម្ពុជាបានបាត់បង់ តាម៉ុក រួចមកហើយ ហើយកម្ពុជាមិនចង់បាត់បង់ជនជាប់ចោទដទៃទៀតដោយមិនបានឆ្លងកាត់ការជំនុំជម្រះត្រឹមត្រូវទេ ។ ប្រជាជនកម្ពុជាមិនស្តាយនឹងការស្លាប់ដោយប្រការណាមួយរបស់ជនជាប់ចោទទេ ប៉ុន្តែប្រជាជនកម្ពុជាស្តាយព័ត៌មានដែលនឹងទៅជាមួយសាកសពទាំងនោះ ។ ប្រជាជនកម្ពុជាចង់ដឹងថាតើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ឪពុកម្តាយនិងសាច់ញាតិរបស់ខ្លួន? **ញាណ សុជាតិ**

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦.៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីសង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិសាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**

# ការពិភាក្សាជាមួយផលិតកររឿង "វាលពិឃាត"

ខ្សែភាពយន្ត «វាលពិឃាត» មានឥទ្ធិពលយ៉ាងខ្លាំងមកលើខ្ញុំ ។ ខ្ញុំនៅចាំថា ខ្ញុំអង្គុយមើលខ្សែភាពយន្តនោះ នៅសមាគមនិស្សិតនៅឆ្នាំ១៩៨៤ ។ នៅពេលនោះខ្ញុំកំពុងតែចាប់ផ្តើមសិក្សាមុខវិទ្យាល្ខោននៅឆ្នាំទីមួយនៅសាកលវិទ្យាល័យសិល្បៈ ដាធីងតុន នៅ ឌឺរ៉ុន នៃប្រទេសអង់គ្លេស ។ ខ្សែភាពយន្តនេះបានជះឥទ្ធិពលដល់ការផលិតល្ខោនរបស់ខ្ញុំដោយវាបានធ្វើឲ្យខ្ញុំសម្រេចចិត្តរួមបញ្ចូលប្រទេសកម្ពុជាជាគ្រឹះដំបូង និងជាធនធានមួយសម្រាប់ការផលិតល្ខោនរបស់ខ្ញុំនៅពេលអនាគត ។ រូបរាងនៃការចាកចោលទីលំនៅ ការក្បត់គ្នានិងការផ្សះផ្សានៅក្នុងខ្សែភាពយន្តបានធ្វើឲ្យខ្ញុំចង់ធ្វើការស្រាវជ្រាវបន្តទៅលើអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងអំពើប្រល័យពូជសាសន៍ផ្សេងទៀត ។ វាបានធ្វើឲ្យខ្ញុំបង្កើតជាសំណួរពីរដែលបច្ចុប្បន្នគឺជាចំណុចសំខាន់នៃការងារល្ខោនដែលខ្ញុំបានរៀបចំ និងបង្កើតឡើង ។ ទីមួយ គឺនៅក្នុងស្ថានភាពនៃការបំភ្លេចចោលនូវអ្វីដែលបានកើតឡើងចំពោះមនុស្សនិងវិញ្ញាណទាំងឡាយនៅពេលដែលអ្នកទាំងនោះត្រូវបានដាក់ឲ្យនៅឯកា គឺពេលដែលចាំបាច់បំផុត ។ ទីពីរ តើការរួចរស់មានជីវិតសារជាថ្មីមានអត្ថន័យយ៉ាងដូចម្តេចចំពោះបុគ្គល និងសហគមន៍ទាំងអស់នៅលើពិភពលោក ។ សំណួរទាំងពីរនេះបន្តផ្សំគ្នាដើម្បីបង្កើតជាផ្នែករួមមួយនៃការប្រតិបត្តិការងារដែលបានធ្វើឲ្យមានការចោទជាសំណួរបន្ថែមថាតើហេតុអ្វីបានជាអំពើប្រល័យពូជសាសន៍នៅតែមានវត្តមាននៅក្នុងសង្គមនិងជីវិតរបស់យើង ។ ខ្ញុំបានទៅជួប ឡូត កុតណាម ដែលជាអ្នកផលិតខ្សែភាពយន្ត «វាលពិឃាត» ពីព្រោះគាត់ជាមនុស្សដែលសក្តិសមជាងគេក្នុងការផ្តល់សម្ភាសន៍ជាពិសេសនៅអំឡុងពេលដែលមានការជំនុំជម្រះក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការប្រកាសសាលក្រម ឌុច នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។ ខាងក្រោមនេះគឺជាចម្លើយរបស់ ឡូត កុតណាម ដែលឆ្លើយតបនឹងសំណួរទាំងបួន ។

**តើលោកអាចរៀបរាប់ពីតួនាទី និងភារកិច្ចរបស់លោកក្នុងនាមលោកជាសមាជិកម្នាក់នៃក្រុមបានទេ?**

ខ្ញុំគឺជាសមាជិកម្នាក់ដែលមានចំណាប់ចំណូលចិត្តទៅលើការប្រែប្រួលអាកាសធាតុ ការអប់រំនិងខុសរ្សាហកម្មថ្នៃប្រឌិត ។ ខ្ញុំជាអតីតប្រធានគណៈកម្មការស្រាវជ្រាវចម្រុះទទួលបន្ទុកថវិកាចំណាយលើផ្នែកទំនាក់ទំនងនៅឆ្នាំ២០០២-២០០៣ (ប្រទេសអង់គ្លេស) និងប្រធានគណៈកម្មការចម្រុះទទួលបន្ទុកថវិកាចំណាយលើបំរែបំរួលអាកាសធាតុឆ្នាំ២០០៧ ។

**តើលោកអាចរៀបរាប់ពីផលប៉ះពាល់ដែលប្រទេសកម្ពុជាបានជះឥទ្ធិពលដល់កិច្ចសហប្រតិបត្តិការរបស់លោក ហើយប្រសិនបើអាចទៅរួច តើលោកអាចរៀបរាប់ពីទស្សនៈរបស់លោកទៅលើសាលក្រម និងការផ្តន្ទាទោស ឌុច ដែលជាប្រធានមន្ទីរ ស-២១ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ដែរឬទេ?**

សាមសិបប្រាំឆ្នាំបន្ទាប់ពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម យើងនៅតែឃើញមានជម្លោះ ។ មនុស្សម្នាក់ៗសុទ្ធតែបានបាត់បង់សមាជិកគ្រួសាររបស់ខ្លួន ។ វាមានភាពគួរឲ្យរន្ធត់ចំពោះទំហំ និងការសម្លាប់មនុស្សដោយគ្មានហេតុផលនៅក្នុងប្រទេសកម្ពុជា ។ ចំពោះមនុស្សជាច្រើននៅប្រទេសអង់គ្លេស កម្ពុជាគឺជាប្រទេសមួយដែលពោរពេញដោយសង្គ្រាមនិងអំពើសាហាវឃោរឃៅ ប៉ុន្តែ វាគឺជាប្រទេសដ៏មានសន្តិភាពមួយមុនឆ្នាំ១៩៦៤ ។ នៅពេលនោះប្រទេសកម្ពុជាត្រូវបានហៅថា ជាកន្លែងដ៏ស្អាតបរិសុទ្ធ កន្លែងដែលបានឆ្លោះទៅរកសម័យកាលក្រោយអាណានិគមនិងមិនមានការរំខានពីខាងក្រៅ ។ សហរដ្ឋអាមេរិកបានទាញប្រទេសនោះឲ្យធ្លាក់ក្នុងសង្គ្រាម ។ បន្ទាប់មានសង្គ្រាមជាមួយវៀតណាម អាមេរិកបានទម្លាក់គ្រាប់បែកមកលើភូមិដែលនៅជិតព្រំដែនពីព្រោះអាមេរិកព្រួយបារម្ភថាជនកុម្មុយនីស្តទាំងប៉ុន្មានបានលាក់ខ្លួននៅទីនោះ ។ នៅពេលដែលប្រជាជនស៊ីវិល

ត្រូវបានសម្លាប់ ប៉ុល ពត មានការខឹងសម្បាដែលបណ្តាលឲ្យមានការបះបោរនិងកាន់អំណាច ។ ប្រសិនបើកម្ពុជាសម័យទំនើបត្រូវអភិវឌ្ឍ អ្នកនៅបស្ចិមប្រទេសត្រូវតែទទួលខុសត្រូវចំពោះបញ្ហាដែលខ្លួនបានបង្កឡើង និងផ្តល់ជំនួយ ។ ការព្រួយបារម្ភរបស់បស្ចិមប្រទេសបានបង្កឲ្យមានបញ្ហានៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំបានឃើញដោយផ្ទាល់នូវបញ្ហាដ៏ធ្ងន់ធ្ងរដែលប្រទេសកម្ពុជាបានជួបប្រទះរហូតដល់បច្ចុប្បន្ន ។ នៅពេលដែលខ្ញុំបានធ្វើទស្សនកិច្ចទៅជួបជាមួយប្រធានមូលនិធិកុមាររបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសអង់គ្លេសនៅឆ្នាំ២០០៣ ខ្ញុំបាននិយាយថាប្រទេសអង់គ្លេសតែងតែជាអ្នកនាំមុខគេ ដូច្នេះយើងត្រូវតែធ្វើបែបនេះម្តងទៀត ។ យើងត្រូវតែចំណាយដើម្បីកេរ្តិ៍ឈ្មោះរបស់យើង ។ នៅសតវត្សរ៍ទី១៩ នៅពេលដែលអង់គ្លេសគឺជាប្រទេសមូលធននិយមនាំមុខគេ យើងបានរកឃើញមធ្យោបាយផ្សះផ្សាតាមរយៈការលើកកម្ពស់សិទ្ធិមនុស្ស ។ យើងបានជំរុញបញ្ហាដូចជាការបញ្ឈប់ទាសភាពនិងការការពារកុមារឲ្យក្លាយទៅជាបញ្ហានាំមុខគេ ។ ហើយយើងត្រូវតែស្វែងរកមធ្យោបាយដើម្បីបង្ហាញពីការយល់ឃើញរបស់យើងចំពោះអ្នកដទៃបែបនេះម្តងទៀត ។ ការងាររបស់មូលនិធិកុមាររបស់អង្គការសហប្រជាជាតិនៅកម្ពុជាមិនមែនជាការងារស្រួលទេ ។ វាគឺជាការងារលំបាកមួយ ។ យើងធ្វើការជាមួយក្មេងៗដែលរស់នៅក្នុងស្ថានភាពដ៏លំបាក ដូចជាក្មេងដែលមានជីវភាពក្រីក្រ ហើយញៀនថ្នាំនិងជួញដូរផ្លូវភេទ ។ ទោះបីជាយ៉ាងណាក៏ដោយ វានៅតែមានមធ្យោបាយសម្រាប់ដោះស្រាយ ។ គម្រោងខ្លះរបស់មូលនិធិកុមាររបស់អង្គការសហប្រជាជាតិដែលខ្ញុំបានឃើញនៅពេលដែលខ្ញុំធ្វើទស្សនកិច្ចមកប្រទេសកម្ពុជាដែលមានដូចជា គម្រោងឲ្យក្មេងជិទង់ធ្វើការងារដើម្បីសហគមន៍ បង្រៀនក្មេងៗឲ្យធ្វើជាចុងភៅនិងផ្តល់អនាគតដ៏ត្រចះត្រចង់ឲ្យក្មេងៗបានធ្វើឲ្យខ្ញុំមានក្តីសង្ឃឹមនិងមានគំនិតខ្លះចំពោះអនាគត ។ ប្រជាជនកម្ពុជានៅតែរំពឹកពីអតីតកាលរបស់ប្រទេស ។ ប៉ុន្តែបន្ទាប់ពីអ្វីទាំងអស់បានកន្លងផុតទៅកម្ពុជានឹងមានអនាគតប្រសើរជាងមុន ។ ខ្ញុំសង្ឃឹមថាមូលនិធិកុមាររបស់អង្គការសហប្រជាជាតិនិងអ្នកដទៃទៀតអាចជួយដល់រឿងនេះបាន ។

**តើលោកអាចបកស្រាយពីសារសំខាន់ និងទំនាក់ទំនងនៃពាក្យ «ការពិត» និង «ការចងចាំ» ក្នុងនាមលោកជាបុគ្គលម្នាក់ និងជាសមាជិកម្នាក់បានដែរឬទេ?**

ខ្ញុំអាចឆ្លើយនឹងសំណួរនេះដោយប្រើប្រាស់អារម្មណ៍ពិតនិងការចងចាំដែលមានជាប់ពាក់ព័ន្ធនឹងវាលពិឃាត ។ ខ្សែភាពយន្តនោះបានបង្ហាញពីរឿងរ៉ាវជីវិតពិតរបស់ប្រជាជនកម្ពុជា ។ លទ្ធផលនៃខ្សែភាពយន្តនោះបានដក់នៅក្នុងចិត្តរបស់ខ្ញុំ ។ ទីមួយ វាបានក្លាយទៅជាពាក្យសម្តីមួយទៀតនៅពេលដែលយើងនិយាយពីអំពើប្រល័យពូជសាសន៍ វាគឺជាការបង្កើតជាពាក្យសម្តីមួយ ។ ទីពីរ នៅប៉ុន្មានឆ្នាំមុន មានរឿងដ៏អស្ចារ្យមួយកើតឡើងចំពោះខ្ញុំគឺនៅឆ្នាំ១៩៨៥ រដ្ឋាភិបាលបានបញ្ជូនខ្ញុំដែលជាជនជាតិអង់គ្លេសទៅចាក់បញ្ចាំងខ្សែភាពយន្តដើម្បីប្រកួតប្រជែងនៅទីក្រុងគៀវ (ប្រទេសអ៊ុយក្រែន) ចំនួនមួយសប្តាហ៍បន្ទាប់មកយើងបានឈ្នះពានរង្វាន់អូស្ការ ។ ខ្ញុំបានដឹងពីប្រទេសអ៊ុយក្រែនតែបន្តិចបន្តួចប៉ុណ្ណោះ ខ្ញុំពិតជាមិនដឹងពីទស្សនៈនយោបាយ សាសនា និងសេដ្ឋកិច្ចរបស់ប្រទេសនោះទេ ។

ពេលខ្លះ យើងបានចាក់បញ្ចាំងខ្សែភាពយន្តនៅព្រឹកថ្ងៃសៅរ៍នៅក្នុងរោងកុនដ៏ធំមួយ ។ នៅទីនោះ មានក្មេងៗប្រមាណ ២.០០០នាក់មើល បន្ទាប់មកក៏មានសំណួរល្អៗជាច្រើន ប៉ុន្តែមិនមាននរណាម្នាក់និយាយអំពីកម្ពុជាឡើយ ។ សំណួរទាំងអស់នោះគឺទាក់ទងនឹងសង្គ្រាមនិងបញ្ហាដ៏គួរចាប់អារម្មណ៍ ។ ឆ្នាំមុន ខ្ញុំបានជួបជាមួយ យូសឆិនកូ ប្រធានាធិបតីថ្មីនៃប្រទេស (អ៊ុយក្រែន) នៅដាវ៉ូ (ប្រទេសស៊ុីស) ។

មានគេណែនាំខ្ញុំឲ្យស្គាល់លោកប្រធានាធិបតី ប៉ុន្តែគាត់និយាយភាសាអង់គ្លេសមិនសូវជាល្អទេ បន្ទាប់មកខ្ញុំបានឮមនុស្សម្នាក់និយាយថា ហ្នឹងហើយ ខ្ញុំគឺជាអ្នកផលិតខ្សែភាពយន្តរឿងវាលពិឃាត ។ ក្រោយមកគាត់ក៏បានឱបខ្ញុំ ហើយនិយាយជាមួយខ្ញុំ ។ ខ្ញុំគិតថាអ្នកទាំងនោះបានថតចម្លងខ្សែភាពយន្តរបស់ខ្ញុំ គាត់មិនបាននិយាយថាអ្នកទាំងនោះបានថតចម្លងខ្សែភាពយន្តរបស់ខ្ញុំទេ ប៉ុន្តែមានខ្សែភាពយន្តថតចម្លងជាច្រើនត្រូវបានយក

ទៅចាក់បង្ហាញនៅគ្រប់សាលារៀននៅអ៊ុយក្រែន ។ គ្រប់ក្មេងៗនៅអ៊ុយក្រែនសុទ្ធតែធ្លាប់មើលខ្សែភាពយន្តនេះ ។

គាត់បាននិយាយថាតើអ្នកដឹងទេថានៅអំឡុងបដិវត្តន៍ទឹកក្រូច វាមិនមានការពិភាក្សាពីសង្គ្រាមស៊ីវិលទេ ។ គាត់បាននិយាយថា នោះគឺដោយសារតែយើងដឹងពីអ្វីដែលសង្គ្រាមបានធ្វើ ។ យើងឃើញអ្វីដែលបានកើតឡើងនៅកម្ពុជា ហើយវានឹងមិនកើតឡើងនៅក្នុងប្រទេសអ៊ុយក្រែនទេ ។ បន្ទាប់ពីឮដូច្នេះហើយ អ្នកនឹងយល់ដឹងភ្លាមៗពីអំណាចនៃភាពពិតរបស់ភាពយន្ត ។ ខ្ញុំមិនអាចធ្វើជាដឹងថា ខ្ញុំបានដឹងពីអ្វីដែលនឹងកើតឡើងនៅពេលផលិតខ្សែភាពយន្តនេះទេ ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់ឲ្យប្រជាជនដឹងពីអំណាចនិងសារសំខាន់នៃភាពយន្តដែលជាប្រព័ន្ធផ្សព្វផ្សាយមួយ និងដឹងពីឥទ្ធិពលរបស់វាទៅលើជីវិតរបស់ប្រជាជន ។

***តើលោកអាចផ្តល់ដកស្រង់ពាក្យសម្តីណាមួយរបស់លោក ឬរបស់អ្នកដទៃដែលអាចឆ្លុះបញ្ចាំងពីសារសំខាន់នៃការពិត និងការចងចាំរបស់សង្គមយើងបច្ចុប្បន្នទេ?***

ខ្ញុំចង់ឲ្យសេដ្ឋកិច្ចពិភពលោករួចផុតពីវិបត្តិដែលកើតឡើងបច្ចុប្បន្ន បន្ទាប់មកក្លាយទៅជាមូលដ្ឋានមួយដែលអាចបង្កើតសង្គមដ៏ជោគជ័យនិងមាននិរន្តរភាព ។ ប៉ុន្តែ យើងកំពុងរស់នៅក្នុងពិភពលោកដែលមានការគំរាមកំហែងគ្នាទៅវិញទៅមក ។ វាគឺជាការគម្រាមកំហែងដែលមានសក្តានុពលអាចធ្វើឲ្យជីវិតរបស់យើងឡើងចុះគ្រប់ពេលវេលា ។

នៅក្នុងស្ថានភាពនៃការប្រកួតប្រជែងគ្នា ប្រទេសដែលចង់ឲ្យប្រជាជនរបស់ខ្លួនមានជីវិតប្រសើរជាងមុនមិនត្រឹមតែតម្រូវឲ្យធនធានប៉ុណ្ណោះទេ គឺត្រូវមានឆន្ទៈនយោបាយផងដែរ ។

ដូចដែលខ្ញុំឃើញអ្នកដែលនៅក្រោយសង្គ្រាមលោកទីពីរគឺជាអ្នកប្រឈមមុខ ។ បុព្វការីជនរបស់យើងបានបន្សល់ទុកនូវកេរដំណែលដ៏អស្ចារ្យដើម្បីចាប់ផ្តើមបង្កើតសង្គមដែលមានស្មើគ្នាជាងមុន និងអនាគតប្រសើរជាងមុន ។

ប៉ុន្តែយើងបានបណ្តោយឲ្យឱកាសជាច្រើនបានកន្លងហួសដែលបន្សល់ទុកនូវគ្រោះថ្នាក់ដល់យើងដែលនៅរស់ វាមិនត្រឹមតែជាបំណុលពិភពលោកទេ តែថែមទាំងជាការបាត់បង់ធនធានធម្មជាតិគ្រប់បែបយ៉ាងរួមទាំងទឹក ។

មធ្យោបាយតែមួយគត់ដែលអាចកែប្រែស្ថានភាពគឺនៅក្នុងថ្នាក់រៀនរួមទាំងថ្នាក់រៀននៅក្នុងប្រទេសកម្ពុជាផងដែរ ។ តើយើងនឹងបណ្តុះបណ្តាលមេដឹកនាំនយោបាយមួយជំនាន់ដែលមានភាពក្លាហាន និងការស្រមើស្រមៃដើម្បីអនាគតដែរឬទេ? តើយើងអាចប្រើប្រាស់មនុស្សដែលមានការច្នៃប្រឌិតអប់រំក្មេងៗនៅគ្រប់ប្រទេសឲ្យចាប់ផ្តើមជីវិតដ៏ប្រសើរជាងមុនជាងមនុស្សចាស់មុនក្មេងជំនាន់ក្រោយនេះដែរឬទេ? ដូច្នេះ យើងត្រូវផ្តល់ការណែនាំ ផ្តល់ការអប់រំ និងការលើកទឹកចិត្ត ។

យើងចាំបាច់ត្រូវតែធ្វើវា ពីព្រោះអ្វីដែលក្មេងៗទាំងនេះនឹងជួបប្រទះមានទ្រង់ទ្រាយធំ ហើយលទ្ធផលនៃកិច្ចខំប្រឹងប្រែងគឺមិនពឹងផ្អែកទៅលើអ្វីទាំងអស់ក្រៅពីអនាគត ។

**ថេន អានហ៊្វីល**




# ស្វែងរកសាច់ញាតិនៅក្នុងរូបថត

នាងខ្ញុំឈ្មោះ ចេស៊ីកា កៀសាន់ សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ។ ម្តាយរបស់ខ្ញុំឈ្មោះ ចក់ ប៉ូលីន មានស្រុកកំណើតនៅក្នុងខេត្តព្រៃវែង ចំណែកស្រុកកំណើតរបស់ឪពុកខ្ញុំវិញប្រហែលនៅព្រែកពោធិ៍ ក្នុងខេត្តកំពង់ចាម ។ ម្តាយរបស់ខ្ញុំបានមកកាន់សហរដ្ឋអាមេរិកក្នុងនាមជាជនភៀសខ្លួនម្នាក់ដូចជាជនរងគ្រោះនៃរបបខ្មែរក្រហមដទៃទៀតដែរ ។ ឪពុកម្តាយ បងប្អូនស្រីពីរនាក់ និងបងប្អូនប្រុសម្នាក់របស់ម្តាយខ្ញុំរស់នៅក្នុងប្រទេសកម្ពុជា ។ ម្តាយរបស់ខ្ញុំបានទៅលេងស្រុកខ្មែរម្តងក្នុងឆ្នាំ១៩៩៧ ហើយពេលនោះគាត់បានជួបជាមួយប្អូនស្រីរបស់គាត់ ។ ពេលនោះម្តាយរបស់ខ្ញុំមិនបានទៅលេងស្រុកកំណើតទេ ដោយសារតែស្ថានភាពសន្តិសុខមិនសូវល្អ ហើយមានគ្រាប់មីនបង្កប់នៅក្នុងដីផង តែគាត់ស្នាក់នៅទីក្រុងភ្នំពេញ ចំណែកប្អូនស្រីរបស់គាត់បានមកភ្នំពេញដើម្បីជួបគាត់ ។ ក្រោយមក ម្តាយរបស់ខ្ញុំបានត្រឡប់មកសហរដ្ឋអាមេរិកវិញ ។ ចាប់តាំងពីពេលនោះមក ម្តាយរបស់ខ្ញុំមិនបានទំនាក់ទំនងជាមួយសាច់ញាតិនៅស្រុកខ្មែរទេ ដោយគ្មានវិធីទាក់ទង ហើយម្តាយរបស់ខ្ញុំក៏មិនដែលបានទៅលេងស្រុកខ្មែរទៀតដែរ ។ ម្តាយរបស់ខ្ញុំមានចិត្តសង្វែកយ៉ាងខ្លាំង ពេលដែលគាត់មិនដឹងពីដំណឹងពីសាច់ញាតិរបស់គាត់ ។ ដូច្នេះ ខ្ញុំមានរូបថតមួយសន្លឹករបស់ប្អូនស្រីម្តាយខ្ញុំដែលបានថតកាលពីឆ្នាំ១៩៩៧ នៅមុខព្រះបរមរាជវាំង ។ បើសិនជាលោកអ្នកស្គាល់អ្នកនៅក្នុងរូបថតនេះ ឬបើសិនជាអ្នកដែលមាននៅក្នុងរូបថតបានជ្រាបពីព័ត៌មាននេះ សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។ ខ្ញុំនិងម្តាយរបស់ខ្ញុំចង់ដឹងពីសុខទុក្ខរបស់សាច់ញាតិរបស់យើងយ៉ាងខ្លាំង ។

**សូមអរគុណ**



រូបទីពីរ រាប់ពីឆ្វេងគឺ មីងរបស់ ចេស៊ីកា កៀសាន់ ដែលកំពុងស្វែងរក

# ចង់ជួបមិត្តភក្តិបាត់ខ្លួនដោយសារសង្រ្គាមនៅកម្ពុជា

*ស្ថានទូតកម្ពុជានៅប្រទេសបារាំងបានប្រាប់អំពីគេហទំព័រ* *www.dccam.org* *មកខ្ញុំ ហើយខ្ញុំក៏ទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាភ្លាម ដើម្បីសួររកដំណឹងរបស់មិត្តភក្តិប្តីខ្ញុំម្នាក់ដែលជាជនជាតិខ្មែរ ហើយបានមករៀនប្រទេសបារាំង។ ប្តីរបស់ខ្ញុំឈ្មោះ* *Colombier Christian* *។ កាលនោះ ប្តីរបស់ខ្ញុំមានមិត្តភក្តិម្នាក់មកពីប្រទេសកម្ពុជា ។ គាត់មានឈ្មោះថា តាន់ យូលាង ។ ប្តីរបស់ខ្ញុំ ហើយនិង តាន់ យូលាង រៀននៅថ្នាក់ទី៥ជាមួយគ្នានៅអនុវិទ្យាល័យ* *Berthecot* *នៅទីក្រុង* *Toulouse* *ប្រទេសបារាំង ហើយខ្ញុំក៏រៀននៅក្នុងថ្នាក់នោះដែរ ។ តាន់ យូលាង បានប្រាប់យើងថា កាលពីឆ្នាំ១៩៧២ ឬ១៩៧៣ គាត់មានអាយុប្រមាណជា ១៧ឬ១៨ឆ្នាំ ។ កាលនោះប្រទេសកម្ពុជាកំពុងមានសង្រ្គាម ហើយឆ្នាំ១៩៧៣ យូលាង បានប្រាប់យើងថា គាត់ត្រូវតែទៅប្រទេសកម្ពុជាវិញ ដើម្បីជួបជុំជាមួយគ្រួសាររបស់គាត់ ។ ចាប់តាំងពីពេលនោះមក ប្តីរបស់ខ្ញុំមិនដែលឮដំណឹងអ្វីពី យូលាង នោះទេ ។ មុនពេលដែល យូលាង បែកចេញទៅ គាត់បានប្រាប់ប្តីខ្ញុំថា យូលាង នឹងផ្តល់ដំណឹងមកគាត់ ។ ប៉ុន្តែ យូលាង មិនដែលផ្តល់ដំណឹងអ្វីឡើយ ។ ខ្ញុំមានរូបថតមួយសន្លឹករបស់ យូលាង ដែលថតដោយប្តីរបស់ខ្ញុំកាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៣ ។ នៅក្នុងរូបថតនេះ យូលាង កំពុងឈរនៅក្បែរម៉ូតូម៉ូប៊ីឡែតម៉ាក* *Peugeot* *១០៤ របស់គាត់នៅចំណតរថយន្តនៃហាងលក់ទំនិញ យីហោ* *Carrefour et Trigano* *។*

*ប្រសិនបើបងប្អូនណាបានស្គាល់ ឬបានឮដំណឹងពីឈ្មោះខាងលើនេះ សូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈអាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬតាមប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។*




**តាន់ យូលាង ថតនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៣**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬអ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ : ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ : លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 134, February 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.